# សៀវភៅណែនាំ

# អំពី ច្បាប់ស្តីពីការងារ

# នៃប្រទេសកម្ពុជា

# សំរាប់វិស័យកាត់ដេរ

---

២០០៥ (កែសម្រួលឡើងវិញ ២០១៣)

ការិយាល័យពលកម្មអន្តរជាតរោងចក្រកាន់តែប្រសើរនៅកម្ពុជា

better factories Cambodia

International Labour Organization

# សៀវភៅណែនាំ
# អំពី ច្បាប់ស្តីពីការងារ
# នៃប្រទេសកម្ពុជា
# សំរាប់វិស័យកាត់ដេរ

២០០៥ (កែសម្រួលឡើងវិញ ២០១៣)

ការិយាល័យពលកម្មអន្តរជាតិ

រោងចក្រកាន់តែប្រសើរនៅកម្ពុជា

**រក្សាសិទ្ធិដោយអង្គការពលកម្មអន្តរជាតិ ឆ្នាំ២០០៥**
**បោះពុម្ពផ្សាយលើកទីមួយ ឆ្នាំ២០០៥**

បោះពុម្ពឡើងវិញឆ្នាំ២០១១ហើយកែប្រែសំរាប់តែផ្លូះបញ្ចាំងសេចក្តីបន្ថែមលើសេចក្តីជូនដំណឹង ០៩៩/១០ និង០៩១/១១ របស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ។

បោះពុម្ពឡើងវិញឆ្នាំ២០០៨ ហើយកែប្រែសំរាប់តែផ្លុះបញ្ចាំងសេចក្តីបន្ថែមលើមាត្រា ១៣៩ និង ១៤៤ នៃច្បាប់ការងារ និងសេចក្តីជូនដំណឹង ៧៤៥/០៦ និង ០៣២/០៨ របស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ។

ការបោះពុម្ពផ្សាយនានារបស់ការិយាល័យពលកម្មអន្តរជាតិ ទទួលបានការរក្សាសិទ្ធិ ដោយអនុលោមតាមពិធីសារទីពីរនៃអនុសញ្ញាស្តីពីសិទ្ធិលើសកម្មសិទ្ធិបញ្ញាជាសកល។ តែទោះជាយ៉ាងនេះក្តី ដំណកស្រង់ខ្លីៗពីការបោះពុម្ពទាំងនេះ អាចត្រូវបានអនុញ្ញាតដោយពុំចាំបាច់សុំការអនុញ្ញាតឡើយ ក្រោមល័ក្ខខ័ណ្ឌដែលប្រភពនៃការដកស្រង់នោះ ត្រូវបានគូសបញ្ជាក់។
ចំពោះការផលិតឡើងវិញ ឬ ការកែប្រែ ត្រូវដាក់ពាក្យសុំទៅកាន់ផ្នែកបោះពុម្ពផ្សាយ (សិទ្ធ និង ការអនុញ្ញាត) នៃការិយាល័យពលកម្មអន្តរជាតិ ដែលមានអាសយដ្ឋាននៅ *CH-1211 Geneva 22* ប្រទេសស្វីស។
ការិយាល័យពលកម្មអន្តរជាតិសូមស្វាគមន៍ការដាក់ពាក្យសុំទាំងអស់។

បណ្ណល័យ ស្ថាប័ន និង អ្នកប្រើប្រាស់ផ្សេងៗទៀតដែលបានចុះបញ្ជីនៅក្នុងចក្រភពអង់គ្លេស ជាមួយនឹងទីភ្នាក់ងារផ្តល់សិទ្ធិកម្មសិទ្ធិបញ្ញា *(Copyright Licensing Agency)* អាសយដ្ឋាន *90 Tottenham Court Road W1T 4LR* [ទូរសារលេខ: (+៤៤) (0)២០ ៧៦៣១ ៥៥០០ អ៊ីម៉េល: cla@cla.co.uk] នៅសហរដ្ឋអាមេរិក ជាមួយមជ្ឈមណ្ឌលផ្តល់ ការអនុញ្ញាតសំរាប់សិទ្ធិលើកម្មសិទ្ធិបញ្ញា *(Copyright Clearance Center)* អាសយដ្ឋាន *222 Rosewood Drive, Danver s, MA 01923* [ទូរសារលេខ:(១) (៩៧៨) ៧៥០៤៤៧០ អ៊ីម៉េល: *info@copyright .com]* ឬ នៅ ប្រទេសដទៃទៀត ជាមួយនឹង អង្គការនៃ សិទ្ធិលើកា រផលិតឡើងដែលជាដៃគូ *(Reproduction Rights Organization)* អាចធ្វើការថតចម្លងបាន ដោយអនុលោមតាមអាជ្ញាប័ណ្ណ ដែលផ្តល់អោយពួកគេ ដើម្បីគោលបំណងនេះ ។

**អង្គការពលកម្មអន្តរជាតិ**
សៀវភៅណែនាំអំពីច្បាប់ស្តីពីការងារនៃប្រទេសកម្ពុជាសំរាប់វិស័យកាត់ដេរ
ទីក្រុងភ្នំពេញ ការិយាល័យពលកម្មអន្តរជាតិ ឆ្នាំ ២០០៥

លេខសៀវភៅស្តង់ដារអន្តរជាតិ *(ISBN) 92 -2-816754-8*

មានជាភាសាអង់គ្លេសផងដែរ: សៀវភៅណែនាំអំពីច្បាប់ស្តីពីការងារនៃប្រទេសកម្ពុជាសំរាប់វិស័យកាត់ដេរ *(ISBN 92-2-116754-2)* ទីក្រុងភ្នំពេញ ឆ្នាំ២០០៥ និង ជាភាសាចិន សៀវភៅណែនាំអំពីច្បាប់ស្តីពីការងារនៃប្រទេសកម្ពុជាសំរាប់វិស័យកាត់ដេរ *(ISBN 92-2-516754-7)* ទីក្រុងភ្នំពេញ ឆ្នាំ២០០៥។

ការពិពណ៌នាដែលប្រើប្រាស់នៅក្នុងការបោះពុម្ពនានា របស់អង្គការពលកម្មអន្តរជាតិ ដែលអនុលោមតាម ការអនុវត្តន៍របស់អង្គការសហប្រជាជាតិ និង ការលើកយកមក បង្ហាញនូវសំភារៈនានា នៅក្នុងនោះមិនបង្ហាញអំពីទស្សនៈ យោបល់ របស់ ការិយាល័យពលកម្មអន្តរជាតិ ទាក់ទងនឹង ស្ថានភាពគតិយុត្តិរបស់ប្រទេសណាមួយ វិស័យ ឬ ព្រំដែននៃសិទ្ធិអំណាច របស់ប្រទេស នោះ ឡើយ ឬទាក់ទងនឹងការកំណត់ព្រំដែនរបស់ប្រទេសណាមួយនោះទេ។

ការទទួលខុសត្រូវចំពោះទស្សនៈដែលបានបង្ហាញនៅក្នុងការសិក្សា អត្ថបទដែលមានចុះហត្ថលេខា និង អត្ថបទចែកចាយផ្សេងៗទៀត គឺធ្លាក់ទៅលើអ្នកនិពន្ធទាំងស្រុង ហើយការបោះពុម្ពផ្សាយមិនមែនសំដៅយកការយល់ព្រមរបស់ ការិយាពលកម្មអន្តរជាតិ លើទស្សនៈយោបល់ដែលបញ្ចេញនៅក្នុងការបោះពុម្ពៈទេ។

ការយោងទៅរកឈ្មោះក្រុមហ៊ុន និងផលិតផលពាណិជ្ជកម្ម ហើយនិងដំណើរការផ្សេងៗទៀត មិនកំណត់អំពី ការយល់ព្រមរបស់ការិយាល័យពលកម្មអន្តរជាតិទេ ហើយការខកខានមិនបានលើកយកក្រុមហ៊ុន ឬ ផលិតផលពាណិជ្ជកម្មជាក់លាក់ ឬដំណើរ ការណាមួយ មិនមែនជាសញ្ញាសំគាល់ពីការមិនយល់ព្រមទេ ។

ការបោះពុម្ពផ្សាយនានា របស់អង្គការពលកម្មអន្តរជាតិ អាចរកបានតាមរយៈពាណិជ្ជករលក់សៀវភៅធំៗ ឬដោយផ្ទាល់ ពីផ្នែក បោះពុម្ពផ្សាយរបស់អង្គការពលកម្មអន្តរជាតិនៃការិយាល័យពលកម្មអន្តរជាតិ ដែលមានអាសយដ្ឋាន *CH-1211 Geneva 22* ប្រទេសស្វីស។ សៀវភៅ និង បញ្ជីរាយ ឈ្មោះការបោះពុម្ពផ្សាយថ្មី អាចរកបានដោយឥតគិតថ្លៃ នៅអាសយដ្ឋានខាងលើ ឬតាមរយៈអ៊ីម៉េលៈ *pubvente@ilo.org* ។

សូមមើលវិបសាយរបស់យើងខ្ញុំ www.ilo.org/pubins

សំរាប់ពត៌មានបន្ថែមឬច្បាប់ចំលងបន្ថែមការបោះពុម្ពផ្សាយ
នេះ សូមទាក់ទងៈ


## អង្គការពលកម្មអន្តរជាតិ

**រោងចក្រកាន់តែប្រសើរនៅកម្ពុជា**

ផ្ទះលេខ ៩ ផ្លូវ ៣២២ ចុះពីមហាវិថីនរោត្តម
ប្រអប់សំបុត្រ ២៦៤២ ភ្នំពេញ ២២៣០២
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទៈ +៨៥៥ ២៣ ២១២ ៨៤៧/ ២២០៣៦២
ភ្ជាប់ទៅលេខ ១០៦-៩
ទូរសារៈ +៨៥៥ ២៣ ២១២ ៩០៣
អ៊ីម៉េលៈ *betterfactories@ilo.org*
អ្នកដែលត្រូវទំនាក់ទំនងៈ
លោក ទ័រម៉ូ ប៉ូទីអៃណិន ( Tuomo Poutiainen )
ប្រធានទីប្រឹក្សាបច្ចេកទេស

## ការិយាល័យពលកម្មអន្តរជាតិ

**ការិយាល័យអនុតំបន់សំរាប់អាស៊ីបូព៌ា**

ការិយាល័យៈ ជាន់ទី១០
អគារអង្គការសហប្រជាជាតិ
រុក្ខវិថី Rajdanern Nok ប្រអប់សំបុត្រ ២-៣៤៩
ទីក្រុងបាងកក់ ១០២០០
ប្រទេសថៃ
ទូរស័ព្ទៈ+៦៦ ២ ២៨៨ ២៥៤៣
ទូរសារៈ+៦៦ ២ ២៨៨ ៣០៤៣
អ៊ីម៉េលៈ suradee@ilo.org
អ្នកដែលត្រូវទំនាក់ទំនងៈ
លោកស្រី suradee Bhadrasirl (ស៊ីរ៉ាឌី បាថ្រាស៊ីរី)
មន្ត្រីកម្មវិធី

## មូលនិធិ

គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជារបស់អង្គការពលកម្មអន្តរជាតិ ទទួលមូនិធិពី:

ក្រសួងការងាររបស់សហរដ្ឋអាមេរិក
រាជរដ្ឋាភិនៃព្រះរាជាណាចក្រកម្ពុជា
សមាគមរោងចក្រកាត់ដេរនៅកម្ពុជា

## សេចក្តីថ្លែងអំណរគុណ


យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសៀវភៅបោះពុម្ពផ្សាយមុនៗ របស់មជ្ឈ មណ្ឌលអប់រំច្បាប់សំរាប់សហាគមន៍ (CLEC) .

អ្នកនិពន្ធសូមថ្លែងអំណរគុណផងដែរចំពោះ លោក Ken loo ( ខិន លូ) (សមាគមរោងចក្រកាត់ ដេរនៅកម្ពុជា) លោក គង់ ផល្លៈ លោក ម៉ែន និម្មិត និង លោក ទូន ស៊ីផាន់ (ក្រុមប្រឹក្សា អាជ្ញាកណ្តាល) លោក ជាសុផល និង ក្រុមអ្នកឃ្លាំមើលល័ក្ខខ័ណ្ឌ ការងារនៃគំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជារបស់អង្គការពលកម្មអន្តរជាតិ) លោកស្រី Anne Ziebarth (អ៊ែន ហ្ស៊ីបា ត្យ ) (ទីប្រឹក្សាគំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជារបស់អង្គការពលកម្មអន្តរជាតិ) លោក Michael Lerner ( ម៉ៃឃើល លើនើ) អ្នកសំរបសំរួលគំរោង របស់មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់ សហាគមន៍ ហើយនិងតំណាង សហាជីព និង វិស័យកាត់ដេរទាំងអស់ដែលបានចូលរួមជាមតិយោបល់សំរាប់សៀវភៅណែនាំនេះ។ អ្នកនិពន្ធ សូមថ្លែងអំណរគុណជាពិសេសដល់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈដែលបានចូលរួមជាមតិយោបល់ដ៏លំអិតនិងមានតំលៃ ។



*និពន្ធដោយៈ*

លោក Daniel Adler (ដាញែល អាដល័រ) ទីប្រឹក្សាផ្នែកច្បាប់របស់មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហាគមន៍
កញ្ញា Susie Brown ( ស៊ូហ្ស៊ី ប្រោន ) ទីប្រឹក្សាផ្នែកច្បាប់របស់មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហាគមន៍
លោកស្រី Ros Harvey (រស់ ហាវី) ប្រធានទីប្រឹក្សាបច្ចេកទេស គំរោងចក្រកាន់តែប្រសើរនៅកម្ពុជារបស់អង្គការពលកម្មអន្តរជាតិ
Eduard (Kees) de Bouter (អិដវ៉ឺដ (ឃីស៍) ដឺ ប៊ូធើ)

*ប្រែសំរួលជាភាសាខ្មែរដោយៈ*
*ស៊ីន គឹមស៊ាន*
*អ៊ី សំគី*

*ប្រែសំរួលជាភាសាចិនដោយៈ*

Flying Tigers Express


រូបថតនៅទំព័រមុខត្រូវបានថតនៅរោងចក្រ *New Island Clothing (Cambodia) Co.,Ltd*

## មុព្វកថា

**ឯកឧត្តម ញ៉ែប ប៊ុនជិន**
**រដ្ឋមន្ត្រីក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ**

រាជរដ្ឋាភិបាលកម្ពុជាបានតាំងចិត្តយ៉ាងមុតមាំ ក្នុងការធានាអោយមានការអភិវឌ្ឍប្រកបដោយ ចេរភាព និង សមធម៌ ។ ការងារសមរម្យគឺជាគន្លឹះមួយក្នុងការកាត់បន្ថយភាពក្រីក្រ នេះមានន័យថា គឺជាការងារដែលមាន ល័ក្ខខ័ណ្ឌការងារដែលផ្តល់ឪកាសអោយកម្មករនិយោជិកលើកកំពស់ខ្លួនគេផ្ទាល់ និង ក្រុមគ្រួសាររបស់គេ  អោយឃ្លាតឆ្ងាយពីភាពក្រីក្របាន។

ចំនុចគន្លឹះនៃយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលឆ្នាំ២០០៤ គឺការបង្កើតការងារ និង ការធានាអោយការកែលំអល័ក្ខខ័ណ្ឌការងារ។ ជាក់ស្តែងជាងនេះទៅទៀត  រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការពង្រឹងអោយមានការគោរពច្បាប់ស្តីពីការងារ និងសន្ធិសញ្ញាអន្តរជាតិនានាអោយបានហ្មត់ចត់ ដើម្បីធានាអោយប្រាកដថាសិទ្ធិ និង ការទទួលខុសត្រូវរបស់កម្មករនិយោជិត និង និយោជក ត្រូវបានគោរព ។ នៅក្នុងឧស្សាហកម្មកាត់ដេរកិច្ចការនេះ នឹង ក្លាយជាគន្លឹះនាំឆ្ពោះទៅរកការជោគជ័យរបស់កម្ពុជានៅក្នុងពិភពលោក ទោះបីជាគ្មានកូតាក៏ដោយ។ យើងចង់ទាក់ទាញអារម្មណ៍ និងអូសទាញអ្នកបញ្ជាទិញទាំងឡាយអោយចូលរួមចំណែកក្នុងការតាំងចិត្តរបស់យើងចំពោះការងារប្រកបដោយភាពសមរម្យ។

កម្ពុជាមានច្បាប់ស្តីពីការងារ និងបទដ្ឋាននានាទំនើបៗ ដែលបានប្រសូតឡើងប្រកបដោយភាពរីកចំរើនក្នុងទសវត្សរ៍ចុងក្រោយនេះ។ ទោះបីជាយ៉ាងនេះ តំរូវការនៅតែមានដើម្បី អោយបុគ្គលដែលពាក់ព័ន្ធនឹងច្បាប់ទាំងនេះ ទទួលបាននូវការយល់ដឹងកាន់តែច្បាស់ឡើងថែមទៀត។  ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលតាមរយៈសេចក្តីបង្គាប់របស់ខ្លួនបានជួយក្នុងការបង្កើនការយល់ដឹងអំពីច្បាប់នេះ។ សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល អនុវត្តបានតែចំពោះភាគីនៃវិវាទប៉ុណ្ណោះ ហើយមិនចង់កាតព្វកិច្ចទេបើសិនជាភាគីជំទាស់នឹងសេចក្តីបង្គាប់។ ក៏ប៉ុន្តែមូលហេតុសំរាប់ការធ្វើសេចក្តីសំរេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺជាឧបករណ៍ដ៏សំខាន់មួយសំរាប់ការបកស្រាយច្បាប់។

ជាលើកទីមួយហើយនៅកម្ពុជា ដែលសៀវភៅណែនាំនេះបានប្រមូលផ្តុំនូវគ្រប់ផ្នែកនៃច្បាប់ស្តី ពីការងារ មកចងក្រងបោះពុម្ពជាសៀវភៅណែនាំនេះត្រូវបានចងក្រងឡើង ដើម្បីផ្តល់ភាពស្រួលក្នុងការអាន និង ស្វែងយល់អំពីធាតុសំខាន់ៗនៃច្បាប់។

ការបោះពុម្ពនេះ មានចំណងគ្រាន់តែជាសៀវភៅណែនាំច្បាប់ស្តីពីការងារកម្ពុជា សំរាប់វិស័យកាត់ដេរសំលៀកបំពាក់តែប៉ុណ្ណោះ។ វាមិនមែនជាការផ្តល់ប្រឹក្សាផ្នែកច្បាប់ទេ។  ក្នុងការដោះស្រាយបញ្ហាដែលទាក់ទង នឹងល័ក្ខខ័ណ្ឌការងារ ឬទំនាក់ទំនងការងារ ជាការចាំបាច់ ត្រូវតែពិគ្រោះយោបល់ជាមួយអ្នកជំនាញ ដូចជាអធិការការងារ មេធាវី សមាគមនិយោជក ឬ សហជីព និង ជាការចាំបាច់ត្រូវតែផ្អែកលើច្បាប់ស្តីពីការងារ និង បញ្ញាត្តិច្បាប់ស្តីពីការងារផ្សេងៗទៀត។

ការបោះពុម្ពនេះ គឺជាការផ្តួចផ្តើមគំនិតរបស់គំរោងកែលំអល័ក្ខខ័ណ្ឌការងារក្នុងវិស័យកាត់ដេរនៃអង្គការពលកម្មអន្តរជាតិ និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។  ក្រសួងការងារ និង បណ្តុះបណ្តាលវីជ្ជាជីវៈ មានសេចក្តីសោមនស្សរីករាយ ក្នុងការគាំទ្រសៀវភៅណែនាំនេះថាជាផ្នែកមួយនៃការលើកកំពស់ការយល់ដឹង  អោយបានកាន់តែទូលំទូលាយអំពីសិទ្ធិ និងការទទួលខុសត្រូវនៅកន្លែងធ្វើការ  និងបង្កើនការគោរពច្បាប់អោយត្រូវតាមបទដ្ឋាននៃច្បាប់ស្តីពីការងារ ។

ភ្នំពេញ. ខែ មករា ឆ្នាំ ២០០៥

**ឯកឧត្តម    ញ៉ែប      ប៊ុនជិន**
រដ្ឋមន្ត្រីក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

## អារម្ភកថា

**គ្រីស្ទីន អរវិនស៍ ក្លក (Christine Evans-Klock)**
**នាយិកា**
**ការិយាល័យអនុតំបន់អង្គការពលកម្មអន្តរជាតិសំរាប់អាស៊ីខាងកើត**

អស់រយៈបួនឆ្នាំចុងក្រោយនេះ អង្គការពលកម្មអន្តរជាតិ ហៅកាត់ថា អាយឡូ *(ILO)* បានធ្វើការតាមដាន ល័ក្ខខណ្ឌការងារនៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់សំរាប់នាំចេញរបស់ប្រទេសកម្ពុជា។យើងបានបំពេញកិច្ចការនេះដោយមានការចូលរួមជាដៃគូពីរាជរដ្ឋាភិបាលកម្ពុជា សមាគមរោងចក្រកាត់ដេរនៅកម្ពុជា និង សហជីពកម្ពុជា។ ជាញឹកញាប់ បំផុត ការរំលោភបំពាននានាចំពោះច្បាប់គឺដោយសារតែកង្វះខាតការយល់ដឹងខាងផ្នែកច្បាប់ការងារតែប៉ុណ្ណោះ។ ប្រការនេះអាចនាំអោយមានវិវាទមិនចាំបាច់ និងការបាត់បង់ការបញ្ជាទិញដែលពាក់ព័ន្ធ ។

សៀវភៅណែនាំនេះមានគោលដៅជួយនិយោជក សហជីព ក៏ដូចជាកម្មករនិយោជិតអោយយល់ដឹងអំពីច្បាប់ការងារ។ សៀវភៅនេះបញ្ចូលរាល់ប្រភពចំបងៗ ទាំងអស់នៃច្បាប់ស្តីពីការងារនៃប្រទេសកម្ពុជា ចូលក្នុងកូនសៀវភៅដែលងាយស្រួលប្រើមួយ ។

ក្នុងផ្នែកនីមួយៗ ធាតុផ្សំគន្លឹះនៃច្បាប់ត្រូវបានធ្វើការពន្យល់ណែនាំ ដោយមិនមែនប្រើប្រាស់ ភាសាអ្នកច្បាប់ ឬអ្នកនីតិបញ្ញត្តិទេ តែផ្ទុយទៅវិញ គឺដោយប្រើប្រាស់ភាសាសាមញ្ញដែលប្រជាពលរដ្ឋទូទៅអាចយល់បាន។

អង្គការពលកម្មអន្តរជាតិ មានក្តីសោមនស្សក្រៃលែងដែលបានចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលដើម្បីឱ្យការបោះពុម្ពសៀវភៅនេះលេចចេញជារូបរាងឡើងមក ។ យើងយល់ថាវាជាការចូលរួមចំនែកយ៉ាងសំខាន់ក្នុងការសំរេចគោដៅ ក្នុងយុទ្ធស្រាស្តចតុកោណរបស់រាជរដ្ឋាភិបាលដើម្បីធានាឱ្យបាននូវបទដ្ឋានការងារ និង បង្កើននូវឪកាសការងារដែលមានលក្ខណ: ល្អប្រសើរ ។ យើងសង្ឃឹមថាសៀវភៅណែនាំនេះ នឹងមានអត្ថប្រយោជន៍ចំពោះប្រទេសកម្ពុជា ក៏ដូចជាចូលរួមចំណែកក្នុងទំនាក់ទំនងការងារដែលប្រកបដោយផាសុខភាពនៅ ក្នុងរង្វង់សេដ្ឋកិច្ចដែលកំពុងតែ រីកលូតលាស់ ។

ច្បាប់នេះនឹងមានការផ្លាស់ប្តូរដោយចៀសមិនរួច ហើយការកែលំអអាចត្រូវ ធ្វើការកត់សំគាល់ ទៅតាម ពេលវេលា ដើម្បីធ្វើឱ្យសៀវភៅណែនាំនេះកាន់តែប្រសើរឡើង។ បើសិនជាអស់លោក អ្នកចង់ស្នើជាយោបល់សំរាប់ការកែលំអ សូមទំនាក់ទំនងមកកាន់អង្គការពលកម្មអន្តរជាតិ ផ្នែកគំរោងកែលំអល័ក្ខខ័ណ្ឌការងារវិស័យកាត់ដេររបស់អង្គការពលកម្មអន្តរជាតិ តាមរយៈអ៊ីម៉េល *betterfactorries@ilo.org* ដើម្បីអោយសំណើរទាំងនោះក្លាយជាការរួមចំណែកមួយនៃការបោះពុម្ពលើកក្រោយ ។

ទីក្រុងបាងកក, ខែមករា ឆ្នាំ២០០៥

**គ្រីស្ទីន អិរិនស៍ ក្លក (Christine Evens-Klock)**
នាយិកា
ការិយាល័យអនុតំបន់អង្គការពលកម្មអន្តរជាតិសំរាប់អាស៊ីខាងកើត

# មាតិកា


***ផ្នែកទី១ សេចក្តីផ្តើម*** ១

១.១ អំពីសៀវភៅណែនាំ ១

១.២ ពាក្យបច្ចេកទេស ២

***ផ្នែកទី២ បទបញ្ញត្តិការងារ*** ៣

២.១ ទិដ្ឋភាពទូទៅ ៣

២.២ កិច្ចសន្យាការងារ ៣

២.៣ អនុសញ្ញារួម ៣

២.៤ បទបញ្ជាផ្ទៃក្នុង ៤

២.៤.១ មាតិកានៃបទបញ្ជាផ្ទៃក្នុង ៤

២.៤.២ ការរៀបចំ និង ការកែប្រែបទបញ្ជាផ្ទៃក្នុង ៤

២.៤.៣ បញ្ជាផ្ទៃក្នុងត្រូវតែបិទផ្សាយ ៤

២.៥ ច្បាប់ស្តីពីការងារជាសេក្តីបង្គាប់សាធារណៈ ៥

***ផ្នែកទី៣ ការជ្រើសរើសកម្មករនិយោជិតឱ្យចូលធ្វើការ*** ៦

៣.១ អាទិភាពចំពោះប្រជាពលរដ្ឋខ្មែរ ៦

៣.២ ការជួលជនបរទេសឱ្យចូលធ្វើការ ៦

៣.៣ ការបង់ប្រាក់ដោយបេក្ខជនដាក់ពាក្យសុំធ្វើការងារត្រូវបានហាមប្រាម ៦

៣.៤ ការងារដោយបង្ខំ ៦

៣.៥ កម្មករនិយោជិតក្មេង ឬ ពលកម្មកុមារ ៦

៣.៥.១ អាយុអប្បបរមារបស់កម្មករនិយោជិក ៧

៣.៥.២ ការការពារកម្មករនិយោជិក ៧

៣.៥.៣ ការងារត្រូវតែសមស្របសំរាប់កម្មករនិយោជិកក្មេង ៧

៣.៥.៤ ការចុះបញ្ជីអំពីអាយុ ៧

៣.៦ ការពិនិត្យសុខភាព ៧

***ផ្នែកទី៤ ប្រភេទផ្សេងៗនៃកម្មករនិយោជិត*** ៨

៤.១ កិច្ចសន្យាការងាររមានថិរវេលាកំណត់ និង មិនកំណត់ ៨

៤.២ កម្មករនិយោជិតផ្តួចម្តាល ៨

៤.២.១ ពេលវេលាកំណត់ចំពោះការងារម្តងម្កាល ៨

៤.២.២ សិទ្ធរបស់កម្មករនិយោជិតម្តងម្កាល ៩

៤.៣ កម្មករនិយោជិតមិនពេញម៉ោង ៩

៤.៤ កម្មករនិយោជិតសាកល្បង ៩

៤.៤.១ រយៈពេលសាកល្បង ១០

៤.៥ ការហ្វឹកហ្វឺនកូនជាង ១០

៤.៥.១ រយៈពេលនៃការហ្វឹកហ្វឺន ១០

***ផ្នែកទី៥ ប្រាក់ ឈ្នួល*** ____ ១១

៥.១ ប្រាក់ឈ្នួលអប្បបរមា ____ ១១

៥.២ ប្រាក់ឈ្នួលអប្បបរមាសំរាប់កម្មករនិយោជិតធ្វើការតាមបរិមាណផលិតផល (កម្មករនិយោជិតដេរស៊ីុបុង) ____ ១១

៥.៣ ប្រាក់ខ្វាន់អតីតភាពការងារ ____ ១២

៥.៤ ប្រាក់ខ្វាន់ការងារទៀងទាត់ ____ ១២

៥.៥ របៀបនៃការបើកប្រាក់ឈ្នួល ____ ១៣

៥.៦ ការកាត់ប្រាក់ឈ្នួល និង ការពិន័យជាប្រាក់ ____ ១៣

៥.៧ ការជូនដំណឹងអំពីប្រាក់ឈ្នួលទៅកម្មករនិយោជិត ____ ១៤

***ផ្នែកទី៦ ថិរវេលាធ្វើការ និង ការងារបន្ថែមម៉ោង*** ____ ១៥

៦.១ ថិរវេលាធ្វើការធម្មតា ____ ១៥

៦.២ ថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ ____ ១៥

៦.៣ ម៉ោងធ្វើការដែលអាចផ្លាស់ប្តូរបាន-ការឈប់សំរាកនៅរសៀលថ្ងៃសៅរ៍ ____ ១៥

៦.៤ ថិរវេលាធ្វើការសំរាប់កម្មករនិយោជិតក្មេង ____ ១៥

៦.៥ ការងារពេលយប់ ____ ១៥

៦.៦ ការងារពេលយប់សម្រាប់កម្មករនិយោជិតក្មេង ____ ១៥

៦.៧ ការងារបន្ថែមម៉ោង ____ ១៦

៦.៧.១ ការងារបន្ថែមម៉ោងត្រូវតែថាការងារខុសពីធម្មតា និង បន្ទាន់តែប៉ុណ្ណោះ ____ ១៦

៦.៧.២ ការងារបន្ថែមម៉ោងត្រូវតែឈរលើគោលការណ៍ស្ម័គ្រចិត្ត ____ ១៦

៦.៧.៣ ការតម្រូវឱ្យមានការអនុញ្ញាតឱ្យធ្វើការងារបន្ថែមម៉ោង ពី ក្រសួងទទួលបន្ទុកខងស័យ ____ ១៦

៦.៧.៤ ការងារបន្ថែមម៉ោងអតបរមា ២ម៉ោងក្នុង១ថ្ងៃ ____ ១៦

៦.៧.៥ ការបើកប្រាក់សំរាប់ការងារបន្ថែមម៉ោង ____ ១៧

៦.៧.៦ អត្រាប្រាក់ឈ្នួលការងារបន្ថែមសំរាប់កម្មករនិយោជិតស៊ីុបុង ____ ១៨

៦.៧.៧ ប្រាក់ឧបត្ថម្ភថ្លៃអាហារសំរាប់ការងារបន្ថែមម៉ោង ____ ១៩

***ផ្នែកទី៧ ការឈប់សំរាកថ្ងៃបុណ្យសាធារណៈ ថ្ងៃឈប់សំរាកនិងអត្ថប្រយោជន៍ដទៃ*** ២០

៧.១ ការឈប់ថ្ងៃសំរាកថ្ងៃបុណ្យសាធារណៈដោយមានប្រាក់ឈ្នួល ____ ២០

៧.២ ការឈប់សំរាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល ____ ២០

៧.២.១ ថ្ងៃឈប់សំរាកបន្ថែមចំពោះការងាររយៈពេលយូរ ____ ២១

៧.២.២ សិទ្ធនៃការប្រើការឈប់សំរាក ____ ២១

៧.២.៣ ការបើកប្រាក់ឈ្នួលជាមុន ____ ២១

៧.២.៤ ការផ្តល់ប្រាក់ឈ្នួលជំនួសឱ្យការឈប់សំរាក ____ ២២

៧.២.៥ កច្ចព្រមព្រៀងបោះបង់ចោលការឈប់សំរាក ____ ២២

៧.២.៦ ការពន្យាពេលការឈប់សំរាក ____ ២៣

៧.៣ ការឈប់សំរាកពិសេស ____ ២៣

៧.៤ ការឈប់សំរាកឈឺ ____ ២៣

៧.៤.១ ការឈប់សំរាកឈឺដោយមានលិខិត បញ្ជាក់ពី គ្រូពេទ្យ ____ ២៤

៧.៤.២ ការផ្តល់ប្រាក់ឈ្នួលក្នុងអំឡុងពេលឈប់សំរាកឈឺ ____ ២៤

| | | |
|---|---|---|
| ៧.៥ | ការឈប់សំរាកលំហែមាតុភាព | ២៤ |
| ៧.៦ | ការសំរាកបំបៅកូន | ២៥ |
| ៧.៧ | បន្ទប់បំបៅកូន | ២៦ |
| ៧.៨ | ទារកដ្ឋាន | ២៦ |
| *ផ្នែកទី៨* | *សុវត្ថិភាពការងារ និង សុខភាព* | ២៧ |
| ៨.១ | លក្ខណៈទូទៅ | ២៧ |
| ៨.២ | គិលានដ្ឋាន និង ការសង្គ្រោះបឋម | ២៧ |
| ៨.២.១ | ទីកន្លែង និង ទំហំគលានដ្ឋាន | ២៧ |
| ៨.២.២ | ចំនួន និង គុណសម្បត្តរបស់កម្មករនិយោជិតសុខាភបាល | ២៧ |
| ៨.២.៣ | ពេទ្យការងារ | ២៨ |
| ៨.២.៤ | ឧបករណ៍ពេទ្យ និង ឱសថ | ២៨ |
| ៨.២.៥ | ចំនួនគ្រែអ្នកអង្គុយ | ២៩ |
| ៨.៣ | បង្គន់អនាម័យ | ២៩ |
| ៨.៣.១ | ចំនួនបង្គន់អនាម័យ | ២៩ |
| ៨.៣.២ | ល័ក្ខខ័ណ្ឌតម្រូវសំរាប់បង្គន់អនាម័យ | ៣០ |
| ៨.៣.៣ | បង្គន់អនាម័យសំរាប់កម្មករនិយោជិតស្ត្រី | ៣០ |
| ៨.៤ | ទឹកផឹក | ៣០ |
| ៨.៤.១ | ល័ក្ខខ័ណ្ឌតម្រូវសំរាប់ទឹកផឹកស្អាតដែលមានសុវត្ថភាព | ៣០ |
| ៨.៤.២ | ទីតាំងនៃធុងទឹក | ៣០ |
| ៨.៤.៣ | គ្រឿងស្រវឹង | ៣០ |
| ៨.៥ | កន្លែងអង្គុយ | ៣១ |
| ៨.៥.១ | ចំនួនកៅអីនៅក្បែរកន្លែងធ្វើការ | ៣១ |
| ៨.៥.២ | បទបញ្ជាផ្ទៃក្នុង | ៣១ |
| ៨.៦ | សំលេង | ៣១ |
| ៨.៧ | ខ្យល់អាកាស  កំដៅ និង ការធ្វើឱ្យមានខ្យល់ចេញចូល | ៣២ |
| ៨.៧.១ | ខ្យល់អាកាស | ៣២ |
| ៨.៧.២ | កំដៅ និង ការធ្វើឱ្យមានខ្យល់ចេញចូល | ៣២ |
| ៨.៧.៣ | ការធ្វើការក្នុងតំបន់ដែលខ្យល់ចេញចូលមានកំរិត | ៣២ |
| ៨.៨ | ពន្លឺ | ៣២ |
| ៨.៩ | ការលើកដាក់ទម្ងន់ដោយកំលាំងពលកម្ម | ៣២ |
| ៨.៩.១ | ស្ត្រីមានផ្ទៃពោះ | ៣៣ |
| ៨.៩.២ | ទំងន់អតបរមា | ៣៣ |
| ៨.១០ | ឧទាហរណ៍អំពីវិធានការជាក់លាក់ពាក់ព័ន្ធទៅនឹងសុខភាព និង សុវត្ថិភាព | ៣៣ |
| *ផ្នែកទី៩* | *គ្រោះថ្នាក់ការងារ និង  ជំងឺវិជ្ជាជីវៈ* | ៣៦ |
| ៩.១ | តើអ្វីជាគ្រោះថ្នាក់ការងារ ? | ៣៦ |
| ៩.២ | ការទទួលខុសត្រូវរបស់និយោជកក្នុងការទប់ស្កាត់មិនឱ្យមានគ្រោះថ្នាក់ការងារ | ៣៦ |
| ៩.៣ | ភារកិច្ចរបស់និយោជកបន្ទាប់ពីគ្រោះថ្នាក់កា | |

រងារកើតឡើង ៣៦
៩.៤ ការជូនដំណឹងអំពីគ្រោះថ្នាក់ការងារ ៣៦
៩.៥ ការប៉ះប៉ូវសងចំពោះគ្រោះថ្នាក់ការងារ ៣៧
៩.៥.១ ការចំណាយលើការព្យាបាល ៣៧
៩.៥.២ ការបាត់បង់សម ត្ថភាពការងារមួយរយៈ ៣៧
៩.៥.៣ ការបាត់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ៣៨
៩.៥.៤ គ្រោះថ្នាក់ការងារបណ្តាលឱ្យស្លាប់ ៣៩
៩.៥.៥ ចំនួនប្រាក់បំណាច់កប្រចាំសំរាប់ការស្លាប់ និងបាត់បង់សមត្ថភាពអចិន្ត្រៃយ៍ ៣៩

***ផ្នែកទី១០ ការតាមដានវិន័យ និង ការបញ្ឈប់ការងារកម្មករនិយោជិត ៤១***
១០.១ វិធានការដាក់វិន័យ និង កំហុស ៤១
១០.១.១ លក្ខខ័ណ្ឌតំរូវក្នុងការបង្ហាញពីកំហុស ៤១
១០.១.២ ពេលវេលាកំណត់សំរាប់ដាក់ទោសវន័យដោយការបញ្ឈប់ការងារ ៤១
១០.១.៣ ពេលវេលាកំណត់សំរាប់វធានការដាក់វន័យ ៤១
១០.១.៤ ការដាក់វន័យត្រូវតែសមហេតុផល ៤១
១០.១.៥ ឧទាហរណ៍អំពីកំហុសធ្ងន់ ៤២
១០.១.៦ ការទាមទារឱ្យបញ្ឈប់ការងារកម្មករនិយោជិត ឬ អ្នកចាត់ចែង ៤២
១០.២ ការព្យួរកិច្ចសន្យាការងារ ៤២
១០.២.១ មូលហេតុនៃការព្យួរកច្ចសន្យាការងារ ៤៣
១០.២.២ ការព្យួរការងារដើម្បីជាការដាក់វ ន័យ
៤៣
១០.២.៣ ការព្យួរការងារដោយសារបញ្ហាសេដ្ឋកច្ច ៤៣
១០.៣ ការបញ្ចប់កិច្ចសន្យាការងារមានថិរវេលាកំណត់ ៤៤
១០.៣.១ ការរំលាយកច្ចសន្យាការងារតាមការព្រមព្រៀង ៤៤
១០.៣.២ ការរំលាយកច្ចសន្យាការងារដោយសារកំហុសធ្ងន់ ៤៥
១០.៣.៣ ការរំលាយកច្ចសន្យាការងារដោយសារករណីប្រធានស័ក្ក ៤៥
១០.៣.៤ ការរំលាយកច្ចសន្យាការងារមានថិរវេលាកំណត់ដោយគ្មានមូលហេតុស្រប់ច្បាប់ ៤៥
១០.៣.៥ ប្រាក់បំណាច់បញ្ចប់កច្ចសន្យានៅពេលបញ្ចប់កច្ចសន្យាការងារមានថិរវេលាកំណត់ ៤៥
១០.៣.៦ ការជូនដំណឹងមុនពេលកាលបរិច្ឆេទនៃកច្ចសន្យាការងារមានថិរវេលាកំណត់ ៤៦
១០.៤ ការបញ្ចប់កិច្ចសន្យាការងារមានថិរវេលាមិនកំណត់ ៤៦
១០.៤.១ ការជូនដំណឹងអំពីការបញ្ចប់កច្ចសន្យាការងារ ៤៧
១០.៤.២ ប្រាក់បំណាច់ចេញពេលបញ្ចប់កច្ចសន្យាការងារមានថិរវេលាមិនកំណត់ ៤៩
១០.៤.៣ សំណងជំងឺចិត្តចំពោះការបញ្ចប់កច្ចសន្យាការងារដោយគ្មានមូលហេតុត្រឹមត្រូវ ៥០
១០.៥ វធានការពិសេសសំរាប់ការបញ្ចប់ពីការងាររួមគ្នា ៥០
១០.៥.១ នីតវធីសំរាប់ការបញ្ចប់ការងាររួមគ្នា ៥១
១០.៦ វធានពិសេសសំរាប់ការបញ្ចប់ការងារសកម្មជនសហជីព និង ប្រតភូបុគគលិក ៥១
១០.៦.១ ការការពារប្រតភូបុគ្គលិក និង សកម្មជនសហជីព ៥១

១០.៦.២ ប្រភេទផ្សេងៗនៃកម្មករនិយោជិកដែលទទួលបានការការពារ ______ ៥២

១០.៧ ការមិនរើសអើង ______ ៥៣

១០.៧.១ ការមិនរើសអើងក្នុងការងារ ______ ៥៣

១០.៧.២ ការរើសអើងដែលអាចអនុញ្ញាតបាន ______ ៥៤

១០.៧.៣ ប្រាក់ឈ្នួលត្រូវស្មើគ្នា ចំពោះការងារដូចគ្នា ______ ៥៤

***ផ្នែកទី១១*** ***ការដោះស្រាយវិវាទ*** ______ ៥៥

១១.១ វិវាទបុគ្គល និង វិវាទការងាររួម ______ ៥៦

១១.១.១ វវាទបុគ្គល ______ ៥៦

១១.១.២ វវាទការងាររួម ______ ៥៦

១១.២ និតិវិធីបណ្តឹងតវ៉ាមិនសុខចិត្ត / បុគ្គលិកតំណាងតំណែង ______ ៥៦

១១.២.១ ការតែងតាំងបុគ្គលិកតំណាងតំណែង ______ ៥៦

១១.២.២ តួនាទីរបស់បុគ្គលិកតំណាងតំណែង ______ ៥៧

១១.៣ ការផ្សះផ្សា ______ ៥៧

១១.៣.១ ការផ្សះផ្សាវិវាទបុគ្គលដោយស្ម័គ្រចិត្ត ______ ៥៧

១១.៣.២ ការផ្សះផ្សាវិវាទការងាររួមជាកាតព្វកិច្ច ______ ៥៧

១១.៣.៣ គ្មានកូដកម្ម ឬ ឡុកអៅក្នុងអំឡុងពេលផ្សះផ្សា ______ ៥៧

១១.៣.៤ កិច្ចព្រមព្រៀងផ្សះផ្សាដែលចងកាតព្វកិច្ច ______ ៥៧

១១.៤ ការដោះស្រាយដោយអាជ្ញាកណ្តាល ______ ៥៨

១១.៤.១ គ្មានកូដកម្ម ឬ ឡុកអៅក្នុងអំឡុងពេលដំណើតការដោះស្រាយដោយអាជ្ញាកណ្តាល ______ ៥៨

១១.៤.២ ការតម្រូវឱ្យសហការជាមួយក្រុមប្រឹក្សាអាជ្ញាកណ្តាល ______ ៥៨

១១.៤.៣ សេចក្តីបង្គាប់អាជ្ញាកណ្តាល ______ ៥៨

១១.៥ កូដកម្ម និង ឡុកអៅ ______ ៥៩

១១.៥.១ តើពេលណាដែលកម្មករនិយោជិតអាចធ្វើកូដកម្មបាន? ______ ៥៩

១១.៥.២ តើពេលណាដែលកម្មករនិយោជិតមិនអាចធ្វើកូដកម្មបាន? ______ ៥៩

១១.៥.៣ នីតិវិធីច្បាប់ក្នុងការធ្វើកូដកម្ម ______ ៥៩

១១.៥.៤ កូដកម្មខុសច្បាប់ ______ ៦០

១១.៥.៥ អហិង្សា ______ ៦០

១១.៥.៦ សេរីភាពរបស់អ្នកមិនមែនជាកូដករ ______ ៦០

១១.៥.៧ គ្មានការដាក់ទណ្ឌកម្មលើកូដករ ______ ៦០

១១.៥.៨ ការបើកប្រាក់ឈ្នួលក្នុងអំឡុងពេលធ្វើកូដកម្ម ______ ៦១

១១.៥.៩ គ្មានការជ្រើសរើសកម្មករនិយោជិតឱ្យចូលធ្វើការក្នុងអំឡុងពេលធ្វើកូដកម្ម ______ ៦១

១១.៥.១០ ឡុកអៅ ______ ៦១

***ផ្នែកទី១២*** ***សហជីព និង ប្រតិភូបុគ្គលិក*** ______ ៦២

១២.១ សេរីភាពក្នុងការបង្កើត និង ចូលរួមក្នុងសហជីព ______ ៦២

១២.២ ការរើសអើងដោយឈរលើមូលដ្ឋាន សមាជិកភាពសហជីព ______ ៦២

១២.៣ ការរួមបញ្ចូលនិយោជក និង កម្មករនិយោជិតទៅក្នុងសហជីព ឬ

សមាគមនតែមួយជាមួយ គ្នាត្រូវបានហាមឃាត់ ៦២
១២.៤ គ្មានការរៀតរៃ្រកក្នុងប្រតិបត្តិការរបស់សហជីព ៦២
១២.៥ ការកាត់ប្រាក់ឈ្នួលក្នុងការបង់ប្រាក់ភាគទានសហជីព ៦២
១២.៦ ការការពារសកម្មជនសហជីពពីការបញ្ឈប់ពីការងារ ៦២
១២.៧ ប្រតិភូបុគ្គលិក ៦៣
១២.៧.១ និយោជកទទួលខុសត្រូវចំពោះការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក ៦៣
១២.៧.២ កាតព្វកិច្ចរបស់និយោជកចំពោះប្រតិភូបុគ្គលិក ៦៣
១២.៧.៣ ប្រតិភូបុគ្គលិកដែលត្រូវបានការពារប្រឆាំងនឹងការបញ្ឈប់ពីការងារ ៦៤
១២.៧.៤ ភារកិច្ចរបស់ប្រតិភូបុគ្គលិក ៦៤
១២.៧.៥ ចំនួនប្រតិភូបុគ្គលិកនៅក្នុងគ្រឹះស្ថានមួយ ៦៥
១២.៨ អនុសញ្ញារួម ៦៥
១២.៨.១ អ្នកណាខ្លះអាចរៀបចំធ្វើអនុសញ្ញារួម? ៦៦
១២.៨.២ ថិរវេលានៃអនុសញ្ញារួម ៦៦
១២.៨.៣ កាតព្វកិច្ចក្នុងការចរចារួម ៦៦
១២.៨.៤ ការចុះបញ្ជីការអនុសញ្ញារួម ៦៦
១២.៨.៥ ការដោះស្រាយវិវាទ ៦៦

*ផ្នែកទី១៣ ការចងក្រងឯកសារ ការរក្សាទុកកំណត់ហេតុ ការបិទផ្សាយ* ៦៧
១៣.១ ប្រកាសបើក និង បិទសហគ្រាស ៦៧
១៣.២ សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន ៦៧
១៣.៣ សៀវភៅបើកប្រាក់ឈ្នួល ៦៧
១៣.៤ សេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិក ៦៨
១៣.៥ ប័ណ្ណការងារ និង សៀវភៅការងារសំរាប់កម្មករនិយោជិតកម្ពុជា និង បរទេស ៦៨
១៣.៦ ការបិទផ្សាយ ៦៨

## ១.១ អំពីសៀវភៅណែនាំនេះ

សៀវភៅណែនាំនេះបាននាំយកនូវប្រភពព័ត៌មានទាំងអស់នៃច្បាប់ស្តីពីការងារនៃប្រទេសកម្ពុជាមកដាក់រួមបញ្ចូលគ្នាតែមួយជាការណែនាំដ៏ទូលំទូលាយមួយសំរាប់ផ្នែកវាយនភ័ណ្ឌ។ សៀវភៅណែនាំនេះកត់ត្រាទុកគ្រប់ផ្នែកសំខាន់ៗទាំងអស់នៃច្បាប់ស្តីពីការងារនៃប្រទេសកម្ពុជាដែលមាន នៅក្នុងច្បាប់ស្តីពី ការងារបទបញ្ញត្តិផ្សេងៗរបស់រាជរដ្ឋាភិបាល បទដ្ឋានពលកម្មអន្តរជាតិដែលបានផ្តល់សច្ចាប័នដោយប្រទេស និង រដ្ឋធម្មនុញ្ញ នៃប្រទេសកម្ពុជា ។

អ្នកប្រើប្រាស់គ្រប់កំរិតនឹងផលប្រយោជន៍នៃសៀវភៅណែនាំនេះ។ ពាណិជ្ជករ អ្នកចាត់ចែង និង បុគ្គលិកផ្នែកធនធានមនុស្សអាចប្រើសៀវភៅណែនាំនេះ ជាឯកសារយោងយ៉ាងរហ័ស ក្នុងការកំណត់អំពីកាតព្វកិច្ចរបស់ពួកគេនៅក្នុងច្បាប់ស្តីពីការងារនៃប្រទេសកម្ពុជាបាន ។

កម្មករនិយោជិត នឹងអាចទទួលបានការយល់ដឹងដ៏ទូលំទូលាយអំពីសិទ្ធនិងកាតព្វកិច្ចរបស់ពួកគេដែលមានកំណត់នៅក្នុងច្បាប់នេះ ។

អង្គការមិនមែនរដ្ឋាភិបាល អង្គការនៅតាមសហគមន៍ សហជីព និង សមាគមនិយោជកក៏នឹងស្វែងយល់អំពីផលប្រយោជន៍របស់សៀវភៅណែនាំនេះនៅក្នុងការងាររបស់ពួកគេផងដែរ ។

សៀវភៅណែនាំត្រូវបានរៀបចំចងក្រងឡើងជា ១២ផ្នែកសំខាន់ៗ:

- បទបញ្ញត្តិស្តីពីការងារ
- ការជ្រើសរើសកម្មករនិយោជិតឱ្យចូលធ្វើការ
- ប្រភេទផ្សេងៗនៃកម្មករនិយោជិត
- ប្រាក់ឈ្នួល
- ថិរវេលាធ្វើការ និងការងារបន្ថែមម៉ោង
- ការឈប់សំរាកថ្ងៃបុណ្យសាធារណៈ ថ្ងៃឈប់សំរាក និង អត្ថប្រយោជន៍ដទៃទៀត
- សុវត្ថិភាពការងារ និង សុខភាព
- គ្រោះថ្នាក់ការងារ និង ជំងឺវិជ្ជាជីវៈ
- ការដាក់វិន័យ និង ការបណ្តេញកម្មករនិយោជិតចេញពីការងារ
- ការដោះស្រាយវិវាទ
- សហជីព និង ប្រតិភូបុគ្គលិក
- ការចងក្រងឯកសារ ការរក្សាទុកកំណត់ហេតុ និង ការបិទផ្សាយ

ឯកសារយោង

ចំពោះបញ្ហានីមួយៗមានកត់ត្រានៅក្នុងផ្នែកទាំងអស់ សៀវភៅណែនាំនេះ រួមបញ្ចូលនូវឯកសារយោងអំពី ប្រភពព័ត៌មានផ្សេងៗនៅក្នុងច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា ។

**ឧទាហរណ៍ អំពីរបៀបប្រើប្រាស់ការណែនាំនេះ**

ពត៌មានស្តីពីអនុសញ្ញារួម អ្នកអានរកឃើញនៅក្នុងចំនងជើង:

## ១២.៨ អនុសញ្ញារួម

អ្នកប្រើប្រាស់ដែលការព័ត៌មានលំអិតជាងនៅក្នុងផ្នែកនេះ អាចទៅមើលផ្នែកនេះនៅក្នុងច្បាប់ស្តីពីការងារ និងប្រកាស ដែលបានចង្អុលបង្ហាញដោយការយោងឯកសារទាំងអស់នោះ។

ច្បាប់ស្តីពីការងារមាត្រា ១ និង ៦៥
សេចក្តីបង្គាប់អាជ្ញាកណ្តាល
១៧០ / ១១(៤) និង ១០១ / ១២(២)

សៀវភៅណែនាំនេះមានមាតិកាលំអិតដែលធ្វើអោយងាយស្រួលរកទីតាំងនៃប្រធានបទដែលចាប់អារម្មណ៍។

សៀវភៅណែនាំនេះមានបំណងដឹកនាំផ្លូវទៅរកច្បាប់ការងារនៃប្រទេសកម្ពុជាតែប៉ុណ្ណោះ។ អ្នកប្រើមិនគួរចាត់ចទុកសៀវភៅណែនាំនេះថាជាទីប្រឹក្សាផ្នែកច្បាប់ទេ។ ជាពិសេសសៀវភៅណែនាំនេះសរសេរឡើង សំរាប់ឧស្សាហកម្មផ្នែកកាត់ដេរសំលៀកបំពាក់។ ទោះបីជាវាអាចអនុវត្តបាននៅក្នុងឧស្សាហកម្មដទៃក៏ដោយ ក៏វាអាចមាន ច្បាប់និងបទបញ្ញត្តិដទៃទៀតដែលជាក់លាក់សំរាប់ផ្នែកឧស្សាហកម្មដែលអាចអនុវត្តបានដែរ (ដូចជានៅក្នុងផ្នែកកសិកម្មចំការ និង សេវាកម្មឧស្សាហកម្ម) ។

ក្នុងការដោះស្រាយបញ្ហាទាំងឡាយដែលទាក់ទងនឹងល័ក្ខខ័ណ្ឌការងារ ឬ ទំនាក់ទំនងកន្លែងធ្វើការ វាអាចចាំបាច់ត្រូវពិគ្រោះយោបល់ជាមួយអ្នកជំនាញដូចជា អធិការការងារ មេធាវី ឬ អ្នកតំណាងសមាគមនិយោជក ឬ សហព័ន្ធសហជីព ។

## ១.២ ពាក្យបច្ចេកទេស

ពាក្យ "បទបញ្ញត្តិ" ដូចមានប្រើនៅក្នុងសៀវភៅណែនាំនេះ រួមបញ្ចូលនូវលិខិតបទដ្ឋានប្រតិបត្តិទាំងអស់ ដូចជា អនុក្រឹត ប្រកាស សារាចរ សេចក្តីណែនាំ និង សេចក្តីដំណើរ។

# ផ្នែកទី២ បទបញ្ញត្តិការងារ

ឯកសារយោង

## ២.១ ទិដ្ឋភាពទូទៅ

សៀវភៅណែនាំនេះគឺនិយាយអំពីច្បាប់ស្តីពីការងារនៃប្រទេសកម្ពុជា។ ច្បាប់ការងារនៃប្រទេសកម្ពុជា កើតចេញមកពីប្រភពមួយចំនួន។ ប្រភពទាំងនេះរួមមានៈ

- រដ្ឋធម្មនុញ្ញ
- ច្បាប់ស្តីពីការងារ
- បទបញ្ញត្តិទាំងឡាយរបស់រាជរដ្ឋាភិបាល ( អនុក្រិត ) និង របស់ក្រសួងទទួលបន្ទុកវិស័យការងារ (ប្រកាស សារាចរ និង សេចក្តីជូនដំណឹង)
- បទដ្ឋានពលកម្មអន្តរជាតិនៃអង្គការពលកម្មអន្តរជាតិ
- អនុសញ្ញារួម
- កិច្ចសន្យាការងារ និង
- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ។

សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល អាចអនុវត្តតែចំពោះភាគីទាំងឡាយដែលមានឈ្មោះនៅក្នុងសេចក្តីបង្គាប់នោះតែប៉ុណ្ណោះ។ ប៉ុន្តែសេចក្តីបង្គាប់នេះត្រូវបានយោងនៅក្នុងសៀវភៅណែនាំនេះ ពីព្រោះសេចក្តីបង្គាប់ទាំងនេះអាចជួយអោយយល់ដឹងពីអត្ថន័យនៃច្បាប់ស្តីពីការងារ ។ ច្បាប់ស្តីពីការងារ និង សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចរកបាននៅលើគេហទំព័រ(វិបសាយថ៍) www.arbitrationcouncil.org/ ។

រដ្ឋាភិបាលនៃប្រទេសកម្ពុជាក៏បានចុះហត្ថលេខាលើអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិដែរ ។ ដោយហេតុនេះហើយ រដ្ឋាភិបាលត្រូវតែចាត់វិធានការដើម្បីអនុវត្តអនុសញ្ញាទាំងអស់ ។

## ២.២ កិច្ចសន្យាការងារ

ច្បាប់ស្តីពីការងារមាត្រា ១ និង ៦៥
សេចក្តីបង្គាប់អាជ្ញាកណ្តាល
១៧០/១១(៤) និង ១០១/១២(២)

កិច្ចសន្យាការងារ គឺជាកិច្ចព្រមព្រៀងមួយដែលបុគ្គលម្នាក់ (កម្មករនិយោជិត) យល់ព្រមធ្វើការដើម្បីទទួលប្រាក់ឈ្នួលពីបុគ្គលម្នាក់ទៀតឬ ក្រុមហ៊ុន (និយោជក) ។ កិច្ចសន្យាការងារអាចសរសេរលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ។

ច្បាប់ស្តីពីការងារអនុវត្តចំពោះបុគ្គលភាគច្រើនដែលមានកិច្ចសន្យាការងារ ដើម្បីការងារនៅក្នុងប្រទេសកម្ពុជា។ ជាទូទៅ ច្បាប់ស្តីពីការងារមិនអនុវត្តទៅលើអ្នកបំរើក្នុងផ្ទះទេ (វៀរលែងតែមានចង្អុលច្បាស់នៅក្នុងច្បាប់) និងអ្នកបំរើការជាអចិន្ត្រៃយ៍ឲ្យរដ្ឋ ( ដូចជា មន្ត្រីរាជការ ចៅក្រម មន្ត្រី នគរបាល យោធា និង កងរាជ អាវុធហត្ថ) ។

## ២.៣ អនុសញ្ញារួម

អនុសញ្ញារួមគឺជាកិច្ចព្រមព្រៀងមួយរវាងកម្មករនិយោជិតមួយក្រុម និង និយោជកម្នាក់ ឬ ច្រើននាក់ស្តីពីប្រាក់ឈ្នួលនិងល័ក្ខខ័ណ្ឌការងារទាំងឡាយ។ សំរាប់ព័ត៌មានបន្ថែមស្តីពីអនុសញ្ញារួម សូម ផ្នែក **១២.៨** ខាងក្រោម ។

ច្បាប់ស្តីពីការងារ មាត្រា ៩៦-១០១
ប្រកាស ២៨៧/០១ និង ៣០៥/០១

## ២.៤ បទបញ្ជាផ្ទៃក្នុង

និយោ ជកដែលមានកម្មករនិយោជិតយ៉ាងតិច ៨នាក់ ត្រូវរៀបចំអោយមានបទបញ្ជាផ្ទៃក្នុង។ "បទបញ្ជាផ្ទៃក្នុង" គឺជាវិធានទាំងឡាយដែលរៀបចំដោយនិយោជកដើម្បីអនុវត្តច្បាប់ស្តី ពីការងារណាមួយ។ បទបញ្ជាផ្ទៃក្នុង មិនត្រូវផ្ទុយនឹងច្បាស់ស្តីពីការងារ បទបញ្ញត្តិទាំងឡាយ ឬ អនុសញ្ញារួម ដែលកំពុងមានប្រសិទ្ធភាពអនុវត្តទេ ។

ច្បាប់ស្តីពីការងារ មាត្រា ២២ -២៥
២៩ ៣០ និង ២៨៤
ប្រកាស ៣១៣/០០
សេចក្តីជូនដំណឹង១៤/០២

### ២.៤.១ មាតិកានៃបទបញ្ជាផ្ទៃក្នុង

ដោយយោងតាម *គំរូបទបញ្ជាផ្ទៃក្នុង* ដែលក្រសួងទទួលបន្ទុកវិស័យការងារបានចេញបទបញ្ជាផ្ទៃក្នុងនានាគួររួមបញ្ចូលនូវ បទបញ្ញត្តិផ្សេងៗដែលទាក់ទងនិង:

ច្បាប់ស្តីពីការងារ
មាត្រា២៣សេចក្តីជូនដំណឹង

- ល័ក្ខខ័ណ្ឌទទួលយកកម្មករនិយោជិតអោយចូលរួមធ្វើការ ការហ្វឹកហាត់កូនជាង និង ការសាកល្បងការងារ
- ការរៀបចំអំពីការងារ
- ការពិនិត្យសុខភាព
- ម៉ោងធ្វើការ ការឈប់សំរាកប្រចាំសប្តាហ៍ និង ការសុំច្បាប់ឈប់សំរាក (រួមមានការឈប់សំរាកពេលឈឺជាដើម)
- ប្រាក់ឈ្នួល ប្រាក់រង្វាន់ និង ផលប្រយោជន៍ផ្សេងៗទៀត
- អវត្តមានរបស់កម្មករនិយោជិត
- ការប្រើប្រាស់សំភារ: និង ហត្ថបករណ៍របស់សហគ្រាសក្នុងការបំពេញការងារ
- ការប្រើប្រាស់អគារ ឬ មូលដ្ឋានរបស់សហគ្រាស
- ការចេញចូលសហគ្រាស
- ទោសវិន័យនានា បើសិនជាកម្មករនិយោជិតរំលោភបញ្ជាផ្ទៃក្នុង ឬមានកំហុសធ្ងន់
- សិទ្ធការពារខ្លួនរបស់កម្មករនិយោជិតមុនពេលត្រូវបានទទួលទោសវិន័យ
- អនាម័យ និងសន្តិសុខការងារ ។

## ២.៤.២ ការរៀបចំ និង ការកែប្រែបទបញ្ជាផ្ទៃក្នុង

និយោជកត្រូវតែពិគ្រោះយោបល់ជាមួយប្រតិភូបុគ្គលិក និងតំណាងសហជីព មុននឹងរៀបចំធ្វើបទបញ្ជាផ្ទៃក្នុង។ និយោជកត្រូវតែរៀបចំធ្វើនូវបទបញ្ជាផ្ទៃក្នុង ក្នុងរយៈពេល ៣ខែ បន្ទាប់ពីសហគ្រាស។ បទបញ្ជាផ្ទៃក្នុង ទាំងឡាយត្រូវមានចុះទិដ្ឋាការដោយអធិការការងារ ។

ច្បាប់ស្តីពីការងារ មាត្រា ២៤ និង ២៨៤
ប្រកាស ៣១៣/០០

## ២.៤.៣ បទបញ្ជាផ្ទៃក្នុងត្រូវតែបិទផ្សាយ

និយោជកត្រូវបិទផ្សាយបទបញ្ជាផ្ទៃក្នុងនៅកន្លែងសាធារណៈ ក្នុងកន្លែងការងារ និង នៅតាមមាត់ទ្វារបន្ទប់ដែលទទួលយកកម្មករនិយោជិតអោយធ្វើការ ។

ច្បាប់ស្តីពីការងារ មាត្រា ២៩

## ២.៥ ច្បាប់ស្តីពីការងារជាសេចក្តីបង្គាប់សាធារណៈ

ច្បាប់ស្តីពីការងារត្រូវបានតាក់តែងឡើងដើម្បីការពារកម្មករនិយោជិត ហើយកម្មករនិយោជិតទាំងអស់មានសិទ្ធទទួលអត្ថប្រយោជន៍យ៉ាងហោចណាស់ស្មើនឹងកំរិតអប្បបរមា និង បទបញ្ញត្តិទាំងឡាយសំរាប់អនុវត្តច្បាប់នេះ។ ដោយសារហេតុផលនេះ បញ្ញត្តិណាមួយនៃកិច្ចសន្យាការងារ អនុសញ្ញារួម ឬបទបញ្ជាផ្ទៃក្នុងទាំងឡាយណា ដែលផ្តល់អត្ថប្រយោជន៍ដល់កម្មករនិយោជិតតិចជាងច្បាប់ មិនអាចយកមកអនុវត្តបានទេ ។

ច្បាប់ស្តីពីការងារមាត្រា ១៣ និង ២៥
សេចក្តីបង្គាប់អាជ្ញាកណ្តាល ១៧០/១១(១) និង ៩៥/១១(៤)

ម្យ៉ាងវិញទៀត កម្មករនិយោជិតអាចតវ៉ាជាមួយនិយោជករបស់ពួកគេ ដើម្បីទទួលបានអត្ថប្រយោជន៍ទាំងឡាយដែលល្អប្រសើរជាងនៅក្នុងច្បាប់នេះ ។

# ផ្នែកទី៣ ការជ្រើសរើសកម្មករនិយោជិតអោយចូលធ្វើការ

ឯកសារយោង

## ៣.១ អាទិភាពចំពោះប្រជាពលខ្មែរ

ច្បាប់ស្តីពីការងារ មាត្រា២៦៣

និយោជកត្រូវផ្តល់អាទិភាពចំពោះប្រជាពលរដ្ឋខ្មែរនៅពេល មានការជួលអោយធ្វើការ ។

## ៣.២ ការជួលជនបរទេសអោយធ្វើការ

ច្បាប់ស្តីពីការងារ មាត្រា ២៦១-២៦៥

ប្រកាស ១៦១/០១

ជនបរទេសធ្វើការនៅប្រទេសកម្ពុជាត្រូវមាន:

- ប័ណ្ណការងារ
- សៀវភៅការងារ
- លិខិតឆ្លងដែនមានសុពលភាព និង ប័ណ្ណស្នាក់នៅត្រឹមត្រូវ
- គ្មានកើតជំងឺឆ្លងណាមួយ
- មានកាយសម្បទាសមរម្យនឹងមុខរបរ ។

## ៣.៣ ការបង់ប្រាក់ដោយបេក្ខជនដាក់ពាក្យសុំធ្វើការខារត្រូវបានហាមឃាត់

ច្បាប់ស្តីពីការងា មាត្រា ៤៥ ១២៦ និង ២៦០

និយោជកមិនអាចទទួលយក ឬ ទាមទារប្រាក់ពីបេក្ខជនដាក់ពាក្យសុំការងារ ក្នុងអំឡុងពេលនៃដំណើរការជួលបុគ្គលិកអោយធ្វើការបានទេ។ និយោជកមិនអាចកាត់ភាគណាមួយពីប្រាក់ឈ្នួលដោយសារការផ្តល់ការងារដើម្បីអោយទៅនិយោជក អ្នកតំណាងរបស់និយោជក ឬ អន្តរការី (អ្នកជ្រើសរើសបុគ្គលិក) បានទេ ។

## ៣.៤ ការងារដោយបង្ខំ

ច្បាប់ស្តីពីការងារ មាត្រា១៥ និង ១៦

ការងារដោយបង្ខំ គឺផ្ទុយនឹងច្បាប់ គឺដូចជាការជួលជនណាម្នាក់អោយធ្វើការដើម្បីកាត់បំណុលដែរ ។

## ៣.៥ កម្មករនិយោជិតក្មេង និង ពលកម្មកុមារ

ភាពក្រីក្រ គឺបញ្ហាធំមួយចំពោះគ្រួសារជាច្រើននៅក្នុង ប្រទេសកម្ពុជា។ បញ្ហានេះដាក់សម្ពាធទៅលើឪពុកម្តាយអោយកូនរបស់ពួកគេធ្វើការ។ ប្រទេសកម្ពុជាមានច្បាប់ដែលបញ្ញត្តិពីពលកម្មកុមារ ។ និយោជិតក្រោមអាយុ ១៥ឆ្នាំដែលអនុញ្ញាតសំរាប់ធ្វើការ អាចបញ្ជូន រឺ ខ្ចីពីគេ នូវឯកសារក្លែងក្លាយ សំរាប់អំ ឡុងពេលជ្រើសរើសបុគ្គលិក ។ បន្ថែមពីនេះ រោងចក្រអាចនឹងមិនអនុវត្តបានគ្រប់គ្រាន់តាមដំណើរការជ្រើសរើសបុគ្គលិក ។ ដើម្បីជៀសវាងការជួលកម្មករនិយោជិតក្រោមអាយុការងារ អ្នកជ្រើសរើសបុគ្គលិកត្រូវផ្តល់អាទិភាពដល់អ្នករកការងារណាដែលរូបរាងពេញវ័យ និង ត្រូវពិនិត្យឲ្យបានល្អិតល្អន់លើឯកសារដើម្បីប្រាកដថាឯកសារទាំងនោះមិនមែនក្លែងក្លាយ រឺ ខ្ចីពីគេ។

## ៣.៥.១ អាយុអប្បបរមារបស់កម្មករនិយោជិត

ច្បាប់ស្តីពីការងារ មាត្រា ១៧៧

អាយុអប្បបរមាដែលអនុញ្ញាតឱ្យធ្វើការបានចំពោះការងារជាប់លាប់គឺអាយុ១៥ឆ្នាំ ។

## ៣.៥.២ ការការពារកម្មករនិយោជិតក្មេង

ច្បាប់ស្តីពីការងារ មាត្រា ១៧២-១៨១

អនីតិជន (ជនដែលមានអាយុតិចជាង ១៨ឆ្នាំ) មិនអាចចុះហត្ថលេខាលើកិច្ចសន្យាការងារ ដោយគ្មានការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាលរបស់ពួកគេបានឡើយ ។

អនីតិជនក៏មិនអាចត្រូវបានជួលអោយធ្វើការងារពេលយប់បានដែរ។ សូមមើលកថាខ័ណ្ឌទី ៦.៥ និង ៦.៦ ខាងក្រោមនេះ អំពីការពន្យល់អំពីការងារពេលយប់ ។

អនីតិជនអាយុពី ១២ ដល់ ១៥ឆ្នាំ អាចត្រូវបានទទួលអោយធ្វើការងារស្រាលៗអោយតែវាជា:

- ការងារដែលមិនបណ្តាលអោយប៉ះពាល់ដល់ការអភិវឌ្ឍន៍សុខភាព ឬស្មារតីរាងកាយ និង
- ការងារដែលមិនប៉ះពាល់ដល់ការសិក្សា ឬកម្មវិធីហ្វឹកហ្វឺន ។

## ៣.៥.៣ ការងារត្រូវតែសមស្របសំរាប់កម្មករនិយោជិតក្មេង

ច្បាប់ស្តីពីការងារ មាត្រា ១៧៨
ប្រកាស ១០៦/០៤

អធិការការងារអាចស្នើអោយអនីតិជនដែលបំរើការងារទទួលការពិនិត្យពីវេជ្ជបណ្ឌិតបានគ្រប់ពេល។

ប្រសិនបើ វេជ្ជបណ្ឌិតសំរេចថាការងារនេះធ្ងន់ធ្ងរចំពោះអនីតិជន និយោជកត្រូវផ្លាស់ប្តូរការងារ ឬ បញ្ឈប់ការងារអតិថិជននេះ។

និយោជកមិនអាចទទួលអនីតិជនអោយធ្វើការដែលមានគ្រោះថ្នាក់ ដូចមានចុះនៅក្នុងប្រកាស ១០៦-០៤ បានទេ។ ប៉ុន្តែ និយោជកអាចស្នើសុំការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យការងារ ទទួលកម្មករនិយោជិតដែលមានអាយុយ៉ាងតិច ១៦ឆ្នាំ អោយធ្វើការដែលមានគ្រោះថ្នាក់បាន លុះត្រាតែកម្មករនិយោជិតនោះ :

- បានទទួលការហ្វឹកហ្វឺនសមស្រប និង
- មិនធ្វើការក្នុងចន្លោះពីម៉ោង ២២:00 ទៅ ៥:00 ។

## ៣.៥.៤ ការចុះបញ្ជីអំពីអាយុ

ច្បាប់ស្តីពីការងារ ១៧៩
សេចក្តីជូនដំណឹង ១១/០៣

និយោជកត្រូវតែរក្សាបញ្ជីស្តីពីអនីតិជនទាំងអស់ដែលធ្វើការអោយខ្លួន។ អធិការការងារត្រូវតែពិនិត្យបញ្ជីនេះ ។ និយោជកគួរតែរក្សាភស្តុតាងបញ្ជាក់ពីអាយុរបស់កម្មករនិយោជិតទាំងអស់។ ភស្តុតាងនេះ គួរតែមានទំរង់ជាអត្តសញ្ញាណប័ណ្ណ សំបុត្រកំណើត លិខិតអាពាហ៍ពិពាហ៍ សៀវភៅគ្រួសារ សៀវភៅការងារ ប្រកាសនីយប័ត្រ ប័ណ្ណបោះឆ្នោត ឬឯកសារទាំងឡាយដែលមានតំលៃស្មើ ។

## ៣.៦ ការពិនិត្យសុខភាព

កម្មករនិយោជិតទាំងអស់ត្រូវបានតំរូវអោយឆ្លងកាត់ការត្រួតពិនិត្យសុខភាពដោយនាយកដ្ឋានពេទ្យការងារ។ និយោជកគឺជាអ្នកដែលត្រូវចេញសាហ៊ុយពិនិត្យសុខភាព

ច្បាប់ស្តីពីការងារ មាត្រា២៤៧
ប្រកាសរួមលេខ ០៩/៩៤
សេចក្តីបង្គាប់អាជ្ញាកណ្តាល
០២/០៣ ២១/០៣ ១៩/០៤ ៥៣/០៤ ៦០/០៤ ៦៣/០៤ ៦៤/០៤ ៧៨/០៤ ២(១៣)

# ផ្នែកទី៤ ប្រភេទផ្សេងៗនៃកម្មករនិយោជិត

ឯកសារយោង

## ៤.១ កិច្ចសន្យាការងារមានថិរវេលាកំណត់ និង មិនកំណត់

ច្បាប់ស្តីពីការងារថែងអំពីប្រភេទនៃកិច្ចសន្យាការងារចំពោះកម្មករនិយោជិតដែលធ្វើការងារជាប់លាប់ ។ កិច្ចសន្យាការងារ មានថិរវេលាមានកំណត់ និងកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ ។

ច្បាប់ស្តីពីការងារ មាត្រា ៦៧ និង ៧៣ សេចក្តីបង្គាប់អាជ្ញាកណ្តាល ១០/០៣ ០២/០៤ ១៥៥/០៩(៩) ៧០/១១(១) និង ១០៥/១១(៣)

កិច្ចសន្យាការងារមួយជាកិច្ចសន្យាការងារមានថិរវេលាកំណត់ កាលណាបើកិច្ចសន្យាការងារ នេះ :

- សរសេរជាលាយលក្ខណ៍អក្សរ
- មានរយៈពេលមិនលើស ២ឆ្នាំ និង
- មានកាលបរិច្ឆេទចាប់ផ្តើម និង បញ្ចប់ច្បាស់លាស់ ។

ប្រសិនបើកិច្ចសន្យាការងារពុំមានល័ក្ខខ័ណ្ឌតំរូវទាំងអស់នេះទេ កិច្ចសន្យាការងារនោះ គឺជាកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីសំរេចមួយកំណត់ថាកិច្ចសន្យាមានថិរវេលាកំណត់អាចត្រូវបានបន្តមួយដង ឬ ច្រើនដង តែក្នុងករណីរយៈពេលសរុបនៃទំនាក់ទំនងការងារមិនលើសពី ២ឆ្នាំ។ ប្រសិនបើការងារស្ថិតក្រោមកិច្ចសន្យាការងារមានថិរវេលាកំណត់បន្តរយៈពេលច្រើនជាង២ឆ្នាំ ពេលនោះកិច្ចសន្យាការងារនេះនឹងក្លាយទៅជាកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ជាស្វ័យប្រវត្តិ ។

## ៤.២ កម្មករនិយោជិតម្តងម្កាល

ច្បាប់ស្តីពីការងារ មាត្រា ៩ និង ១០ សេចក្តីបង្គាប់អាជ្ញាកណ្តាល០៣/០៣ ២៦/០៤ ៣០/០៤ និង ១១៦/១១(២)

ច្បាប់ស្តីពីការងារកំណត់ថាកម្មករនិយោជិតម្តងម្កាលជាជនដែលៈ

- ធ្វើការមួយជាក់លាក់ដែលត្រូវតែបញ្ចប់ក្នុងរយៈពេលខ្លី ឬ
- ធ្វើការមួយពេលៗ ធ្វើឈប់ៗ ឬ ធ្វើមួយរដូវៗ។

កម្មករនិយោជិតម្តងម្កាល ជួនកាលក៏ត្រូវគេហៅថាជាកម្មករនិយោជិត បណ្តែត ឬ កម្មករបណ្តោះអាសន្នដែរ ។

### ៤.២.១ ពេលវេលាកំណត់ចំពោះការងារម្តងម្កាល

ច្បាប់ស្តីពីការងារ មាត្រា ៩ សេចក្តីបង្គាប់អាជ្ញាកណ្តាល ២៦/០៤ ១០/ ០៨(១) និង

វាមិនសមស្របទេក្នុងការប្រើកម្មករនិយោជិតម្តងម្កាល (ឬបណ្តែត) ដោយផ្អែកលើមូលដ្ឋានជាប់លាប់សំរាប់រយៈពេលយូរ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសំរេចថា ប្រសិនបើកម្មករនិយោជិតម្តងម្កាល (ឬបណ្តែត) ធ្វើការច្រើនជាង ២១ថ្ងៃ ក្នុង១ខែ ក្នុងរយៈពេលលើសពី ២ខែជាប់ៗគ្នានៅពេលនោះ ពួកគេគួរតែត្រូវបានចាត់ទុកថាជាកម្មករនិយោជិត សាកល្បង ឬ ជាប់លាប់ ។

## ៤.២.២ សិទ្ធរបស់កម្មករនិយោជិតម្តងម្កាល

ច្បាប់ស្តីពីការងារ មាត្រា ១០ និង ១៦១
សេចក្តីជូនដំណឹង ០៤១/១១
សេចក្តីបង្គាប់អាជ្ញាកណ្តាល ៣០/០៤ និង ៩៧/០៨(១០)

កម្មករនិយោជិតម្តងម្កាលមានសិទ្ធដូចគ្នានឹងកម្មករនិយោជិតជាប់លាប់។ ដូច្នេះកម្មករនិយោជិតម្តងម្កាលត្រូវតែទទួលប្រាក់ឈ្នួល និង ការប្រព្រឹត្តដូចគ្នានឹងកម្មករនិយោជិតជាប់លាប់ដែរ។ ប៉ុន្តែអត្ថប្រយោជន៍របស់កម្មករនិយោជិតម្តងម្កាលអាចត្រូវបាន ប្រសិនឡើងជាសំណងជំងឺចិត្តចំពោះការមិនផ្តល់ឱ្យនេះ។

ប្រសិនបើ និយោជក មិនផ្តល់អោយកម្មករនិយោជិតម្តងម្កាលនូវការឈប់សំរាកប្រចាំឆ្នាំ ការឈប់សំរាកឈឺ សំរាកបុណ្យសាធារណៈ បុព្វលាភ និង អត្ថប្រយោជន៍ដទៃទៀតទេនោះ និយោជកគួរតែផ្តល់អោយពួកគេនូវអាត្រាប្រាក់ឈ្នួលតាមម៉ោង កើនឡើងជាសំណងជំងឺចិត្តចំពោះការមិនផ្តល់ អោយ ។

**ឧទាហរណ៍: កម្មករនិយោជិតម្តងម្កាល**

*គឹមឡេង* ត្រូវបានគេជួលអោយធ្វើការជាកម្មករនិយោជិតបណ្តែត នៅក្នុងរោងចក្រ *X*។ នៅក្នុងខែខ្លះ គាត់ធ្វើការស្ទើរតែពេញម៉ោង ហើយខែខ្លះទៀតគាត់អាចធ្វើការត្រឹមតែ ៤ ឬ ៥ ថ្ងៃអាស្រ័យ ទៅលើការងារនៅក្នុងរោងចក្រ ។

បើសិនជានាងធ្វើការពាក់កណ្តាលម៉ោងនៅ ខែមេសា ឆ្នាំ២០១១ ដូច្នេះដើម្បីអោយស្របនឹងច្បាប់ស្តីពីការងារ និយោជករបស់នាងគួរតែ:

- ផ្តល់ប្រាក់ឈ្នួលអោយនាង ៥០% នៃប្រាក់ឈ្នួលប្រចាំថ្ងៃ នៅថ្ងៃបុណ្យសាធារណៈក្នុង ខែមេសា។
- ផ្តល់អោយនាង ០/៧៥ ថ្ងៃ (ឬ ៦ម៉ោង) ក្នុងមួយខែសំរាប់ពេលឈប់សំរាប់ប្រចាំឆ្នាំ និង
- ផ្តល់អោយនាងប្រាក់រង្វាន់ការងារទៀងទាត់ ៧ដុល្លារអាមេរិកសមាមាត្រទៅតាមចំនួនថ្ងៃដែលនាងធ្វើការ

## ៤.៣ កម្មករនិយោជិតមិនពេញម៉ោង

កម្មករនិយោជិតមិនពេញម៉ោង គឺជាកម្មករនិយោជិតដែលធ្វើការតិចជាង ៤៨ម៉ោងក្នុង១សប្តាហ៍។ កម្មករនិយោជិតមិនពេញម៉ោង មានសិទ្ធិដូចគ្នានឹងកម្មករនិយោជិតធ្វើការពេញម៉ោងដែរ លើកលែងតែប្រាក់ឈ្នួល និង អត្ថប្រយោជន៍របស់ពួកគេដែលអាចត្រូវបានកាត់បន្ថយទៅតាម ចំនួនម៉ោងដែលពួកគេធ្វើការ ។

## ៤.៤ កម្មករនិយោជិតសាកល្បង

នៅពេលចាប់ផ្តើមកិច្ចសន្យាការងារ និយោជកអាចកំណត់រយៈ ពេលសាកល្បងការងាររហូតដល់ទៅ ៣ខែដើម្បីវាយតំលៃអំពី ជំនាញ និង អាកប្បកិរិយារបស់កម្មករនិយោជិត ។

ច្បាប់ស្តីពីការងារ មាត្រា ៦៨ និង ៨២
សេចក្តីជូនដំណឹង ០៦/៩៧ និង ១៧/០០
សេចក្តីបង្គាប់អាជ្ញាកណ្តាល ២៧/០៣ ៥៥/០៤(២) និង ៣៧/១១(១)

### ៤.៤.១ រយៈពេលសាកល្បង

ច្បាប់ស្តីពីការងារ មាត្រា ៦៨
សេចក្តីជូនដំណឹង ០៦/៩៧ និង ១៧/០០
សេចក្តីបង្គាប់អាជ្ញាកណ្តាល ១៣/០៤ ៩២/០៨(៥) និង ១៥/១១(២)

រយៈពេលអតិបរមានៃការសាកល្បងគឺ:

- ១ខែ សំរាប់កម្មករនិយោជិតមិនប្រើឯកទេស
- ២ខែ សំរាប់កម្មករនិយោជិតឯកទេស
- ៣ខែ សំរាប់និយោជិតធម្មតា

សេចក្តីជូនដំណឹង ០៦/៩៧ ចែងថាកម្មករនិយោជិតដែលបន្ទាប់ពីបញ្ចប់ដោយជោគជ័យនូវការហ្វឹកហ្វឺនកូនជាង "ត្រូវតែស្ថិតនៅក្នុងរយៈពេលសាកល្បងរយៈពេល៣ ខែមុននឹងក្លាយទៅជាងអ្នកដេរ " ។ ប៉ុន្តែក្នុងការអនុវត្តច្បាប់ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានសំរេចថា អ្នកដេរ និង អ្នកកាត់សំលៀកបំពាក់ជាកម្មករនិយោជិតឯកទេស ដូច្នេះរយៈពេលសាកល្បងការងារអតិបរមា របស់ពួកគេ គួរតែត្រូវបញ្ចប់ដោយមិនអោយលើសពី ២ខែ ។

## ៤.៥ ការហ្វឹកហ្វឺនកូនជាង

ច្បាប់ស្តីពីការងារ មាត្រា ៥១-៦៤ប្រកាស ០០៤/០០

និយោជិកផ្តល់ការហ្វឹកហ្វឺនវិជ្ជាជីវៈទៅកូនជាង។ កម្មករនិយោជិតដែលគ្មានជំនាញទទួលការហ្វឹកហ្វឺនដំបូង ហើយបន្ទាប់ពីការបញ្ចប់ការហ្វឹកហ្វឺននេះដោយជោគជ័យ ពួកគេនឹងរំពឹងថាក្លាយទៅជាកម្មករនិយោជិតសាកល្បង និង បន្ទាប់មកទៀតក្លាយទៅជាកម្មករនិយោជិតជាប់លាប់ ។

### ៤.៥.១ រយៈពេលនៃការហ្វឹកហ្វឺនកូនជាង

ច្បាប់ស្តីពីការងារ មាត្រា ៥១
ប្រកាស ០០៤/០០
សេចក្តីជូនដំណឹង ០៦/ ៩៧
សេចក្តីបង្គាប់អាជ្ញាកណ្តាល ៦២/០៤

ជាទូទៅការហ្វឹកហ្វឺនកូនជាងមិនអាចលើសពី ២ឆ្នាំទេ ។ ប៉ុន្តែសេចក្តីជូនដំណឹង ០៦/៩៧ ចែងថាក្នុងឧស្សាហកម្មសំលៀកបំពាក់នៅទីក្រុងភ្នំពេញ រយៈនៃការហ្វឹកហ្វឺនកូនជាង មិនគួរលើសពី ២ខែទេ។ ពុំមានការកំរិតរយៈពេលពិសេសសំរាប់កូនក្នុងឧស្សាហកម្មសំលៀកបំពាក់ដែលនៅក្រៅទីក្រុងភ្នំពេញ ។

និយោជកគួរប្រើប្រាស់ការហ្វឹកហាត់កូនជាងតែចំពោះកម្មករនិយោជិតដែលគ្មានបទពិសោធន៍ក្នុងវិស័យឧស្សាហកម្មតែប៉ុណ្ណោះ ។

# ផ្នែកទី ៥ ប្រាក់ឈ្នួល

ច្បាប់ស្តីពីការងារ មាត្រា ១០២-១១៩

ឯកសារយោង

## ៥.១ ប្រាក់ឈ្នួលអប្បបរមា

ច្បាប់ស្តីពីការងារ មាត្រា ១០៤
១០៥និង ១០៨ និង ១០៣/១៣
សេចក្តីជូនដំណឹង ០៤៩/១០
សេចក្តីបង្គាប់អាជ្ញាកណ្តាល០៤/០៣
២៥/០៣ និង ២៦/០៤

និយោជកត្រូវតែបើប្រាក់អោយកម្មករនិយោជិតទាំងអស់ ដែលធ្វើការពេញម៉ោង ( រួមទាំងកម្មករនិយោជិតដេរស៊ីប៉ុង និង កម្មករនិយោជិតម្តងម្កាល ) យ៉ាងតិចបំផុតស្មើនឹងប្រាក់ឈ្នួលអប្បបរមា។

និយោជកត្រូវតែបិទផ្សាយអំពីប្រាក់ឈ្នួលអប្បបរមានៅកន្លែងធ្វើការ និង ក្នុងការិយាល័យបើកប្រាក់ឈ្នួល ក៏ដូចជាការិយាល័យជួលបុគ្គលិកអោយចូលធ្វើការ ។

ក្រសួងទទួល បន្ទុកវិស័យការងារ បានកំណត់អំពីប្រាក់ឈ្នួលអប្បបរមាសំរាប់តែឧស្សាហកម្មកាត់ដេរសំលៀកបំពាក់វាយនភ័ណ្ឌនិងដេរស្បែកជើង។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ប្រាក់ឈ្នួលអប្បបរមាប្រហាក់ប្រហែលគ្នានេះ គួរតែផ្តល់អោយនៅឧស្សាហកម្មមន្តសាលដទៃទៀត ។

ប្រាក់ឈ្នួលអប្បបរមា និង ប្រាក់រង្វាន់សំរាប់ឧស្សាហកម្មកាត់ដេរសំលៀកបំពាក់វាយនភ័ណ្ឌ និង ដេរស្បែកជើងបានកំណត់ ដូចខាងក្រោមនេះ :

| ប្រភេទកម្មករនិយោជិត | ប្រាក់ឈ្នួលអប្បបរមាប្រចាំខែ |
|---|---|
| កូនជាង ( សេចក្តីជូនដំណឹង ០៦/៩៧) | ៣០ដុល្លារ* |
| រយៈពេលសាកល្បង (សេចក្តីជូនដំណឹង ១០៣/១៣) | ៧៥ដុល្លារ |
| កម្មករនិយោជិតជាប់លាប់( សេចក្តីជូនដំណឹង ១០៣/១៣) | ៨០ដុល្លារ |

*តារាងនេះយោងទៅតាមសេចក្តីជូនដំណឹង ០៦-៩៧ ដែលចែងថាកូនជាងជាពិសេស ក្នុងឧស្សាហកម្មសំលៀកបំពាក់នៅទីក្រុងភ្នំពេញ ប្រាក់ឈ្នួលអប្បបរមាគឺ ៣០ដុល្លារ។ ពុំមានប្រាក់ឈ្នួលអប្បរបរមាជាកំហិតសំរាប់កូនជាងនៅក្នុងឧស្សាហកម្ម សំលៀកបំពាក់នៅក្រៅទីក្នុងភ្នំពេញ ។

## ៥.២ ប្រាក់ឈ្នួលអប្បបរមាសំរាប់កម្មករនិយោជិតធ្វើការតាមបរិមាណផលិតផល ( កម្មករនិយោជិតដេរស៊ីប៉ុង )

ច្បាប់ស្តីពីការងារ មាត្រា ១០៨
សេចក្តីជូនដំណឹង ០៤៩/១០
និង១០៣/១៣
សេចក្តីបង្គាប់អាជ្ញាកណ្តាល ១៤/០៣
១៥៩/០៨(១) ១៦២/០៩(២) និង
៣៨/១០(២)

ប្រាក់ឈ្នួលអប្បបរមាសំរាប់កម្មករនិយោជិតដេរស៊ីប៉ុង នៅក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់វាយនភ័ណ្ឌ និង ដេរស្បែកជើង ដែលធ្វើការតាមម៉ោងធ្វើការធម្មតា ( ៤៨ ម៉ោងក្នុងមួយសប្តាហ៍ ) គឺ៨០ដុល្លារក្នុងមួយខែ។ ប្រសិនបើការបង់ប្រាក់ឈ្នួលរបស់ពួកគេ ផ្អែកទៅលើអត្រាបរិមាណតិចជាងនេះ និយោជកនៅតែត្រូវផ្តល់ប្រាក់ឈ្នួល ៨០ដុល្លារក្នុងមួយខែ។ ប្រសិនបើការបង់ប្រាក់របស់ពួកគេ ផ្អែកលើអត្រាបរិមាណលើសពី ៨០ដុល្លារ និយោជកត្រូវតែផ្តល់ប្រាក់ឈ្នួលដែល មានចំនួនលើសនោះ ។

## ៥.៣ ប្រាក់រង្វាន់ការងារអតីតភាពការងារ

និយោជកនៅក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ វាយនភ័ណ្ឌ និង ស្បែកជើង ត្រូវតែផ្តល់ប្រាក់រង្វាន់អតីតភាពទៅអោយកម្មករនិយោជិត ដែលមានអតីតភាពការងារយ៉ាងតិចបំផុត១ឆ្នាំ។ អតីតភាពនេះចាប់ផ្តើមនៅថ្ងៃទី១ ខែ សីហា ឆ្នាំ ២០០០។ ការងារមុនកាលបរិច្ឆេទនេះមិនបានរាប់ បញ្ចូលក្នុងការគិតពីរង្វាន់អតីតភាពទេ។

សេចក្តីជូនដំណឹង ០១៧/០០ និង ០៤១/១១
សេចក្តីបង្គាប់អាជ្ញាកណ្តាល (៥) ៨៩/១២(៦) និង ១៧៦/១២

តារាងខាងក្រោមនេះបង្ហាញអំពីរបៀបនៃការគិតរង្វាន់អតីតភាព ។

| រយៈពេលធ្វើការ | រង្វាន់អតីតភាពការងារក្នុងមួយខែ |
|---|---|
| + ១ឆ្នាំ* | ២ដុល្លារ |
| + ២ឆ្នាំ | ៣ដុល្លារ |
| + ៣ឆ្នាំ | ៤ដុល្លារ |
| + ៤ឆ្នាំ | ៥ដុល្លារ |
| + ៥ឆ្នាំ | ៦ដុល្លារ |
| + ៦ឆ្នាំ | ៧ដុល្លារ |
| + ៧ឆ្នាំ | ៨ដុល្លារ |
| + ៨ឆ្នាំ | ៩ដុល្លារ |
| + ៩ឆ្នាំ | ១០ដុល្លារ |
| ចាប់ពី ១០ឆ្នាំឡើងទៅ (អតិបរមា) | ១១ដុល្លារ |

* កំណត់សំគាល់: ប្រាក់រង្វាន់អតីតភាពចាប់ផ្តើមផ្តល់អោយកម្មករចាប់ពីខែទី ១៣ ។

## ៥.៤ ប្រាក់រង្វាន់អតីតការងារទៀងទាត់

កម្មករនិយោជិតនៅក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់វាយណភ័ណ្ឌ និង ដេរស្បែកជើងដែល ធ្វើការយ៉ាងទៀងទាត់រៀងរាល់ថ្ងៃក្នុង១ខែ ត្រូវតែបានទទួលប្រាក់រង្វាន់យ៉ាងតិចបំផុត ១០ដុល្លារ ក្នុង១ខែ។ កម្មករនិយោជិត ទាំងនេះរួម ទាំងកម្មករនិយោជិតម្តងម្កាល កម្មករនិយោជិតសាកល្បងការងារ និង កម្មករនិយោជិតដេរស៊ីបុងផង។

ច្បាប់ស្តីពីការងារ មាត្រា ១០
សេចក្តីជូនដំណឹង ០៧១/០០ ៧៤៥/០៦ និង ២៣០/១២
សេចក្តីបង្គាប់អាជ្ញាកណ្តាល ០៤/០៣ ២៦/០៣ ៦២/០៤ ៦៣/០៤ ១០/១២(២០) និង ១៣២/១២(៨)

និយោជកត្រូវតែផ្តល់ប្រាក់រង្វាន់ការងារទៀងទាត់ ប្រសិនបើកម្មករនិយោជិតបានទទួលការអនុញ្ញាតអោយឈប់សំរាក (ដូចជាការឈប់សំរាកប្រចាំឆ្នាំ ឬ ការឈប់សំរាក ថ្ងៃបុណ្យ) ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាល យល់ឃើញថា នៅពេលដែលកម្មករនិយោជិតសុំច្បាប់ឈប់សំរាក ព្យាបាលជំងឺដោយមានការបញ្ជាក់ពីគ្រូពេទ្យដែលទទួលស្គាល់តាមផ្លូវច្បាប់ ប្រាក់រង្វាន់ទៀងទាត់នេះត្រូវតែបង់តាមសមាមាត្រនៃថ្ងៃដែលធ្វើការ ។

**ឧទាហរណ៍: ការឈប់សំរាកពេលមានជំងឺ និង ប្រាក់រង្វាន់ការងារទៀងទាត់**

*ម៉ាលី* ធ្វើការពេញម៉ោងនៅរោងចក្រ *Z* ។ ក្នុងអំឡុងខែមិថុនា នាងមកធ្វើការយ៉ាងទៀងទាត់ លើកលែងតែរយៈពេលមួយថ្ងៃដែលនាងបានសុំច្បាប់ឈប់ព្យាបាលជំងឺដោយមានការបញ្ជាក់ត្រឹមត្រូវ ។

និយោជករបស់នាងអាចកាត់ប្រាក់ចំនួន ០,៣៨ដុល្លារ ( =១០ដុល្លារ/២៦ថ្ងៃ ) ពីក្នុងប្រាក់រង្វាន់ការងារទៀងទាត់ចំនួន ១០ដុល្លារ របស់នាង សំរាប់ខែមិថុនា ។

## ៥.៥ ប្រាក់ឧបត្ថម្ភការថែទាំសុខភាព

សេចក្តីជូនដំណឹង ២០៦/១១

និយោជកត្រូវតែផ្តល់ប្រាក់ឧបត្ថម្ភការថែទាំសុខភាពដល់កម្មករនិយោជិតដូចខាងក្រោម៖

១) គ្រប់កម្មករនិយោជិតទាំងអស់នៅក្នុងវិស័យឧស្សាហកម្មវាយនភ័ណ្ឌ សំលៀកបំពាក់ និង ស្បែកជើង ត្រូវតែទទួលបានប្រាក់ឧបត្ថម្ភការថែទាំសុខភាព ៥ដុល្លារ ក្នុង១ខែ។ ប្រាក់ឧបត្ថម្ភនេះ ត្រូវផ្តល់អោយបន្ថែមពីលើប្រាក់ឈ្នួលធម្មតារបស់កម្មករនិយោជិត (ប្រាក់ឈ្នួលគោល) ។

២) កម្មករនិយោជិតថ្មីទើបតែជ្រើសរើសក្នុងខែដំបូង ដែលផ្តើមធ្វើការតិចជាង ២៦ថ្ងៃការងារសំរាប់ការបើកប្រាក់ខែដំបូងរបស់ពួកគេ ត្រូវទទួលប្រាក់ឧបត្ថម្ភការថែទាំសុខភាព ដូចមានចែងខាងក្រោម៖

ក. និយោជិតដែលបានធ្វើការ ១៣ថ្ងៃ រឺ តិចជាងនេះ ត្រូវទទួលប្រាក់យ៉ាងតិចបំផុត ២.៥០ដុល្លារ សំរាប់ប្រាក់ឧបត្ថម្ភការថែទាំសុខភាព សំរាប់ខែដំបូង។

ខ. និយោជិតដែលបានធ្វើការ ១៤ថ្ងៃ រឺ ច្រើនជាងនេះ ត្រូវទទួលប្រាក់ឧបត្ថម្ភការថែទាំសុខភាពពេញ គឺ ៥ដុល្លារ សំរាប់ខែដំបូង ។

## ៥.៦ ប្រាក់ឧបត្ថម្ភកន្លែងស្នាក់នៅ/មធ្យោបាយធ្វើដំណើរ

សេចក្តីជូនដំណឹង ២៣០/១២

ប្រសិនបើនិយោជកមិនបានផ្តល់មធ្យោបាយធ្វើដំណើរ ឬកន្លែងស្នាក់នៅដល់កម្មករនិយោជិត និយោជកត្រូវផ្តល់ប្រាក់ដល់កម្មករនិយោជិតយ៉ាងតិចបំផុត ៧ដុល្លារ ក្នុង១ខែ សំរាប់មធ្យោបាយធ្វើដំណើរ ឬកន្លែងស្នាក់នៅ។

គ្រប់រោងចក្រទាំងអស់ ដែលមិនបានផ្តល់មធ្យោបាយធ្វើដំណើរ ឬកន្លែងស្នាក់នៅ ត្រូវតែផ្តល់ប្រាក់សំរាប់កម្មករនិយោជិតថ្មីទើបជ្រើសរើស ដែលផ្តើមធ្វើការតិចជាង ២៦ថ្ងៃនៃថ្ងៃធ្វើការ សំរាប់ថ្ងៃបើកប្រាក់ខែដំបូងរបស់ពួកគេ ដូចខាងក្រោម ៖

ក. កម្មករនិយោជិតដែលបានធ្វើការ ១៣ថ្ងៃ រឺ តិចជាងនេះ ត្រូវទទួលប្រាក់សោហ៊ុយធ្វើដំណើរ និងកន្លែងស្នាក់នៅចំនួន ៣.៥០ដុល្លារ សំរាប់ខែដំបូង ។

ខ. និយោជិតដែលបានធ្វើការ ១៤ថ្ងៃ រឺ ច្រើនជាងនេះ ត្រូវទទួលប្រាក់សោហ៊ុយធ្វើដំណើរ និងកន្លែងស្នាក់នៅចំនួន ៧ដុល្លារ សំរាប់ខែដំបូង ។

គ.សំរាប់កម្មករនិយោជិតដែលទទួលប្រាក់តាមថ្ងៃ រឺ តាមសប្តាហ៍ ប្រាក់សោហ៊ុយធ្វើដំណើរ និងកន្លែងស្នាក់នៅនេះត្រូវគណនាតាមអត្រា ០.២៧ដុល្លារក្នុងមួយថ្ងៃ។

## ៥.៧ របៀបនៃការបើកប្រាក់ឈ្នួល

ច្បាប់ស្តីពីការងារ មាត្រា ១១៣/១១៩ ១២៦ និង ១២៧
ប្រកាស ៨០/៩៧
សេចក្តីជូនដំណឹង ០៦/៩៧
ច្បាប់ស្តីការងារ មាត្រា១១៣/១១៥
សេចក្តីបង្គាប់អាជ្ញាកណ្តាល០២/០៤
ច្បាប់ស្តីពីការងារមាត្រា១១៣/១១៥
សេចក្តីបង្គាប់អាជ្ញាកណ្តាល៣៧/០៤

និយោជកត្រូវតែបើកប្រាក់ឈ្នួល:

- ទៅកម្មករនិយោជិតដោយផ្ទាល់ដៃ លើកលែងតែកម្មករ និយោជិតយល់ព្រមលើវិធីផ្សេងៗទៀត
- ជាក្រដាក់ប្រាក់
- នៅកន្លែងធ្វើការផ្ទាល់ ឬ នៅជិតកន្លែងធ្វើការ ដែលធ្វើឡើងនៅថ្ងៃធ្វើការមិនមែនថ្ងៃឈប់សំរាកទេ។ ប្រសិនបើថ្ងៃបើកប្រាក់ឈ្នួលប៉ះចំថ្ងៃឈប់ និយោជកត្រូវតែបើកប្រាក់ឈ្នួលមិនត្រូវថ្ងៃឈប់សំរាកនោះ ហើយនិង
- ក្នុងម៉ោងធ្វើការ ។

ច្បាប់ស្តីពីការងារ មាត្រា ១១៣-១១៥
សេចក្តីបង្គាប់អាជ្ញាកណ្តាល ៣៧/០៤ ៧២/១០(៧) ៣៩/១២(៧) និង ១៧២/១២(៦)

ឯកសារយោង

## ៥.៨ ការកាត់ប្រាក់ឈ្នួល និង ការពិន័យជាប្រាក់

ច្បាប់ស្តីពីការងារ មាត្រា ២៨ ៩៤ ១២៦ និង ១២៧

សេចក្តីបង្គាប់អាជ្ញាកណ្តាល ០២/០៣ ២១/០៣ ៣០/០៣ ៦០/០៤ ១៩/១២(៣) ១០១/១២(៣) និង ១៥៨/១២(៦)

ជាទូទៅ និយោជកមិនត្រូវបានអនុញ្ញាតអោយកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតទេ។ ជាពិសេស និយោជកមិនអាចគិត ឬ កាត់ប្រាក់ឈ្នួលដូចខាងក្រោមបានទេ:

- ពិន័យជាប្រាក់ ឬ កាត់ប្រាក់របស់កម្មករនិយោជិត ដើម្បីដាក់ទណ្ឌកម្មពួកគេពីកំហុស ឬ ការបដិសេធមិនព្រមធ្វើការបន្ថែមម៉ោងនោះទេ
- តម្រូវអោយមានកិច្ចធានាជាប្រាក់កាស ឬ ជាប័ណ្ណសិទ្ធណាមួយ ដើម្បីទទួលបាន ឬ រក្សាការងារ
- កាត់ប្រាក់ឈ្នួល ជាការដោះដូរនឹងការជួលអោយធ្វើការ
- កាត់ប្រាក់ឈ្នួល ពីកម្មករនិយោជិតដែលជ្រើសរើសមិនញ៉ាំអាហារនៅក្នុងក្រុមហ៊ុន
- គិតតម្លៃពីកម្មករនិយោជិតច្រើនជាងតម្លៃពិតប្រាកដដោយការបាត់ប័ណ្ណសំគាល់ខ្លួន ឬ
- គិតតម្លៃពីកម្មករនិយោជិតនូវប្រាក់សំរាប់ការ ពិនិត្យសុខភាពដែលជាកាតព្វកិច្ចរបស់និយោជក ។

និយោជកអាចកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតតែដើម្បីបង់ការចំណាយជាក់ស្តែងលើ:

- គ្រឿងប្រដាប់ប្រដា និង ឧបករណ៍ចាំបាច់សំរាប់កម្មករនិយោជិតមិនបានយកមកប្រគល់អោយវិញ
- វត្ថុធាតុ និង សំភារៈផ្សេងៗដែលកម្មករនិយោជិតទទួលបន្ទុក និង ប្រើប្រាស់ និង
- ចំនួនប្រាក់ដែលនៅជំពាក់អត្សាបដ្ឋាន ។

ចំពោះការកាត់ប្រាក់ខែទាំងនេះ ចំនួនទឹកប្រាក់ដែលកាត់ពីកម្មករនិយោជិត មិនត្រូវអោយហួសដល់ភាគប្រាក់ឈ្នួលអប្បបរមា ដែលកម្មករនិយោជិតយកទៅផ្ទះនោះទេ ។

និយោជក ក៏អាចកាត់ប្រាក់ឈ្នួលសំរាប់ជាភាគទានសហជីពផងដែរ ( សូមមើលកថាខ័ណ្ឌទី ១២.5 ខាងក្រោម )។

**ឧទាហរណ៍: ការកាត់ប្រាក់ឈ្នួល**

កម្មករនិយោជិតនៅក្នុងរោងចក្រ X ទាំងអស់ត្រូវបានគេត្រូវបានគេផ្តល់អោយនូវប័ណ្ណចេញដែលធ្វើពីប្លាស្ទីក ។ ដើម្បីជំនួសប័ណ្ណមួយនៃប័ណ្ណទាំងនេះ និយោជកត្រូវចំណាយ ២០០០រៀល ។

និយោជកអាចរៀបចំវិធានការមួយថែងថា ប្រសិនបើកម្មករនិយោជិតណាម្នាក់ ធ្វើអោយបាត់ប័ណ្ណសំគាល់ខ្លួនកម្មករនោះនឹងត្រូវកាត់២០០០រៀល ពីប្រាក់ឈ្នួលដើម្បីធ្វើប័ណ្ណនោះឡើងវិញ។

ឯកសារយោង

## ៥.៩ ការជូនដំណឹងអំពីប្រាក់ឈ្នួលទៅកម្មករនិយោជិត

ច្បាប់ស្តីពីការងារ មាត្រា ១១២
សេចក្តីបង្គាប់អាជ្ញាកណ្តាល ២៤/០៣ ៦២/១០(៦) ៥៦/១១(៥) ៤០/១២(២) និង ៥៨/១២(១)

និយោជកត្រូវតែពន្យល់អោយច្បាស់លាស់ទៅកម្មករនិយោជិតអំពីរបៀបគណនាប្រាក់ឈ្នួលរបស់ពួកគេ:

- មុនពេលទទួលកម្មករនិយោជិតអោយធ្វើការ និង
- មុននឹងផ្លាស់ប្តូរប្រាក់ឈ្នួលរបស់ពួកគេ ( ដូចជាមុនពេលប្តូរទំរង់ និងតម្លៃបុង )

និយោជក គួរផ្តល់បុងបើកប្រាក់ឈ្នួលទៅកម្មករនិយោជិតនៅថ្ងៃបើកប្រាក់ឈ្នួលនីមួយៗ។ បុងបើកប្រាក់ទាំងនេះត្រូវតែសរសេរជាភាសាខ្មែរ និង បង្ហាញអំពីរបៀបដែលគណនាប្រាក់ឈ្នួល ។

# ផ្នែកទី៦ ថិរវេលាធ្វើការ និង ការងារបន្ថែមម៉ោង

ឯកសារយោង

## ៦.១ ថិរវេលាធ្វើការធម្មតា

ជាទូទៅ ថិរវេលាធ្វើការធម្មតាមិនគួរលើសពី ៨ម៉ោងក្នុង១ថ្ងៃ ឬ មិនត្រូវលើសពី៤៨ម៉ោងក្នុង១សប្ដាហ៍ ។

ច្បាប់ស្ដីពីការងារ មាត្រា ១៣៧

## ៦.២ ថ្ងៃឈប់សំរាកប្រចាំសប្ដាហ៍

កម្មករនិយោជិតត្រូវតែបានឈប់សំរាកយ៉ាងតិចណាស់មួយថ្ងៃពេញ (២៤ម៉ោង) ក្នុងសប្ដាហ៍។ ជាធម្មតាគឺនៅថ្ងៃអាទិត្យ។

ច្បាប់ស្ដីពីការងារ មាត្រា ១៤៦-១៤៨

## ៦.៣ ម៉ោងធ្វើការដែលអាចផ្លាស់ប្ដូរបាន-ការឈប់សំរាកនៅរសៀលថ្ងៃសៅរ៍

និយោជកអាចកំណត់ចំនួនម៉ោងធ្វើការធម្មតាបាន ដើម្បីអោយកម្មករនិយោជិតបានឈប់សំរាកនៅរសៀលថ្ងៃសៅរ៍ និង ថ្ងៃអាទិត្យ។ ប៉ុន្តែ និយោជកមិនត្រូវបន្ថែមម៉ោងធ្វើការនៅថ្ងៃធម្មតាអោយលើសពី៩ម៉ោងក្នុងមួយថ្ងៃឡើយ ។

ច្បាប់ស្ដីពីការងារ មាត្រា ១៤១
ប្រកាស ១៤៣/០២

## ៦.៤ ថិរវេលាធ្វើការសំរាប់កម្មករនិយោជិតក្មេង

អនីតិជនមិនអាចធ្វើការលើសពី ៨ម៉ោងក្នុង១ថ្ងៃបានទេ ហើយពួកគេត្រូវបានការឈប់សំរាកយ៉ាងតិចចំនួន ១៣ម៉ោងបន្តបន្ទាប់គ្នា ។

ប្រកាស ១៤៤/០២

## ៦.៥ ការងារពេលយប់

ច្បាប់ការងារស្ដីពីការងារពេលយប់ ត្រូវបានធ្វើវិសោធកម្ម ក្នុងឆ្នាំ២០០៧។

មាត្រា១៤៤ (វិសោធនកម្ម) ចែងថា ការងារពេលយប់ គឺធ្វើឡើងពីចន្លោះពីម៉ោង ២២:00 ដល់ 0៥:00 ព្រឹក ។

ក្នុងមាត្រា ១៤៤ ( វិសោធនកម្ម ) ការងារពេលយប់ ធ្វើឡើងកំឡុងពេលធ្វើការធម្មតា ( មិនមែនម៉ោងបន្ថែម ) ត្រូវបានប្រាក់ឈ្នួល ១៣០% នៃអត្រាម៉ោង ធ្វើការធម្មតា ដែលមិនមែនធ្វើការនៅពេលយប់ ។

ក្នុងមាត្រា១៣៩ ( វិសោធនកម្ម ) ការងារពេលយប់ដែលធ្វើបន្ថែមម៉ោង ត្រូវផ្តល់ប្រាក់ឈ្នួល ២០០%នៃអត្រាម៉ោងធ្វើការធម្មតា ដែលមិនធ្វើការពេលយប់ (កើនឡើង ១០០%បន្ថែមលើប្រាក់ឈ្នួលគោល)។

ការធ្វើវិសោធនកម្មលើ មាត្រា ១៤៤ មិនបានផ្លាស់ប្តូរ អត្ថន័យនៃពាក្យ "យប់" ដែលនៅតែមាន ន័យថារយៈពេលយ៉ាងតិច ១១ម៉ោង រួមបញ្ចូលទាំងរយៈពេល ចន្លោះពីម៉ោង ២២:00 ដល់0៥:00 ព្រឹក ។ យោងតាមក្រុមប្រឹក្សាអាជ្ញាកណ្តាលសហគ្រាស ត្រូវកំណត់រយៈពេល យ៉ាង តិច១១ម៉ោង ថាជាពេលយប់ (ដូចជាម៉ោង

ច្បាប់ស្ដីពីការងារ មាត្រា ១៣៩ និង១៤៤ (វិសោធនកម្ម)
ប្រកាស ៨០/៩៩ សារាចរ ២៤/៩៩
សេចក្ដីជូនដំណឹង ០១៤/៩៩
សេចក្ដីបង្គាប់អាជ្ញាកណ្ដាល ៩៧/០៤
សេចក្ដីបង្គាប់អាជ្ញាកណ្ដាល ១១៩/០៩ (១)
សេចក្ដីបង្គាប់អាជ្ញាកណ្ដាល ២៥/១១(១)

២០:០០-០៧:០០ ឬម៉ោង ១៩:០០-០៦:០០ ) ហើយប្រសិនបើ កម្មករនិយោជិត បញ្ចប់ការងារក្នុងកំឡុងពេលនេះ និយោជកត្រូវផ្តល់អោយ ពួកគេនូវ ទីកន្លែងដេកឬការដឹកជញ្ជូន ទៅផ្ទះដូចមានតំរូវក្នុងសេចក្តីប្រកាស ៨០/៩៩ ។

## ៦.៦ ការងារពេលយប់សំរាប់កម្មករនិយោជិតក្មេង

ប្រកាស ១៩៨/០២

អនីតិជនមិនត្រូវបានអនុញ្ញាតអោយធ្វើការពេលយប់នៅក្នុងរោងចក្រកាត់ដេរសំលៀកបំពាក់ទេ។ ករណីលើកលែងចំពោះវិធាននេះគឺអ្នកមានអាយុ ពី១៦ ដល់ ១៨ឆ្នាំ ដែលគេអនុញ្ញាតអោយធ្វើការពេលយប់ ដើម្បីការពារគ្រោះថ្នាក់ ឬ ជួសជុលឧបករណ៍បន្ទាប់ពីគ្រោះថ្នាក់។ ប្រសិនបើនេះកើតឡើងនិយោជកត្រូវតែជូនដំណឹងទៅក្រសួងទទួលបន្ទុកវិស័យការងារជាមុន ។

អនីតិជនត្រូវបានអនុញ្ញាតអោយធ្វើការនៅពេលយប់នៅក្នុងរោងចក្រប្រភេទខ្លះដែលមានចុះក្នុងប្រកាស ១៩៨/០២ ប៉ុន្តែគ្រាន់តែក្នុងគោលបំណងហ្វឹកហ្វឺនតែប៉ុណ្ណោះ ។

## ៦.៧ ការងារបន្ថែមម៉ោង

ច្បាប់ស្តីពីការងារ មាត្រា ១៣៧-១៤០
ប្រកាស ៨០/៩៩
សេចក្តីជូនដំណឹង ០១៤/៩៩

ការងារបន្ថែមម៉ោង គឺជាការងារដែលធ្វើលើសចំនួនម៉ោង ការធម្មតា។

### ៦.៧.១ ការងារបន្ថែមម៉ោងត្រូវតែជាការងារខុសពីការងារខុសពីធម្មតា និង បន្ទាប់តែប៉ុណ្ណោះ

ច្បាប់ពីការងារ មាត្រា ១៣៩

ការងារបន្ថែមម៉ោងត្រូវតែទទូលការអនុញ្ញាតការងារខុសពីធម្មតា និង បន្ទាន់ប៉ុណ្ណោះ ។

### ៦.៧.២ ការងារបន្ថែមម៉ោងត្រូវតែឈរលើគោលការណ៍ស្ម័គ្រចិត្ត

ប្រកាស ៨០ /៩៩
សេចក្តីបង្គាប់អាជ្ញាកណ្តាល ០៧/០៨(១) និង ៨៦/១១(៨)

កម្មករនិយោជិតត្រូវតែទទូលការអនុញ្ញាតអោយជ្រើសរើសថាតើត្រូវធ្វើការបន្ថែមម៉ោង ឬ មិនធ្វើ។ និយោជកមិនត្រូវដាក់ទោសទណ្ឌ ចំពោះកម្មករនិយោជិតណាដែលជ្រើសរើសមិនធ្វើការងារបន្ថែមម៉ោងនោះទេ ។

### ៦.៧.៣ ការតម្រូវឱ្យមានការអនុញ្ញាតឱ្យធ្វើការងារបន្ថែមម៉ោងពីក្រសួងទទួលបន្ទុកវិស័យការងារ

ប្រកាស ៨០/៩៩

និយោជក ត្រូវតែទទូលការអនុញ្ញាតពីក្រសួងទទូលបន្ទុកវិស័យការងារមុនពេលផ្តល់ការងារបន្ថែមម៉ោងទៅកម្មករនិយោជិត។

## ៦.៧.៤ ការងារបន្ថែមម៉ោងអតិបរមា ២ម៉ោងក្នុង១ថ្ងៃ

សេចក្តីបង្គាប់អាជ្ញាកណ្តាល១០/០៤

យោងតាមលិខិតអនុញ្ញាតការងារបន្ថែមម៉ោងដែលចេញពីក្រសួងទទួលបន្ទុកវិស័យការងារ ការងារបន្ថែមម៉ោងជាធម្មតាត្រូវបានកំរិត ត្រឹម២ម៉ោងក្នុង១ថ្ងៃ ។

## ៦.៧.៥ ការបើកប្រាក់សំរាប់ការងារបន្ថែមម៉ោង

ច្បាប់ស្តីពីការងារ មាត្រា ១៣៩ (វិសោធនកម្ម)
ប្រកាស ១០/៩៩ និង ៨០/៩៩
សេចក្តីបង្គាប់អាជ្ញាកណ្តាល ១៩/១០(៤) និង ៣៦/១១(២)

កម្មករនិយោជិតត្រូវតែបានទទួលប្រាក់បន្ថែមលើការងារបន្ថែមម៉ោង។ តារាងខាងក្រោម កំណត់អំពីអត្រាប្រាក់ឈ្នួល:

| ពេលវេលាធ្វើការ | អត្រាប្រាក់ឈ្នួល |
|---|---|
| ការងារបន្ថែមម៉ោងនៅក្នុងនៅថ្ងៃច័ន្ទ ដល់ ថ្ងៃសៅរ៍ (មិនមែនការងារពេលយប់) | ១៥០% |
| ធ្វើការបន្ថែមម៉ោងពីថ្ងៃច័ន្ទ ដល់ ថ្ងៃសៅរ៍ (ការងារពេលយប់ ២២:០០-០៥:០០) | ២០០%* |
| ថ្ងៃអាទិត្យ | ២០០% |
| ថ្ងៃបុណ្យសាធារណ: | ២០០% (ប្រាក់ឈ្នួលធម្មតា+១០០% បន្ថែម)** |

*សូមមើលកថាខ័ណ្ឌទី៦.៥ ស្តីពីការងារពេលយប់

**សូមមើលកថាខ័ណ្ឌទី៧.១ ស្តីពីការឈប់សំរាកថ្ងៃបុណ្យដោយមានប្រាក់ឈ្នួល

ដើម្បីគិតប្រាក់ឈ្នួលម៉ោងបន្ថែម ដំបូងត្រូវកំណត់អំពីអត្រាប្រាក់ឈ្នួលតាមម៉ោង។ ការគណនានេះធ្វើឡើងតាមការប្រើរូបមន្តខាងក្រោមនេះ :

ក្នុងការអនុវត្តន៍សំរាប់វិស័យឧស្សាហកម្មនាពេលបច្ចុប្បន្ននេះ គេកំណត់យកប្រាក់ឈ្នួលគោលប្រចាំ ខែដូចកំណត់ក្នុងរូបខាងក្រោមនេះ :

$$\text{អត្រាប្រាក់ឈ្នួលតាមម៉ោង} = \frac{\text{ប្រាក់ឈ្នួលគោលប្រចាំខែ}}{\text{២៦(ថ្ងៃ)}\times\text{៨(ម៉ោង)}}$$

អត្រាប្រាក់ឈ្នួលតាមម៉ោងគុណនឹងចំនួនម៉ោងការងារបន្ថែមម៉ោង និង អត្រាប្រាក់ឈ្នួលការងារបន្ថែមម៉ោង ស្មើនឹងការផ្តល់ប្រាក់ឈ្នួលបន្ថែមម៉ោង ។

*អត្រាប្រាក់ឈ្នួលប្រចាំម៉ោង X ចំនួនម៉ោងធ្វើការបន្ថែមម៉ោង X អត្រាប្រាក់ឈ្នួលបន្ថែមម៉ោង = ប្រាក់ឈ្នួលបន្ថែមម៉ោង*

**ឧទាហរណ៍: ការងារបន្ថែមម៉ោងសំរាប់កម្មករនិយោជិតទៀងទាត់**

ម៉ាលីកាធ្វើការប្រាក់ឈ្នួលតាមម៉ោងធ្វើការ ។ នាងរកបាន៨០ដុល្លារក្នុងមួយខែ។ នៅថ្ងៃមួយនិយោជកសុំអោយនាងធ្វើការបន្ថែមចំនួនពីរម៉ោង ។

ការគិតប្រាក់ឈ្នួលសំរាប់ការងារបន្ថែមម៉ោងចំនួនពីរម៉ោងរបស់ ម៉ាលីកា ត្រូវបានកំណត់ដូចខាងក្រោមនេះ:

*អត្រាប្រាក់ឈ្នួលប្រចាំម៉ោង* $= \frac{(\text{៨០ប្រាក់ឈ្នួលគោលប្រចាំខែ})}{\text{២៦(ថ្ងៃ)}\times\text{៨(ម៉ោង)}} =$ ០.៣៨ ដុល្លារក្នុងមួយម៉ោង

*ប្រាក់ឈ្នួលសំរាប់ការងារបន្ថែមម៉ោងរយ:ពេលពីរម៉ោង= ០.៣៨ X ២ម៉ោង X ១៥០% = ១.១៤ដុល្លារ*

ច្បាប់មិនមានកំណត់អោយបានច្បាស់អំពីរបៀបគណនាអត្រាប្រាក់ឈ្នួលតាមម៉ោង។ ឧទាហរណ៍ អ្នកខ្លះអះអាងថាប្រាក់រង្វាន់អតីតភាពគួរតែគិតទៅក្នុងការគណនារកប្រាក់ឈ្នួលគោល។

## ៦.៧.៦ អត្រាប្រាក់ឈ្នួលការងារបន្ថែមម៉ោងសំរាប់កម្មករនិយោជិតដេរស៊ីបុង

ច្បាប់ស្តីពីការងារ មាត្រា ១០៨ និង ១៣៩
ប្រកាស ៨០ / ៩៩
សេចក្តីជូនដំណឹង ០១៧/០០
សេចក្តីបង្គាប់អាជ្ញាកណ្តាល ៧៨ / ០៤

អត្រាប្រាក់ខ្ពស់ដូចគ្នា ត្រូវតែអនុវត្តចំពោះអត្រាថ្លៃបុងសំរាប់កម្មករនិយោជិតដេរស៊ីបុង ដែលធ្វើការបន្ថែមម៉ោង។ នេះមានន័យថាកម្មករនិយោជិតដេរស៊ីបុងគួរទទួលបានប្រាក់ឈ្នួលបន្ថែមចំនួន៥០%សំរាប់ការងារដែលគេបំពេញក្នុងអំឡុងម៉ោងធ្វើការបន្ថែមម៉ោងធម្មតា និង ១០០% បន្ថែមសំរាប់ការងារបន្ថែមម៉ោងពេលយប់ ថ្ងៃអាទិត្យនិង ថ្ងៃបុណ្យសាធារណ: ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថាច្បាប់មិនបានចែងអំពីរូបមន្តសំរាប់គិតអត្រាប្រាក់ឈ្នួលការងារបន្ថែមម៉ោងតែបង់ប្រាក់ឈ្នួលការងារបន្ថែមម៉ោង យោងតាមឧទាហរណ៍ដូចកំណត់ខាងក្រោមនេះ ។

**ឧទាហរណ៍: ការគណនាប្រាក់ឈ្នួលបន្ថែមម៉ោងសំរាប់កម្មករនិយោជិតដេរស៊ីបុង**

*សុភ័ណ្ឌ* ធ្វើផ្នែកការកាត់ ហើយទទួលប្រាក់ឈ្នួលតាមអត្រាបុង គឺ 0.៦0ដុល្លារក្នុងមួយបុង ។ ខែមួយ និយោជករវល់យ៉ាងខ្លាំង ហើយសុំអោយ *សុភ័ណ្ឌ* ធ្វើការបន្ថែមម៉ោងចំនួន ២0ម៉ោង ក្នុងខែនោះ ។

*សុភ័ណ្ឌ* ធ្វើបាន១៥0បុងក្នុងខែនោះ ដែលធ្វើអោយគាត់ទទួលបានឈ្នួលចំនួន៦0ដុល្លារ ( ដោយផ្អែកលើអត្រាបរិមាណ0.៦0ដុល្លារក្នុងមួយបុង )។ ក៏ប៉ុន្តែ *សុភ័ណ្ឌ* មានសិទ្ធិទទួលបានប្រាក់ឈ្នួលខ្ពស់ជាងនេះ (១៥0%) សំរាប់ការងារបន្ថែមម៉ោងចំនួន២0ម៉ោងរបស់គាត់ ។

ការគិតប្រាក់ឈ្នួលសំរាប់ការងារបន្ថែមម៉ោងចំនួន២0ម៉ោងរបស់ *សុភ័ណ្ឌ* ត្រូវបានកំណត់ដូចខាងក្រោមនេះ:

*អត្រាប្រាក់ឈ្នួលប្រចាំម៉ោង* = *៩0 ដុល្លារ(ទឹកប្រាក់សរុបដែលរបានពីការដេរស៊ីបុងសំរាប់រយៈពេល១ខែ)* / *២២៨ (ចំនួនម៉ោងការងារក្នុងរយៈពេលខែ)*

= *0.៣៩ដុល្លារ*

*ប្រាក់ឈ្នួលបន្ថែមសំរាប់ការងារបន្ថែមម៉ោង = អត្រាប្រាក់ឈ្នួលប្រចាំម៉ោង (0.៣៩) x ១.៥% x ២0ម៉ោង = ១១.៧0 ដុល្លារ*

ប្រសិនបើការងារបន្ថែមម៉ោងបានធ្វើនៅពេលយប់ ឬ ថ្ងៃអាទិត្យ អត្រាប្រាក់ឈ្នួលដែល ប្រើសំរាប់ការគិតថ្លៃឈ្នួលគួរស្មើនឹង១00% ជំនួសអោយ៥0% ។

## ៦.៧.៧ ប្រាក់ឧបត្ថម្ភថ្លៃអាហារសំរាប់ការងារបន្ថែមម៉ោង

**សេចក្តីជូនដំណឹង 0៩១/១១**
**សេចក្តីបង្គាប់អាជ្ញាកណ្តាល ៧៣/0៤ ៨២/១២(២) និង ១៦៣/១២(២)**

កម្មករនិយោជិតដែលធ្វើការបន្ថែមម៉ោងត្រូវទទួលបាននូវប្រាក់ឈ្នួលចំនួន ២000រៀលក្នុង១ថ្ងៃសំរាប់អាហារ ឬ ទទួលអាហារមួយពេលដោយឥតគិតថ្លៃរៀងរាល់ថ្ងៃដែលគេធ្វើការងារបន្ថែមម៉ោង។ អាហារនេះអាចត្រូវបានផ្តល់ជូននៅពាក់កណ្តាលម៉ោង ឬ មុនចាប់ផ្តើមធ្វើការថែមម៉ោង ។

# ផ្នែកទី៧ ការឈប់សំរាកថ្ងៃបុណ្យសាធារណៈ ថ្ងៃឈប់សំរាក និង អត្ថប្រយោជន៍ដទៃទៀត

ឯកសារយោង

## ៧.១ ការឈប់សំរាកថ្ងៃបុណ្យសាធារណៈដោយមានប្រាក់ឈ្នួល

ច្បាប់ស្តីពីការងារ មាត្រា ១៦១ ១៦២ និង ១៦៤
ប្រកាស ១០/៩៩
សេចក្តីបង្គាប់អាជ្ញាកណ្តាល ១៤/១០(២) និង ៥៧/១២(៥)

ក្រសួងទទួលបន្ទុកវិស័យការងារចេញប្រកាសរៀងរាល់ឆ្នាំ ដើម្បីកំណត់ថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួលនៅប្រទេសកម្ពុជា ។

បើសិនជាថ្ងៃបុណ្យប៉ះចំថ្ងៃអាទិត្យ កម្មករនិយោជិតអាចឈប់សំរាកនៅថ្ងៃច័ន្ទបន្ទាប់។ ការឈប់សំរាកនៅថ្ងៃបុណ្យមិនប៉ះពាល់ដល់រយៈពេលនៃសេវាកម្ម ( អតីតភាព ) ឬការកាត់បន្ថយថ្ងៃឈប់សំរាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលទេ ។

និយោជកត្រូវតែផ្តល់ប្រាក់ឈ្នួលធម្មតាដល់កម្មករនិយោជិតសំរាប់ថ្ងៃបុណ្យ ។

និយោជកដែលធ្វើអាជីវកម្មមិនអាចបញ្ឈប់សកម្មភាពថ្ងៃបុណ្យ អាចស្នើអោយកម្មករនិយោជិតធ្វើការនៅថ្ងៃទាំងនេះបាន។ ការងារនេះត្រូវតែធ្វើដោយស្ម័គ្រចិត្ត ។ និយោជកត្រូវតែផ្តល់អោយកម្មករនិយោជិត នូវប្រាក់ឈ្នួលទៀងទាត់របស់ពួកគេបូកជាមួយនឹងចំនួនទឹកប្រាក់មួយរយភាគរយទៀតសំរាប់ការងារនៅថ្ងៃបុណ្យ ។ នេះមានន័យថា ពួកគេទទួលបានប្រាក់ឈ្នួល១ថ្ងៃបន្ថែមទៅលើប្រាក់ឈ្នួលធម្មតារបស់ពួកគេ ។

**ឧទាហរណ៍: ការងារនៅថ្ងៃបុណ្យ**

*ណារិទ្ធិ* ធ្វើការនៅក្នុងរោងចក្រកាត់ដេរសំលៀកបំពាក់ទទួលបានឈ្នួល ២.៣៨ដុល្លារក្នុង១ថ្ងៃ។ នេះគឺជារដូវរវល់បំផុត ហើយនិយោជករបស់គាត់បានសុំអោយ គាត់ធ្វើការនៅថ្ងៃបុណ្យ។ បើសិន ជា *ណារិទ្ធិ* មិនធ្វើគាត់អាចទទួលប្រាក់ឈ្នួលធម្មតាសំរាប់ថ្ងៃបុណ្យ (២.៣៨ដុល្លារក្នុង១ថ្ងៃ) ។ តែបើសិនជាគាត់ធ្វើការ គាត់ទទួលបានប្រាក់ឈ្នួលមួយថ្ងៃទៀត (២.៣៨ដុល្លារ)។

## ៧.២ ការឈប់សំរាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល

ច្បាប់ស្តីពី មាត្រា ១៦៦-១៧០
សេចក្តីជូនដំណឹង ០១៧/០០

កម្មករនិយោជិតទាំងអស់មានសិទ្ធិឈប់សំរាក់ប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល។

កម្មករនិយោជិតពេញម៉ោងទទួលបាន ១.៥ថ្ងៃនៃការសំរាកប្រចាំឆ្នាំក្នុង១ខែ គឺស្មើនឹង១៨ថ្ងៃក្នុងមួយឆ្នាំ។ កម្មករនិយោជិតដែលធ្វើការតិចជាង ៤៨ម៉ោង ក្នុង១សប្តាហ៍ទទួលបានការសំរាកតាមមូលដ្ឋានអត្រាសមាមាត្រ។ ឧទាហរណ៍ ប្រសិនបើកម្មករនិយោជិតធ្វើការបានពាក់កណ្តាលនៃពេលវេលាធ្វើការធម្មតា ពួកគេទទួលបាន ០.៧៥ថ្ងៃសំរាកប្រចាំឆ្នាំក្នុង១ខែ ។

| ចិរវេលាធ្វើការធម្មតា (ម៉ោងក្នុងមួយសប្តាហ៍) | ការឈប់សំរាកក្នុងមួយខែ (ថ្ងៃធ្វើការធម្មតា) |
|---|---|
| ៤៨ | ១.៥០ ថ្ងៃ |
| ៤០ | ១.២៥ ថ្ងៃ |
| ២៤ | ០.៧៥ ថ្ងៃ |

## ៧.២.១ ថ្ងៃឈប់សំរាកបន្ថែមចំពោះការខាររយៈពេលយូរ

ច្បាប់ស្តីពីការងារមាត្រា ១៦៦ សេចក្តីបង្គាប់អាជ្ញាកណ្តាល ៦២/០៤ ១៥៥/០៩(១) ១១២/១០(៤) និង ៤៦/១២(៥)

និយោជកត្រូវតែផ្តល់អោយកម្មករនិយោជិត១ថ្ងៃបន្ថែមរយៈពេលរៀងរាល់៣ឆ្នាំនៃការងារបន្តបន្ទាប់ដូចបង្ហាញនៅក្នុងតារាងខាងក្រោមនេះ ៖

| ចំនួនឆ្នាំនៃការងារ | ចំនួនថ្ងៃនៃការឈប់សំរាកប្រចាំឆ្នាំ |
|---|---|
| ១-៣ | ១៨ |
| ៤-៦ | ១៩ |
| ៧-៩ | ២០ |

## ៧.២.២ សិទ្ធិនៃការប្រើការឈប់សំរាក

ច្បាប់ស្តីពីការងារ មាត្រា ១៦៧ សេចក្តីបង្គាប់អាជ្ញាកណ្តាល ២៧/០៤ ៧២/១០(៣) ១១៦/១១(៧) និង ១៨១/១២(៧)

និយោជកត្រូវតែអនុញ្ញាតអោយកម្មករនិយោជិតឈប់សំរាកប្រចាំឆ្នាំរបស់ពួកគេនៅពេលដែលគេស្នើសុំលើកលែងតែមានមូលហេតុបន្ទាន់ជាពិសេសដែលកម្មករនិយោជិតមិនអាចឈប់សំរាកប្រចាំឆ្នាំបាន។ កម្មករនិយោជិតមានសិទ្ធិប្រើប្រាស់សិទ្ធិឈប់សំរាកប្រចាំឆ្នាំបន្ទាប់ពីធ្វើការបានមួយឆ្នាំ។

និយោជកអាចកំណត់វិធានសមហេតុផលអំពីរយៈពេលជូនដំណឹង ដែលកម្មករនិយោជិតត្រូវផ្តល់ដំណឹងមុនពេលឈប់សំរាកប្រចាំឆ្នាំ ។

## ៧.២.៣ ការបើកប្រាក់ឈ្នួលជាមុន

ច្បាប់ស្តីពីការងារ មាត្រា ១៦៨ សេចក្តីបង្គាប់អាជ្ញាកណ្តាល ២៧/០៤ ២៣/០៨(៧) ៩០/០៩(៤) និង ១៧/១២(២)

មុនពេលឈប់សំរាកប្រចាំឆ្នាំ
និយោជកត្រូវតែផ្តល់អោយកម្មករនិយោជិតនូវប្រាក់ឈ្នួលដែលពួកគេត្រូវទទួលបើសិនជាពួកគេនៅធ្វើការ។

ការផ្តល់ប្រាក់ឈ្នួលសំរាប់ពេលឈប់សំរាកប្រចាំត្រូវតែផ្អែកលើ:

- ប្រាក់ទទួលបានជាក់ស្តែងជាមធ្យមរបស់កម្មករនិយោជិតក្នុងអំឡុងពេលមួយឆ្នាំមុនពេលឈប់សំរាកប្រចាំឆ្នាំ ឬ
- ប្រាក់ឈ្នួលប្រចាំថ្ងៃដែលកម្មករនិយោជិតអាចបានទទួល ប្រសិនបើពួកគេទៅធ្វើការ ។

និយោជកត្រូវតែផ្តល់ប្រាក់ឈ្នួលណាមួយខាងលើដែលច្រើនជាង ។

**ឧទាហរណ៍: ការផ្ដល់ប្រាក់ឈ្នួលសំរាប់ពេលឈប់សំរាកប្រចាំឆ្នាំ**

*សុខ* បានធ្វើការនៅក្នុងរោងចក្រកាត់ដេរសំលៀកបំពាក់រយ:ពេល១ឆ្នាំ និង មិនដែលឈប់សំរាកប្រចាំឆ្នាំទេ។ គាត់បានទទួលប្រាក់ឈ្នួល ៨០ដុល្លារ ក្នុង១ខែ និង តែងតែមកធ្វើការយ៉ាងទៀង ទាត់។ រួមទាំងប្រាក់រង្វាន់ គាត់ទទួលបានសរុបគឺ ១១៦៨ដុល្លារ សំរាប់រយ:ពេល ១២ ខែកន្លងមក ។ បន្ទាប់ពី ១២ខែត្រឹម *សុខ* ទទួលបានការអនុញ្ញាតសំរាកប្រចាំឆ្នាំ ៦ថ្ងៃ ដើម្បីត្រលប់ទៅលេង ភូមិកំណើត ។

និយោជកត្រូវតែផ្ដល់ប្រាក់ឈ្នួលអោយ សុខ សំរាប់ការឈប់សំរាកជាមុន ។ ដើម្បីគិតប្រាក់ ឈ្នួលរបស់ សុខ និយោជកត្រូវតែគិតចំនួនប៉ុន្មានដែល សុខ បានទទួលជាមធ្យមក្នុង១ថ្ងៃ ក្នុងរយ:ពេលមួយឆ្នាំមុន ។

ចំនួនទឹកប្រាក់គួរតែគិតដូចខាងក្រោមនេះ៖

*១១៦៨ ដុល្លារ (ប្រាក់ឈ្នួលនិងប្រាក់រង្វាន់សរុបក្នុងរយ:ពេល១២ខែមុន)*

= ________________________________________

*១២ (ខែក្នុង១ឆ្នាំ) x ២៦ (ថ្ងៃធ្វើការក្នុង១ខែ)*

= *៣.៧៣* ដុល្លារ (ចំនួនប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ)

និយោជករបស់ សុខ ត្រូវតែផ្ដល់អោយ សុខ ២២.៣៨ ដុល្លារ សំរាប់រយ:ពេល៦ថ្ងៃ ដែល សុខ សុំច្បាប់ឈប់ប្រចាំឆ្នាំនោះ (៣.៧៣ដុល្លារសំរាប់មួយថ្ងៃៗ ដែលគាត់ឈប់សំរាក) មុនពេលដែលគាត់ឈប់សំរាក ។

## ៧.២.៤ ការផ្ដល់ប្រាក់ឈ្នួលជំនួសអោយការឈប់សំរាក

ច្បាប់ស្ដីពីការងារមាត្រា ១៦៧ សេចក្ដីបង្គាប់អាជ្ញាកណ្ដាល ២៧/០៤ ១១២/១០(៨) និង

នៅពេលបញ្ចប់ការងារ និយោជកត្រូវតែផ្ដល់អោយកម្មករនិយោជិតនូវប្រាក់ឈ្នួលពេញចំពោះថ្ងៃសំរាកដែលនៅសេសសល់។ ការផ្ដល់ប្រាក់ឈ្នួលនេះត្រូវបានគិតដូចគ្នានឹងវិធីនៅក្នុងឧទាហរណ៍ខាងលើ ។

## ៧.២.៥ កិច្ចសន្យាព្រមព្រៀងបោះបង់ចោលការឈប់សំរាក

ច្បាប់ស្ដីពីការងារមាត្រា ១៦៧ សេចក្ដីបង្គាប់អាជ្ញាកណ្ដាល ២៧/០៤ ៩០/០៩(៨) និង

កិច្ចសន្យាព្រមព្រៀងណាដែលចែងថាកម្មករនិយោជិតសុខចិត្តបោះបង់សិទ្ធិឈប់សំរាកប្រចាំឆ្នាំ គឺជាកិច្ចព្រមព្រៀងដែលគ្មានសុពលភាព ។

ទោះបីជាកម្មករនិយោជិតនៅតាមរោងចក្រនានានៅក្នុងប្រទេសកម្ពុជា ជាទូទៅសុខចិត្តទទួលយកការបង់ប្រាក់ជំនួសអោយការឈប់សំរាកក៏ដោយ ក៏កិច្ចព្រមព្រៀងបែបនេះគ្មានសុពលភាពដែរ បើយោងតាមបកស្រាយដែលមានលក្ខណ:តឹងតែង។

### ៧.២.៦ ការពន្យារពេលការឈប់សំរាក

កម្មករនិយោជិតអាចយល់ព្រមពន្យាការឈប់សំរាកប្រចាំឆ្នាំ រហូតដល់ចុងបញ្ចប់នៃកិច្ចសន្យា។ ប៉ុន្តែនិយោជកមិនត្រូវអនុញ្ញាតអោយកម្មករនិយោជិតឈប់សំរាកតិចជាង ១២ថ្ងៃក្នុង១ឆ្នាំហើយ ថ្ងៃដែលនៅសល់ពីរយៈពេល ១២ថ្ងៃនេះមិនអាចត្រូវបានពន្យាអោយលើសពីរយៈពេល៣ឆ្នាំបន្តបន្ទាប់គ្នាបានឡើយ ។

ច្បាប់ស្តីពីការងារមាត្រា ១៦៧
សេចក្តីបង្គាប់អាជ្ញាកណ្តាល
២៧/០៤
៤០/០៩(៤) និង ៨៩/១២(៨)

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានយល់ឃើញថា នៅពេលដែលវាមិនមែនជាកំហុសរបស់កម្មករ និយោជិត ក្នុងការខកខានមិនបានឈប់សំរាករយៈពេលបីឆ្នាំដូចនិយាយខាងលើនេះមិនអាចយកអនុវត្តបានទេ ។ មានន័យថា នៅពេលបញ្ចប់កិច្ចសន្យា កម្មករនិយោជិតរូបនោះត្រូវតែទទួលបានជាទឹកប្រាក់សំរាប់ការឈប់សំរាកប្រចាំឆ្នាំទាំងអស់ដែលគេមិនបានប្រើប្រាស់ ។

## ៧.៣ ការឈប់សំរាកពិសេស

កម្មករនិយោជិតអាចឈប់សំរាកពិសេសរហូតដល់ ៧ថ្ងៃ ដោយមូលហេតុផ្ទាល់ខ្លួនដែលប៉ះពាល់ផ្ទាល់ដល់គ្រួសាររបស់គេ។ និយោជកមិនគួរបដិសេធដោយមិនសមហេតុផលលើការឈប់សំរាកពិសេសទេ ប្រសិនបើ:

ច្បាប់ស្តីពីការងារមាត្រា ១៧១
ប្រកាស ៧៦/៩៨ និង ២៦៧/០១
សេចក្តីបង្គាប់អាជ្ញាកណ្តាល
១៩៤/១២(៦)

- កម្មករនិយោជិត រៀបអាពាហ៍ពិពាហ៍
- ប្រពន្ធរបស់កម្មករនិយោជិតសំរាលកូន
- កូនរបស់និយោជិតរៀបអាពាហ៍ពិពាហ៍
- ប្តីប្រពន្ធកូន ឬ ឪពុកម្តាយរបស់កម្មករនិយោជិតស្លាប់ ឬ ឈឺ ។

ប្រសិនបើ កម្មករនិយោជិតមិនទាន់បានប្រើការឈប់សំរាកប្រចាំឆ្នាំរបស់គេ និយោជកអាចកាត់ការឈប់សំរាកពិសេសការឈប់សំរាកប្រចាំឆ្នាំដែលនៅក្នុងឆ្នាំនោះ ។ បើសិនជាកម្មករនិយោជិតពុំមានការឈប់សំរាកប្រចាំឆ្នាំ និយោជកអាចតំរូវអោយកម្មករនិយោជិតធ្វើការដើម្បីកាត់សងការឈប់សំរាកពិសេស ។ តែទោះជាយ៉ាងណាក៏នៅតែមានការដាក់កំហិតលើចំនុចនេះផងដែរ។ ឧទាហរណ៍ រយៈពេលធ្វើការសរុបមិនត្រូវបានអោយលើសពីរយៈពេល ១០ម៉ោងក្នុង មួយថ្ងៃ ឬ ៥៤ ម៉ោងក្នុងមួយអាទិត្យឡើយ ។

## ៧.៤ ការឈប់សំរាកឈឺ

កម្មករនិយោជិតម្នាក់ៗមានសិទ្ធិឈប់សំរាកឈឺ ។ និយោជក គួរតែដាក់បញ្ចូលការឈប់សំរាកឈឺមានប្រាក់ឈ្នួលនៅក្នុងបទបញ្ជាផ្ទៃក្នុង ។

ច្បាប់ស្តីពីការងារ មាត្រា ៧១ និង ៧២
សេចក្តីជូនដំណឹង ១៤/០២
សេចក្តីបង្គាប់អាជ្ញាកណ្តាល ២៦/០៣
៦៨/០៤ និង ១៥/១២(៣)

## ៧.៤.១ ការឈប់សំរាកឈឺដោយមានលិខិតបញ្ជាក់ពីគ្រូពេទ្យ

ច្បាប់ស្តីពីការងារមាត្រា ៧១
សេចក្តីបង្គាប់អាជ្ញាកណ្តាល ២៦/០៣ និង ១៥/១២(៣)

និយោជកត្រូវតែផ្តល់ការឈប់សំរាកឈឺទៅកម្មករនិយោករហូតដល់៦ខែ ប្រសិនបើកម្មករនិយោជិត:

- អវត្តមានពីការងារដោយសារជំងឺ និង
- មានលិខិតបញ្ជាក់ត្រឹមត្រូវពីគ្រូពេទ្យ ។

និយោជកអាចបញ្ចប់ការងារកម្មករនិយោជិតបាន ប្រសិនបើកម្មករនិយោជិតនោះឈប់សំរាកឈឺលើសពី៦ខែ ។

## ៧.៤.២ ការផ្តល់ប្រាក់ឈ្នួលក្នុងអំឡុងពេលឈប់សំរាកឈឺ

ឧបសម្ព័ន្ធនៃសេចក្តីជូនដំណឹង ១៤/០២
សេចក្តីបង្គាប់អាជ្ញាកណ្តាល២៦/០៣ ១៣/០៤ ៣០/០៤ ៦២/០៤ ៦៣/០៤ និង ៤២/១២(១)

ច្បាប់នេះមិនតម្រូវអោយផ្តល់ប្រាក់ឈ្នួលក្នុងពេលឈប់សំរាកឈឺទេ ប៉ុន្តែតាមគោលនយោបាយរបស់ក្រសួងទទួលបន្ទុកវិស័យការងារ និយោជកគួរពិចារណាផ្តល់ប្រាក់ឈ្នួលក្នុងពេលឈប់សំរាកឈឺដូចខាងក្រោម:

- ១០០% នៃប្រាក់ឈ្នួលក្នុងអំឡុងពេលឈប់សំរាកឈឺក្នុងខែទីមួយ
- ៦០% នៃប្រាក់ឈ្នួលក្នុងអំឡុងខែទី២ និងទី៣ និង
- ឈប់សំរាកដោយគ្មានប្រាក់ឈ្នួល ពីខែទី៤រហូតដល់ខែទី៦ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថាក្នុងករណីដែលកម្មករនិយោជិតត្រូវបានបញ្ជាក់ថាមានជំងឺដោយគ្រូពេទ្យដែលទទួលបានការអនុញ្ញាតនិងទទួលស្គាល់តាមច្បាប់ និយោជកត្រូវតែផ្តល់ជូនកម្មករនិយោជិតនូវប្រាក់រង្វាន់ការងារទៀងទាត់ចំនួន៥ដុល្លារ ដោយគិតទៅតាមសមាមាត្រនៃចំនួនថ្ងៃដែលធ្វើការប្រចាំខែនោះ ។

## ៧.៥ ការសំរាកលំហែមាតុភាព

រដ្ឋធម្មនុញ្ញ មាត្រា ៤៦
ច្បាប់ស្តីពីការងារ មាត្រា ១៨២-១៨៣
សេចក្តីបង្គាប់អាជ្ញាកណ្តាល២៤/០៣ ៤៩/០៤ ៨០/១០ ១១៥/០៨(១) ១៧២/១១(៧) ១១២/១១(១) ១៤៨/១២(២) និង ២៧/១២(១២)

និយោជកត្រូវតែផ្តល់អោយកម្មករនិយោជិតដែលសំរាលកូន នូវការឈប់សំរាកលំហែមាតុភាពចំនួន ៩០ថ្ងៃ (៣ខែ) ។

និយោជកមិនអាចបញ្ឈប់កម្មករនិយោជិត:

- ដោយសារមានផ្ទៃពោះ
- នៅពេលកំពុងឈប់លំហែមាតុភាព ឬ
- មុនពេលឈប់លំហែមាតុភាពបានឡើយ ។

និយោជកត្រូវតែអោយប្រាក់ឈ្នួលពាក់កណ្តាល និងអត្ថប្រយោជន៍ផ្សេងៗ ទៅកម្មករនិយោជិតដែលមានអតីតភាពការងារយ៉ាងតិចមួយឆ្នាំក្នុងអំឡុងពេលឈប់លំហែមាតុភាព ។ និយោជកគួរគិតប្រាក់ឈ្នួលដោយ

ផ្អែកតាមមូលដ្ឋានប្រាក់ឈ្នួលមធ្យមរបស់កម្មករនិយោជិតក្នុងអំឡុងពេល ១២ខែ មុនពេលសំរាកលំហែមាតុភាព មិនមែនផ្អែកតាមប្រាក់ឈ្នួលអប្បបរមា ឬ ប្រាក់ឈ្នួល គោលទេ ។

អំឡុងពេល២ខែដំបូង បន្ទាប់ពីត្រឡប់មកពីការឈប់លំហែមាតុភាព កម្មករនិយោជិតអាចត្រូវតម្រូវអោយធ្វើតែការងារស្រាលៗប៉ុណ្ណោះ ។

**ឧទាហរណ៍: ការឈប់លំហែមាតុភាព**

*សុខា* បានធ្វើការនៅរោងចក្រកាត់ដេរសំលៀកបំពាក់អស់រយៈពេល២ឆ្នាំ មុនពេលមានផ្ទៃពោះ ។ ប្រាក់ឈ្នួលគោលរបស់នាងគឺ ៨០ដុល្លារ ហើយប្រាក់រង្វាន់អតីតភាពការងារនាងគឺ ៣ដុល្លារ។ នាងបានមកធ្វើការយ៉ាងទៀងទាត់ ដូច្នេះនាងតែងតែទទួលប្រាក់រង្វាន់១០ដុល្លារ និង អត្ថប្រយោជន៍ផ្សេងៗទៀតប្រសិនបើមាន ។ ប្រាក់ឈ្នួល និង ផលប្រយោជន៍ទាំងអស់របស់នាងគឺ ស្មើនឹង ១២០០ដុល្លារ ក្នុងរយៈពេល១២ខែកន្លងមកនេះ ។

ដោយសារនាងបានធ្វើការលើសពី១ ឆ្នាំ *សុខា* មានសិទ្ធិទទួលបានការឈប់លំហែមាតុភាព ៩០ ថ្ងៃ និងប្រាក់ឈ្នួលពាក់កណ្តាល។ ចំនួនប្រាក់ឈ្នួលនេះត្រូវបានគិតដូចខាងក្រោមនេះ៖

$$= \frac{\text{១២០០ដុល្លារ (ចំនួនប្រាក់ឈ្នួល និងផលប្រយោជន៍សរុបរយៈពេល១២ខែកន្លងមក}}{\text{១២ ( ចំនួនខែនៅក្នុង១ឆ្នាំ)}}$$

*= ១០០ ដុល្លារ*

និយោជក ត្រូវ៧ បើកចំនួនទឹកប្រាក់ដែលរកបានប្រចាំខែ គុណនឹង៥០% = ៥០ដុល្លារ និងបើក ប្រាក់ឈ្នួលចំនួននេះអោយ *សុខា* រៀងរាល់ខែក្នុងអំឡុងពេលដែលនាងកំពុងឈប់លំហែមាតុ ភាព

## ៧.៦ ការសំរាកបំបៅកូន

ច្បាប់ស្តីពីការងារ មាត្រា ១៨៤-១៨៥
សេចក្តីបង្គាប់អាជ្ញាកណ្តាល
០៥/០៣
៩៤/០៤(១១) ០៨/០៧(៧)
៧៥/០៩(៤) និង ១៧/១០(១២)

រយៈពេលឆ្នាំទី១នៃជីវិតរបស់កូន ម្តាយមានសិទ្ធិទទួលបានប្រាក់ឈ្នួល ក្នុងពេលសំរាកបំបៅកូនក្នុងម៉ោងធ្វើការ។ ម្តាយអាចចែកការសំរាកនេះជា២វគ្គ ដែលមួយវគ្គៗអាចមានរយៈពេល៣០នាទី ( ឧទាហរណ៍ដូចជា ៣០នាទីក្នុងម៉ោងធ្វើការពេលព្រឹក និង៣០នាទីក្នុងម៉ោងធ្វើការពេលរសៀល ) ។ ពេលវេលាច្បាស់លាស់នៃការសំរាកបំបៅកូន គួរតែត្រូវបានព្រមព្រៀងរវាងម្តាយ និង និយោជករបស់នាង ។ ប្រសិនបើគ្មានការព្រមព្រៀងទេនោះ ការសំរាកនេះគួរតែត្រូវយកម៉ោងពាក់កណ្តាលពេលនៃរយៈពេលម៉ោងធ្វើការវេននីមួយៗ។ ច្បាប់មិនអនុញ្ញាតអោយមានការផ្តល់ទឹកដោះគោ ឬ ការបង់ប្រាក់ជំនួសអោយការសំរាកបំបៅកូនជាដាច់ខាត ។ ការសំរាកបំបៅកូន គឺជាការសំរាកបន្ថែមលើការសំរាកធម្មតាដែលកម្មករនិយោជិតបានទទួល។

ឯកសារយោង

## ៧.៧ បន្ទប់បំបៅកូន

និយោជកដែលជួលស្ត្រីធ្វើការយ៉ាងតិច ១០០នាក់ ត្រូវរៀបចំអោយមានបន្ទប់បំបៅកូន ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថាច្បាប់មិនអនុញ្ញាតឱ្យមានការផ្តល់ទឹកដោះគោ ឬ ការបង់ប្រាក់ជំនួសអោយការសំរាកបំបៅកូនទេ ។

ច្បាប់ស្តីពីការងារ មាត្រា ១៨៦
សេចក្តីបង្គាប់អាជ្ញាកណ្តាល
៦៣/០៤ ៦៨/០៤ ៥៦/១១(១) និង
៧៩(៤)

## ៧.៨ ទារកដ្ឋាន

និយោជកដែលជួលស្ត្រីអោយធ្វើការយ៉ាងតិច ១០០នាក់ ត្រូវរៀបចំអោយមានទារកដ្ឋានមួយ ។

បើសិនជានិយោជកពុំមានលទ្ធភាពរៀបចំទារកដ្ឋានសំរាប់ក្មេងដែលមានអាយុលើសពី១៨ខែបានទេ និយោជកនោះត្រូវតែចេញសោហ៊ុយទាំងនោះ ។

ច្បាប់ស្តីពីការងារ មាត្រា ១៨៦
សេចក្តីបង្គាប់អាជ្ញាកណ្តាល
៦៣/០៤
៥៦/១១(១) ០៤/១៦(៦) និង
៩៨/១២(៥)

# ផ្នែកទី៨ សុវត្ថិភាពការងារ និង សុខភាព

ឯកសារយោង

## ៨.១ លក្ខណៈទូទៅ

និយោជកត្រូវតែធានាអោយបានថាកន្លែងធ្វើការមានសុវត្ថិភាព សុខភាព និង អនាម័យ ។

ច្បាប់ស្តីពីការងារ មាត្រា ២៣ ២២៨-២៣០

## ៨.២ គិលានដ្ឋាន និង ការសង្គ្រោះបឋម

និយោជកដែលប្រើកម្មករនិយោជិតយ៉ាងតិច៥០នាក់នៅកន្លែងធ្វើការមួយត្រូវតែរៀបចំអោយមានគិលានុដ្ឋានមួយ។

ច្បាប់ស្តីពីការងារ មាត្រា ២៤២ ២៤៤
ប្រកាស ៣៣០/០០

### ៨.២.១ ទីកន្លែង និង ទំហំគិលានដ្ឋាន

គិលានដ្ឋាន ត្រូវតែនៅជិតកន្លែងធ្វើការ និង:

- ងាយចេញចូល
- ស្អាតបាត
- ឆ្ងាយពីសំលេងលាន់ខ្លាំង ធូលី និងសំរាម
- មានខ្យល់អាកាសល្អ
- យ៉ាងតិចមានទំហំ២០ម៉ែត្រការ៉េ និង
- ផ្តល់កន្លែងដាច់ដោយឡែកសំរាប់កម្មករនិយោជិតស្ត្រី។

ប្រកាស ៣៣០/០០ ប្រការ ២
សេចក្តីបង្គាប់អាជ្ញាកណ្តាល ០៣/០៣

### ៨.២.២ ចំនួន និង គុណសម្បត្តិរបស់កម្មករនិយោជិតសុខាភិបាល

ចំនួនបុគ្គលិក ដែលតម្រូវអោយមាននៅក្នុងគិលានដ្ឋាន គឺផ្អែកទៅលើចំនួនកម្មករនិយោជិត ដូចបានកំណត់នៅក្នុងតារាងខាងក្រោមៈ

ប្រកាស ៣៣០/០០ប្រការ ៣

សេចក្តីបង្គាប់អាជ្ញាកណ្តាល ៣៥/១១(៩) និង ២២៨/១២(៦)

| ចំនួនកម្មករនិយោជិត | ចំនួនគិលានុប្បដ្ឋាក ឬ គិលានុប្បដ្ឋាយិកា ដែលត្រូវប្រចាំការ | ចំនួនគ្រូពេទ្យ | ចំនួនម៉ោងរបស់ គ្រូពេទ្យ ក្នុងមួយវេន៨ ម៉ោង |
|---|---|---|---|
| ៥០-៣០០ | ១ | វេជ្ជបណ្ឌិត១ឬគ្រូពេទ្យមធ្យម១ | ២ម៉ោង |
| ៣០១-៦០០ | ១ | វេជ្ជបណ្ឌិត១ | ២ម៉ោង |
| ៦០១-៩០០ | ២ | វេជ្ជបណ្ឌិត១ | ៣ម៉ោង |
| ៩០១-១៥០០ | ២ | វេជ្ជបណ្ឌិត១ | ៤ម៉ោង |
| ១៥០១-២០០០ | ២ | វេជ្ជបណ្ឌិត១ | ៦ម៉ោង |
| ច្រើនជាង២០០០ | ៣ | វេជ្ជបណ្ឌិត១ | ៨ម៉ោង |

បុគ្គលិកនៅក្នុងគិលានដ្ឋានត្រូវមានវត្តមានក្នុងរយៈពេលម៉ោងការងារជាប់លាប់ និង ការងារ បន្ថែមម៉ោង ។

ឯកសារយោង

## ៨.២.៣ ពេទ្យការងារ

ច្បាប់ស្តីពីការងារ មាត្រា ២៣៩ និង២៤០
ប្រកាស ១៣៩០/០១

ច្បាប់ការងារផ្តល់ជូនពេទ្យការងារនូវតួនាទីយ៉ាងច្បាស់លាស់នៅក្នុងទីកន្លែងធ្វើការ។ ពេទ្យការងារត្រូវ:

- ផ្តល់ដំបូន្មានផ្នែកអនាម័យ និងសន្តិសុខការងារក្នុងកន្លែងការងារ
- រក្សាអាថិកំបាំងវិជ្ជាជីវៈ និង អាថិកំបាំងបច្ចេកទេសបែបផែនផលិតរបស់សហគ្រាស
- បង្កាសុខភាពកម្មករនិយោជិតអោយផុតពីគ្រោះថ្នាក់ការងារវិជ្ជាជីវៈ និង ជំងឺឆ្លងផ្សេងៗ
- ពិនិត្យព្យាបាលបឋមដល់កម្មករនិយោជិតដែលឈឺផ្សេងៗពេលបំពេញការងារមុនពេលបញ្ជូលទៅមន្ទីពេទ្យ ។

## ៨.២.៤ ឧបករណ៍ពេទ្យ និង ឳសថ

ប្រកាស ៣៣០/០០ប្រការ ៥
សេចក្តីបង្គាប់អាជ្ញាកណ្តាល ២២៥/១២(៦)

គិលានដ្ឋានត្រូវតែមាន:

- គុម្ពយ
- កៅអី៣
- ទូឯកសារ១
- ទូឳសថ
- យ៉ាងតិចគ្រែ២ ដោយមានពូក និងកំរាលពូក
- ឧបករណ៍សំលាប់មេរោគ និង
- ឳសថនិងឧបករណ៍ដែលចាំបាច់ផ្សេងៗទៀត ។

### ៨.២.៥ ចំនួនគ្រែអ្នកជំងឺ

ប្រកាស ៣៣០/០០ប្រការ ១ ប្រការ៤ និងប្រការ ៥

និយោជកដែលប្រើកម្មករនិយោជិតលើសពី៥០នាក់ នៅកន្លែងធ្វើការត្រូវមានគ្រែអ្នកជំងឺនៅក្នុង ឬ នៅជិតគិលានដ្ឋាន។ ចំនួនគ្រែត្រូវតែមានចំនួនស្មើនឹង ២% នៃចំនួនកម្មករនិយោជិត រហូតដល់មានចំនួនអតិបរមា ២០គ្រែ។

| ចំនួនបង្គន់អនាម័យ | គ្រែ |
|---|---|
| ៥០-២០០ | ២ |
| ៥០០ | ១០ |
| ច្រើនជាង១០០០ | ២០ |

## ៨.៣ បង្គន់បង្គន់អនាម័យ

ប្រកាស ០៥២/០០
សេចក្តីបង្គាប់អាជ្ញាកណ្តាល ៣១/១២(៦) និង ៣៤/១២(៤)

និយោជកត្រូវតែផ្តល់បង្គន់អនាម័យដែលស្អាតបាតដល់កម្មករនិយោជិត ។

### ៨.៣.១ ចំនួនបង្គន់អនាម័យ

និយោជកត្រូវផ្តល់បង្គន់អនាម័យដោយឡែកពីគ្នារវាងកម្មករនិយោជិតប្រុស និងកម្មករនិយោជិតស្រី ដោយយោងតាមចំនួនដូចខាងក្រោមនេះ៖

| ចំនួនកម្មករនិយោជិត (ប្រុស ឬ ស្រី) | ចំនួនបង្គន់អនាម័យ |
|---|---|
| ១-១៥ | ១ |
| ១៦-៣៥ | ២ |
| ៣៦-៥៥ | ៣ |
| ៥៦-៨០ | ៤ |
| ៨១-១១០ | ៥ |
| ១១១-១៥០ | ៦ |
| ១៥១-១០០០ | បន្ថែម១សំរាប់មនុស្ស៥០នាក់ |
| លើសពី១០០០នាក់ | បន្ថែម១សំរាប់មនុស្ស៧០នាក់ |

### ៨.៣.២ លក្ខខណ្ឌតម្រូវសំរាប់បង្គន់អនាម័យ

បង្គន់អនាម័យនីមួយៗត្រូវតែ:

- មានកំរាលក្រោម និង ជញ្ជាំងមិនជ្រាបទឹក
- មានទ្វារដែលបិទដោយមានគន្លឹះខ្ទាស់ពីក្នុង
- មានជញ្ជាំងដែលលាបពណ៌ស្រាលៗ
- មានពន្លឺគ្រាប់គ្រាន់
- នៅក្នុងកន្លែងធ្វើការ ឬ មានតាក តភ្ជាប់ទៅកន្លែងធ្វើការ
- មានសាប៊ូ និង ទឹកគ្រប់គ្រាន់
- សំអាតយ៉ាងតិច១ដងក្នុង១ថ្ងៃ និង
- មានប្រព័ន្ធផ្លូវទឹកយ៉ាងសមស្រប ។

### ៨.៣.៣ បង្គន់អនាម័យសំរាប់កម្មករនិយោជិតស្ត្រី

សហគ្រាសណាមួយដែលមានកម្មករនិយោជិតស្ត្រីយ៉ាងតិច១០០នាក់ ត្រូវតែមានបង្គន់អង្គុយផ្ទាល់មួយ សំរាប់រៀងរាល់ស្ត្រី៥០នាក់ ។

## ៨.៤ ទឹកផឹក

និយោជកត្រូវតែផ្តល់ទឹកផឹកមានសុវត្ថិភាពអោយបានគ្រប់គ្រាន់ដល់កម្មករនិយោជិត ដែលធ្វើការនៅក្នុងសហគ្រាស ។

ប្រកាស០៥៤/០០
សេចក្តីបង្គាប់អាជ្ញាកណ្តាល
១៤៣/០៩(២) ៧២/១០(៤) និង

### ៨.៤.១ ល័ក្ខខ័ណ្ឌតម្រូវសំរាប់ទឹកផឹកស្អាតដែលមានសុវត្ថិភាព

ទឹកផឹកត្រូវតែដាក់នៅក្នុងធុងស្អាតដែលមានគំរបបិទជិត និង មានចំពួយបង្ហូរទឹកមួយពីខាងក្រោម ។ និយោជកត្រូវតែផ្តល់ពែង ដែលមានអនាម័យសំរាប់ផឹកទឹក ។

### ៨.៤.២ កន្លែងដាក់ទឹក

ធុងទឹកត្រូវតែនៅជិតកន្លែងធ្វើការរបស់កម្មករនិយោជិត ។

### ៨.៤.៣ គ្រឿងស្រវឹង

គ្មាននរណាម្នាក់អាចនាំយកគ្រឿងស្រវឹងទៅក្នុងកន្លែងធ្វើការ ឬ ផ្តល់គ្រឿងស្រវឹងទៅកម្មករនិយោជិតក្នុងម៉ោងធ្វើការបានទេ ។

## ៨.៥ កន្លែងអង្គុយ

ប្រកាស០៥៣/០០

និយោជកត្រូវតែផ្តល់កៅអីដែលសមរម្យនៅក្នុងកន្លែងធ្វើការនីមួយៗសំរាប់អោយកម្មករនិយោជិតប្រើប្រាស់។

### ៨.៥.១ ចំនួនកៅអីនៅក្បែរកន្លែងធ្វើការ

ទោះជាការងារមិនអាចធ្វើដោយអង្គុយបានក៏ដោយ និយោជកត្រូវតែមានកៅអីនៅជិតកន្លែងធ្វើការសំរាប់កម្មករនិយោជិតប្រើប្រាស់នៅពេលដែលពួកគេត្រូវការ ។

### ៨.៥.២ បទបញ្ជាផ្ទៃក្នុង

វិធានទាំងឡាយស្តីពីការប្រើកៅអីអាចសរសេរបញ្ចូលនៅក្នុងបទបញ្ជាផ្ទៃក្នុងបាន ។

## ៨.៦ សំលេង

អនុក្រឹត្យ ៩២/០០
ប្រកាស១៣៨/០៣

កំរិតសំលេងអតិបរមានៅក្នុងកន្លែងធ្វើការមានកំណត់នៅក្នុងអនុក្រិត ៩២/០០ ដូចខាងក្រោមនេះ៖

| កំរិតសំលេង ( dB (A) ) | រយៈពេលអតិបរមា (ម៉ោង) |
|---|---|
| ៧៥ | ៣២ |
| ៨០ | ១៦ |
| ៨៥ | ៨ |
| ៩០ | ៤ |
| ៩៥ | ២ |
| ១០០ | ១ |
| ១០៥ | ០.៥ |
| ១១០ | ០.២៥ |
| ១១៥ | ០.១២៥ |

យោងទៅតាមអនុក្រឹត្យលេខ ៩២/០០ និយោជកត្រូវតែផ្តល់នូវការការពារសំលេងខ្លាំង ទៅកម្មករនិយោជិតដែលធ្វើការ នៅក្នុងកំរិតសំលេងលើសពី ៨០ dB (A) ។ ដោយយោងទៅតាមប្រកាស ១៣៨/០៣ កំរិតសំលេងគឺ ៨៥ dB(A) ។

## ៨.៧ ខ្យល់អាកាស កំដៅ និង ការធ្វើអោយមានខ្យល់ចេញចូល

អនុក្រឹត្យ ៥២/០០
ប្រកាស ១២៥/០១ និង១៤៧/០២

### ៨.៧.១ ខ្យល់អាកាស

អនុក្រឹត្យ ៥២ / ០០

អនុក្រិត ៥២/០០ ចែងអំពីកំរិតជាតិគីមីអតិបរមានៅក្នុងលំហអាកាស។

### ៨.៧.២ កំដៅ និង ការធ្វើអោយមានខ្យល់ចេញចូល

ប្រកាស ១២៥/០១ និង ១៤៧/០២
សេចក្តីបង្គាប់អាជ្ញាកណ្តាល ៨៦/១១(១០)

និយោជកត្រូវតែធានាថាសីតុណ្ហភាពនៅក្នុងកន្លែងធ្វើការគឺសមស្របសំរាប់កម្មករនិយោជិត។ នៅរោងចក្រ ឬ រោងជាងត្រូវមានលំហអាកាសយ៉ាងតិច ១០មព សំរាប់កម្មករនិយោជិតគ្រប់គ្នា។ និយោជកត្រូវតែមាន ទែម៉ូម៉ែត (ឧបករណ៍វាស់សីតុណ្ហភាព) នៅក្នុងកន្លែងធ្វើការដើម្បីតាមដានសីតុណ្ហភាព ។

### ៨.៧.៣ ការធ្វើការក្នុងតំបន់ដែលខ្យល់ចេញចូលមានកំរិត

ប្រកាស១៣៩/០៣

ក្នុងករណីកម្មករនិយោជិតត្រូវតែធ្វើការនៅក្នុងកន្លែងដែលខ្យល់ចេញចូលមានកំរិត (ដូចជាក្នុងរូងភ្នំ ក្រោមដី ឬ ក្នុងបំពុងស៊ីឡាំងធំ) និយោជកត្រូវតែធានាថា កម្មករនិយោជិតអាចទទួលបានខ្យល់បរិសុទ្ធយ៉ាងតិច ៣០មព ចំពោះកម្មករនិយោជិតម្នាក់ៗ ក្នុង១ម៉ោង។

## ៨.៨ ពន្លឺ

ប្រកាស៤៨៤/០៣

និយោជកត្រូវតែធានាថា មានពន្លឺធម្មជាតិ ឬ ពន្លឺសិប្បនិម្មិត គ្រប់គ្រាន់នៅក្នុងកន្លែងធ្វើការ ដើម្បីអោយកម្មករនិយោជិតអាចមើលឃើញច្បាស់ ដោយគ្មានការលំបាកចំពោះភ្នែករបស់ពួកគេ ។ ប្រកាស ៤៨៤/០៣ កំណត់ពីកំរិតពន្លឺ (គិតជាលុច (Lux)) សំរាប់ប្រភេទផ្សេងៗគ្នានៃកន្លែងធ្វើការ ។

## ៨.៩ ការលើកដាក់ទម្ងន់ដោយកំលាំងពលកម្ម

ច្បាប់ស្តីពីការងារ មាត្រា ២៣០
ប្រកាស ១៣៩/០៣
សេចក្តីបង្គាប់អាជ្ញាកណ្តាល ៨៦/១១(៩)

និយោជកត្រូវចៀសវាងកុំអោយមានការលើកដាក់ដោយកំលាំងពលកម្មដែលអាចបណ្តាលអោយមានគ្រោះថ្នាក់ដល់សុខភាពកម្មករនិយោជិត ពិសេសបើសិនជាការងារនោះអាចបង្កគ្រោះថ្នាក់ដល់ឆ្អឹងខ្នងរបស់ពួកគេ ។

### ៨.៩.១ ស្ត្រីមានផ្ទៃពោះ

ស្ត្រីមានផ្ទៃពោះ ស្ត្រីដែលទើបតែសំរាលកូនរួច រលូតកូន ឬ រំលូតកូនរួច ក្នុងរយៈពេល២ខែដំបូងមិនត្រូវលើកដាក់ទំងន់លើសពី ៥ គ.ក្រ ទេ ។

## ៨.៩.២ ទំនន់អតិបរមា

កម្មករនិយោជិតអាចលើកដាក់ទំងន់ធ្ងន់អតិបរមាដូចមានរៀបរាប់ក្នុងតារាងក្រោមនេះ ៗ

| | ប្រុស | | ស្ត្រី | |
|---|---|---|---|---|
| | ១៥ឆ្នាំ↗ | ១៨ឆ្នាំ↗ | ១៥ឆ្នាំ↗ | ១៨ឆ្នាំ↗ |
| លើកដាក់ទំងន់ផ្ទាល់ | ១២ គ.ក្រ | ៥០គ.ក្រ | ៦ គ.ក្រ | ២៥ គ.ក្រ |
| រទេះរុញកង់មួយ | ៣២ គ.ក្រ | ៨០គ.ក្រ | ហាម | ៤០ គ.ក្រ |
| រទេះរុញកង់បី ឬបួន | ៤៨ គ.ក្រ | ១២០គ.ក្រ | ២៤ គ.ក្រ | ៦០ គ.ក្រ |

## ៨.១០ ឧទាហរណ៍អំពីវិធានការដាក់លាក់ពាក់ព័ន្ធទៅនឹងសុខភាព និង សុវត្ថិភាព

ដើម្បីធ្វើអោយសុខភាព និង សុវត្ថិភាព មានភាពកាន់តែល្អប្រសើរឡើង និង ដើម្បីការពារគ្រោះថ្នាក់ការងារ និយោជកគួរតែចាត់វិធានការដាក់លាក់ដូចជា:

*លំហអាកាស*

- ដំឡើង និង ថែរក្សាប្រព័ន្ធខ្យល់ចេញចូលនិងបន្ថយកំដៅ
- វាស់ស្ទង់សីតុណ្ហភាពជាប្រចាំ
- ធ្វើការកាត់បន្ថយធូលី

*អាហារដ្ឋាន*

- រក្សាបរិមាណទទួលទានអាហាររួមទាំងកំរាលឥដ្ឋ ចង្រ្កាន កន្លែងបំរើការ និង ជុំវិញឪ្យ បានស្អាត និង មានអនាម័យ
- ធានាថា អាហារត្រូវបានរៀបចំ និង ចំអិនត្រឹមត្រូវ
- ធានាថា អាហារមានគុណភាព និង តម្លៃសមរម្យ

*សារធាតុគីមី*

- ស្តុបសារធាតុគីមីនៅក្នុងកន្លែងបិទជិតដោយឡែកពីកន្លែងធ្វើការ
- ធុងដាក់សារធាតុគីមីត្រូវមានបិទផ្លាកសញ្ញាអោយបានច្បាស់ជាភាសាខ្មែរ (និងភាសាដទៃទៀតដែលពាក់ព័ន្ធ)
- ដំឡើងឧបករណ៍ធ្វើអោយមានខ្យល់អាកាសចេញចូលក្នុងរោងចក្រនៅកន្លែងដែលមានប្រើសារធាតុគីមី
- ចែកកន្លែងដែលប្រើសារធាតុគីមីនៅក្នុងរោងចក្រឱ្យដាច់ដោយឡែកពីកន្លែងធ្វើការ
- ហ្វឹកហ្វឺនកម្មករនិយោជិតពីរបៀបធ្វើការជាមួយសារធាតុគីមី
- ផ្តល់អោយកម្មករនិយោជិតនូវសំលៀកបំពាក់ការពារ ( ដូចជាស្រោមអនាម័យ ) និង ឧបករណ៍( ដូចជាវ៉ែនតា ឬ ម៉ាស់ពាក់មុខ )

ការហ្វឹកហ្វឺន

- ហ្វឹកហ្វឺនពីការគេចភាពអាសន្នអោយបានទៀងទាត់

*ច្រកទ្វារចេញពេលមានអាសន្ន*

- ដំឡើង និង ដាក់សញ្ញាច្រកចេញ
- រក្សាច្រកទ្វារនោះអោយងាយស្រួលក្នុងការប្រើប្រាស់ និង មិនចាក់សោរ

*បំពង់ពន្លត់អគ្គិភ័យ*

- ដំឡើងបំពង់ពន្លត់អគ្គីភ័យអោយបានគ្រប់គ្រាន់ និង ធានាអោយបានថាបំពង់ទាំងនោះ ងាយស្រួលនឹងយកប្រើប្រាស់
- សាកល្បងបំពង់ពន្លត់អគ្គីភ័យជាទៀងទាត់។

*សង្គ្រោះបឋម*

- ផ្តល់អោយមានប្រអប់ដាក់ថ្នាំព្យាបាលបឋមអោយគ្រប់គ្រាន់ និង ធ្វើអោយប្រាកដថា កម្មករនិយោជិតមានភាពងាយស្រួលក្នុងការយកមកប្រើប្រាស់ ។
- ពិនិត្យមើលរបស់របរនៅក្នុងប្រអប់ដាក់ថ្នាំព្យាបាលបឋមអោយបានទៀងទាត់ ។

*ម៉ាស៊ីន*

- ដំឡើងម៉ាស៊ីននៅមានសុវត្ថិភាព និង ថែទាំអោយបានល្អ
- ដាក់អោយមានរបាំងការពារម្ហូលសំរាប់ម៉ាស៊ីនដេរ
- ដំឡើង និង ថែទាំប្រព័ន្ធ និង ខ្សែអគ្គីសនីអោយមានសុវត្ថិភាព
- បិទផ្លាកសញ្ញាសុវត្ថិភាពនៅពីលើប្រអប់បិទ/បើកអគ្គិសនី។

*សំលេង*

- វាស់ស្ទង់កំរិតសំលេង
- ផ្តល់ប្រដាប់ការពារសំលេងទៅកម្មករនិយោជិត ដែលធ្វើការនៅកន្លែងធ្វើការដែលមាន សំលេងខ្លាំង

*អនាម័យ*

- ជួសជុលបង្គន់អនាម័យ និង ទ្វារបង្គន់អនាម័យដែលខូច
- ដាក់ផ្លាកសញ្ញាសំរាប់បុរសនិងស្ត្រីនៅទ្វារបង្គន់អនាម័យ
- ផ្តល់ប្រដាប់ប្រដាសំរាប់លាងសំអាតនៅជិតបង្គន់អនាម័យ

*ផ្លូវដើរ*

- ដាក់ផ្លាកសញ្ញាផ្លូវដើរអោយច្បាស់ និង រក្សាផ្លូវដើរទាំងនោះកុំអោយមានវត្ថុ និង សំរាមនៅទើសទែង ។

# ផ្នែកទី៩ គ្រោះថ្នាក់ការងារ និង ជំងឺវិជ្ជាជីវៈ

ឯកសារយោង

## ៩.១ តើអ្វីជាគ្រោះថ្នាក់ការងារ?

ច្បាប់ស្តីពីការងារ មាត្រា ២៤៨ និង ២៥៧
ប្រកាស ២៤៣/០២
សេចក្តីបង្គាប់អាជ្ញាកណ្តាល ១០១/០៨ (១ និង ២) និង ១០០/០៩(១)

គ្រោះថ្នាក់ ឬ ជំងឺដែលចាត់ទុកថាទាក់ទងនឹងការងារ គឺជាគ្រោះថ្នាក់ឬ ជំងឺដែលកើតឡើងចំពោះកម្មករនិយោជិត:

- ដោយសារធ្វើការ
- ក្នុងម៉ោងធ្វើការ ឬ
- ពេលពួកគេកំពុងធ្វើដំណើរដោយត្រង់ពីផ្ទះទៅធ្វើការ ឬ ពីកន្លែងធ្វើការទៅផ្ទះ

គ្រោះថ្នាក់អាចចាត់ទុកថាទាក់ទងនឹងការងារ ទោះបីវាជាកំហុសរបស់អ្នកណាក៏ដោយ ។

ជំងឺវិជ្ជាជីវៈក៏ចាត់ទុកថា ជាគ្រោះថ្នាក់ការងារដែរ ។

## ៩.២ ការទទួលខុសត្រូវរបស់និយោជកក្នុងការទប់ស្កាត់មិនឱ្យមានគ្រោះថ្នាក់ការងារ

ច្បាប់ស្តីពីការងារ មាត្រា ២២៩-២៣០ និង ២៥០
សេចក្តីបង្គាប់អាជ្ញាកណ្តាល ៩៦/១០(៩)

និយោជកត្រូវតែទទួលខុសត្រូវឬចាត់អោយអ្នកមានអ្នកទទួលខុសត្រូវ ក្នុងការការពារមិនអោយមានគ្រោះថ្នាក់ការងារកើតឡើង។

## ៩.៣ ភារកិច្ចរបស់និយោជកបន្ទាប់ពីគ្រោះថ្នាក់ការងារកើតឡើង

ប្រកាស២៤៣/០២

ពេលដែលកម្មករនិយោជិតមានគ្រោះថ្នាក់និយោជកត្រូវតែ:

- ផ្តល់ការសង្គ្រោះបឋម
- រក្សាទិដ្ឋភាពនៃកន្លែងកើតហេតុ
- ផ្តល់ឯកសារពាក់ព័ន្ធទៅគណៈកម្មការអង្កេតគ្រោះថ្នាក់ការងារ
- អនុញ្ញាតអោយសាក្សីរាយការណ៍ជូនទៅគណៈកម្មការអង្កេតគ្រោះថ្នាក់ការងារ
- ចេញថ្លៃចំណាយសំរាប់ការងារស្រាវជ្រាវពីគ្រោះថ្នាក់នោះ និង សំរាប់ការវិភាគបច្ចេកទេស ហើយនិង
- ចាត់វិធានការការពារគ្រោះថ្នាក់ប្រហាក់ប្រហែលគ្នានេះ មិនអោយកើតឡើងសារជាថ្មីម្តងទៀតនាពេលអនាគត។

## ៩.៤ ការជូនដំណឹងអំពីគ្រោះថ្នាក់ការងារ

ប្រកាស២៤៣/០២

និយោជក ត្រូវតែជូនដំណឹងទៅក្រសួងទទួលបន្ទុកវិស័យការងារជាលាយលក្ខណ៍អក្សរ ពីគ្រោះថ្នាក់ការងារមិនអោយលើសពី ៤៨ម៉ោង បន្ទាប់ពីគ្រោះថ្នាក់កើតឡើង ។

## ៩.៥ ការប៉ះប៉ូវសងចំពោះគ្រោះថ្នាក់ការងារ

ច្បាប់ស្តីពីការងារ មាត្រា ២៥២-២៥៥
ប្រកាស ២៤៣/០២
សេចក្តីបង្គាប់អាជ្ញាកណ្តាល
៩៦/១០(១០) និង ៣១/១២(១៣)

និយោជក ត្រូវចេញថ្លៃចំណាយលើការព្យាបាល និង ការថែទាំសុខភាពរបស់កម្មករនិយោជិតដែលទទួលគ្រោះថ្នាក់ការងារ។

និយោជកត្រូវប៉ះប៉ូវសងទៅកម្មករនិយោជិតដែលបាត់បង់សមត្ថភាពការងារមួយរយៈ ឬ ជាអចិន្ត្រៃយ៍ ឬ ស្លាប់ដោយសារគ្រោះថ្នាក់ការងារ។

ចំពោះកម្មករនិយោជិតណាដែលធ្វើអោយមានគ្រោះថ្នាក់ដោយចេតនា ពុំមានសិទ្ធិទទួលបានការប៉ះប៉ូវ ។

### ៩.៥.១ ការចំណាយលើការព្យាបាល

ច្បាប់ស្តីពីការងារ មាត្រា ២៥៤
ប្រកាស ២៤៣/០២
សេចក្តីបង្គាប់អាជ្ញាកណ្តាល
២៣/០៧(២)

និយោជក ត្រូវចេញថ្លៃចំពោះថ្លៃចំណាយលើការព្យាបាលសំខាន់ៗ របស់កម្មករនិយោជិតដែលទទួលរងគ្រោះថ្នាក់ការងាររួមទាំងថ្លៃឪសថ ថ្លៃព្យាបាល និង ការចំណាយលើមន្ទីរពេទ្យ ការធ្វើ អវៈយវៈ សិប្បនិម្មិត និង ការផ្តល់ជំនួយសំរាប់ហ្វឹកហ្វឺនវិជ្ជាជីវៈឡើងវិញ ។

### ៩.៥.២ ការបាត់បង់សមត្ថភាពការងារមួយរយៈ

ច្បាប់ស្តីពីការងារ មាត្រា ២៥៤
ប្រកាស ២៤៣/០២ ប្រការ ៨
សេចក្តីបង្គាប់អាជ្ញាកណ្តាល
៣១/១២(១៣)

កម្មករនិយោជិតដែលបាត់បង់សមត្ថភាពការងារមួយរយៈដោយសារគ្រោះថ្នាក់ការងារមានសិទ្ធិ:

- ទទួលប្រាក់ឈ្នួលធម្មតាសំរាប់ថ្ងៃដែលមិនបានធ្វើការ ( កាលណា ការបាត់បង់សមត្ថភាពនោះមានរយៈ ពេលយ៉ាងយូរបំផុតត្រឹម ៤ថ្ងៃ ឬ តិចជាង ) និង
- ទទួលប្រាក់ឧបត្ថម្ភ ( ស្មើនឹងប្រាក់ឈ្នួលប្រចាំថ្ងៃ ) ពីថ្ងៃទី៥ រហូតដល់ពេលដែលកម្មករនិយោជិតលិខិតបញ្ជាក់ថាអាចធ្វើការឡើងវិញ ដែលចេញដោយគ្រូពេទ្យជាផ្លូវការ ដែលទទួលស្គាល់ដោយក្រសួងទទួលបន្ទុកវិស័យការងារ ( បើកាលណា ការបាត់បង់សមត្ថភាពមានរយៈពេល៥ថ្ងៃនៃថ្ងៃធ្វើការ ឬ ច្រើនជាងនេះ ) ។

ប្រាក់ឈ្នួលប្រចាំថ្ងៃ ត្រូវគិតដោយផ្អែកលើមូលដ្ឋាននៃប្រាក់ឈ្នួលប្រចាំថ្ងៃជាមធ្យមរបស់កម្មករ និយោជិតក្នុងខែមុនពេលទទួលរងរបួស (រួមទាំងប្រាក់បន្ថែមម៉ោង និង ប្រាក់រង្វាន់ផ្សេងៗទៀត)

វិធានខាងលើ ក៏អាចអនុវត្តចំពោះកម្មករនិយោជិតដែលបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ផងដែរ ប៉ុន្តែតែចំពោះអ្នកដែលអសមត្ថភាពមានអត្រាតិចតួចជាង ២០% ។

## ៩.៥.៣ ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍

ច្បាប់ស្តីពីការងារ មាត្រា ២៥៣
ប្រកាស ២៤៣/០២ ប្រការ ៩

កាលណាគ្រោះថ្នាក់ការងារបណ្តាលអោយបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ កម្មករនិយោជិត ត្រូវតែមានវេជ្ជបណ្ឌិតវាយតម្លៃលើភាគរយនៃអសមត្ថភាពរបស់គេ ។ ប្រសិនបើអសមត្ថភាពត្រូវបានកំរិតថា ២០% ឬច្រើនជាងនេះកម្មករនិយោជិតមានសិទ្ធទទួលបានប្រាក់បំណាច់ឆ្នាំ ជាសំណងជំងឺចិត្ត ។ សំណងជំងឺចិត្តត្រូវបានគិតដូចខាងក្រោម:

អត្រាបាត់បង់សមត្ថភាព ៥០%

- *១/២ x [(ប្រាក់ឈ្នួលជាក់ស្តែងប្រចាំឆ្នាំ) x (%អសមត្ថភាព)]*

អត្រាបាត់បង់សមត្ថភាពលើសពី ៥០%

- *(ប្រាក់ឈ្នួលរកបានជាក់ស្តែងប្រចាំឆ្នាំ) x [(២៥%)+(១.៥x(%អសម្ថភាព - ៥០%))]*

កាលណាគ្រោះថ្នាក់បណ្តាលអោយបាត់បង់សមត្ថភាពដែលតម្រូវអោយមានការថែទាំជាប្រចាំពីជនដទៃ ការប៉ះប៉ូវត្រូវបន្ថែម ៥០% ទៀត ។

**ឧទាហរណ៍: សំណង់ចំពោះការរងរបួសក្នុងការងារ**

*សុខ* ទទួលរងរបួសដោយសារម៉ាស៊ីនកាត់នៅរោងចក្រកាត់ដេរសំលៀកបំពាក់ដែលគាត់ធ្វើការ ។ ជាលទ្ធផលវាធ្វើអោយភ្នែកម្ខាងរបស់គាត់មើលលែងឃើញ។ វេជ្ជបណ្ឌិតបញ្ជាក់ថា គាត់ពិការភ្នែកជាអចិន្ត្រៃយ៍ ៣០% ។

គាត់បានទទួលប្រាក់ឈ្នួលអប្បបរមា ៨០ ដុល្លារក្នុង ១ខែ។ ប៉ុន្តែគាត់ធ្វើការបន្ថែមម៉ោងយ៉ាងច្រើន និងតែងតែទៅធ្វើការយ៉ាងទៀងទាត់ ដោយរួមទាំងប្រាក់រង្វាន់ និង ម៉ោងបន្ថែមគាត់បានទទួលសរុប ១៣៥៣.៦០ដុល្លារក្នុងរយៈពេល ១២ខែ មុនគាត់ទទួលរងរបួស ។

*សុខ*មានសិទ្ធទទួលបានសំណង់ដូចខាងក្រោមនេះ៖

*១/២ X[(ប្រាក់ដែលរកបានជាក់ស្តែងប្រចាំឆ្នាំ ១៣៥៣.៦០ដុល្លារ)X(%បាត់បង់សមត្ថភាពការងារ ៣០%)]*

= ២០៣.*០៤ ដុល្លារ ក្នុង១ឆ្នាំ*

## ៩.៥.៤ គ្រោះថ្នាក់ការងារបណ្តាលអោយស្លាប់

ច្បាប់ស្តីពីការងារ មាត្រា ២៥៣
ប្រកាស២៤៣/០២ ប្រការ ១១

ប្រសិនបើកម្មករនិយោជិតម្នាក់ស្លាប់ដោយសារគ្រោះថ្នាក់ការងារ និយោជកត្រូវចេញថ្លៃចំណាយលើពិធីបុណ្យសព និង ប្រាក់ឧបត្ថមប្រចាំឆ្នាំ ( ប្រាក់បំណាច់ប្រចាំឆ្នាំ ) ទៅគ្រួសាររបស់កម្មករនិយោជិតដែលស្លាប់នោះ។ ចំនួនទឹកប្រាក់ដែលបង់សំរាប់ពិធីបុណ្យសពត្រូវតែយ៉ាងហោចណាស់ស្មើនឹង ៩០ដង នៃចំនួនប្រាក់ឈ្នួលប្រចាំថ្ងៃជាមធ្យម ឬ ស្មើនឹងប្រាក់ឈ្នួលរបស់កម្មករនិយោជិតនោះចំនួនបីខែ។ ចំនួនប្រាក់បំណាច់ប្រចាំឆ្នាំ គឺផ្អែកលើភាគរយនៃប្រាក់ឈ្នួលគោលប្រចាំឆ្នាំរបស់កម្មករនិយោជិតនោះ ។

សមាជិកគ្រួសារត្រូវតែទទួលបានសំណង់ជំងឺចិត្តដូចកំណត់នៅក្នុងតារាងខាងក្រោមនេះ៖

| សមាជិកនៅក្នុងបន្ទុក | ផលប្រយោជន៍ជាភាគរយៈ | សរុប |
|---|---|---|
| ប្តី/ប្រពន្ធ | ៣០% | ៣០% |
| កូនទី១ | ១៥% | ៤៥% |
| កូនទី២ | ១៥% | ៦០% |
| កូនទី៣ បន្តបន្ទាប់ | ១០% | ៧០%-៨៥%** |

**ប្រាក់បំណាច់ប្រចាំឆ្នាំសរុបមិនអាចលើសពី ៨៥% នៃប្រាក់ឈ្នួលឆ្នាំបានទេ ។

ចំពោះកុមារ ប្រាក់បំណាច់ប្រចាំឆ្នាំនេះ ជាទូទៅអនុវត្តបានតែពេលគេមានអាយុ ១៦ឆ្នាំ ឬ ក្មេងជាងហ្នឹក ហើយមិនទាន់រៀបការ[១] ។

## ៩.៥.៥ ចំនួនប្រាក់បំណាច់ប្រចាំឆ្នាំសំរាប់ការស្លាប់ និងបាត់បង់សមត្ថភាពជាអចិន្ត្រៃយ៍

ប្រកាស២៤៣/០២

ក្នុងករណីស្លាប់ ឬ បាត់បង់សមត្ថភាពជាអចិន្ត្រៃយ៍ ភាគីអាចព្រមព្រៀងគ្នាចំពោះការបើកប្រាក់សរុបទាំងអស់ជំនួសអោយការបើកប្រាក់បំណាច់ប្រចាំឆ្នាំបាន ។

[១]មានករណីលើកលែងចំពោះកុមារដែលបន្តការហ្វឹកហាត់ការងារ ( រហូតដល់អាយុ ១៨ឆ្នាំ ) និងបន្តការសិក្សារហូតដល់អាយុ ២២ឆ្នាំ)

**ឧទាហរណ៍: ប្រាក់ប្រចាំឆ្នាំចំពោះករណីស្លាប់**

សន្មតថា *សុខ* ( ពីឧទាហរណ៍ខាងលើ ) បានស្លាប់ដោយសាររបួសរបស់គាត់។ អ្នកនៅក្រោម បន្ទុករបស់គាត់ គឺ ប្រពន្ធ និង កូននៅក្មេងៗ ២នាក់ ។

ក្រៅពីការចំណាយលើបុណ្យសព ប្រពន្ធ *សុខ* អាចមានសិទ្ធទទួលបានប្រាក់បំណាច់ប្រចាំឆ្នាំ ដូចខាងក្រោមនេះ៖ *[( ប្រាក់ឈ្នួលទទួលបានជាក់ស្តែងប្រចាំឆ្នាំ ១៣៥៣.៦០ដុល្លារ ) x ( ៣០% + ១៥% +១៥% )]*

*= ៦០៩.១២ ដុល្លារក្នុងមួយឆ្នាំ ។*

# ផ្នែកទី១០ ការដាក់វិន័យ និង ការបញ្ឈប់ការងារកម្មករនិយោជិត

ឯកសារយោង

## ១០.១ វិធានការដាក់វិន័យ និង កំហុស

ច្បាប់ស្តីពីការងារ មាត្រា ២៦ ២៧ និង ២៨

និយោជកមានសិទ្ធិដាក់វិន័យកម្មករនិយោជិត ។ ប៉ុន្តែនៅពេលចាត់វិធានការដាក់វិន័យ និយោជកត្រូវតែអនុវត្តតាមច្បាប់ស្តីពីការងារ និង បញ្ញត្តិ ក៏ដូចជា អនុសញ្ញារួម និងបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាសផងដែរ ។

### ១០.១.១ លក្ខខណ្ឌតំរូវក្នុងការបង្ហាញពីកំហុស

សេចក្តីបង្គាប់អាជ្ញាកណ្តាល ២៧/០៣ និង ១៩៣/១២

និយោជកដែលចង់ដាក់វិន័យ ឬ បញ្ឈប់ការងារកម្មករនិយោជិតដោយសារកំហុស ត្រូវតែបង្ហាញពីភស្តុតាងនៃកំហុសរបស់កម្មករនិយោជិតនោះ ។

### ១០.១.២ ពេលវេលាកំណត់សំរាប់ការដាក់ទោសវិន័យបណ្តេញពីការងារ

ច្បាប់ស្តីពីការងារមាត្រា ២៦
សេចក្តីបង្គាប់អាជ្ញាកណ្តាល ២៦/០៤ ១៦៩/០៩(១) ១៩៥/១២ និង ១៨៨/១២(១)

និយោជកអាចបញ្ឈប់ការងារកម្មករនិយោជិតបានតែចំពោះកំហុសធ្ងន់ប៉ុណ្ណោះ ប្រសិនបើគេធ្វើដូច្នេះ ក្នុងរយៈពេល៧ថ្ងៃនៃកាលបរិច្ឆេទ ដែលគេបានដឹងថា កម្មករនិយោជិតបានប្រព្រឹត្តកំហុសធ្ងន់នោះ ។

### ១០.១.៣ ពេលវេលាកំណត់សំរាប់វិធានការដាក់វិន័យ

ច្បាប់ស្តីពីការងារ មាត្រា ២៦

និយោជកអាចដាក់វិន័យបាន ប្រសិនបើគេធ្វើដូច្នេះក្នុងរយៈពេល ១៥ថ្ងៃ នៃកាលបរិច្ឆេទដែលគេបានដឹងពីកំហុសរបស់កម្មករនិយោជិត ។

### ១០.១.៤ ការដាក់វិន័យត្រូវតែសមហេតុផល

ច្បាប់ស្តីពីការងារមាត្រា ២៧
សេចក្តីបង្គាប់អាជ្ញាកណ្តាល ១៨៤/១០ ១៩/១២ និង ២៩៩/១២

ការដាក់វិន័យណាមួយដែលនិយោជកធ្វើឡើងចំពោះកម្មករនិយោជិត ត្រូវសមាមាត្រទៅនឹងទំងន់ទោសដែលកម្មករនិយោជិតនោះបានប្រព្រឹត្ត ។

និយោជកអាចបញ្ឈប់ការងារកម្មករនិយោជិតភ្លាមៗបានចំពោះកំហុសធ្ងន់ ( សូមអានផ្នែក១០. ១.៥ ខាងក្រោម ) ប៉ុន្តែ ចំពោះកំហុសដែលមិនធ្ងន់ គេត្រូវធ្វើការព្រមាន ដោយសរសេរជាលាយលក្ខណ៍អក្សរទៅកម្មករនិយោជិតមុនពេលបញ្ឈប់ការងារ ។

ឯកសារយោង

### ១០.១.៥ ឧទាហរណ៍អំពីកំហុសធ្ងន់

ច្បាប់ស្តីពីការងារ មាត្រា ៨៣(ខ) ៣៣០ និង ៣៣៧
សេចក្តីបង្គាប់អាជ្ញាកណ្តាល ១៨/០៤ ២២/០៤ ១៩៤/១២ និង ២០០/១២

ច្បាប់ស្តីពីការងារចែងដូចឧទាហរណ៍ខាងក្រោមនេះស្តីពីកំហុសធ្ងន់:

- ការប្រើប្រាស់និយោជក
- ការក្លែងបន្លំនិយោជក វិច្ឆេទកម្ម ការមិនគោរពតាមកិច្ចសន្យាការងារ ឬ ការផ្សាយអាថ៌កំបាំងវិជ្ជាជីវៈ
- ល្មើសធ្ងន់ធ្ងរចំពោះវិធានខាងវិន័យសន្តិសុខ និង អនាម័យ
- ការគំរាម កំហែងជេរប្រមាថ ឬវាយដំនិយោជក ឬ កម្មករនិយោជិតឯទៀត
- ការញុះញុងកម្មករនិយោជិតឯទៀតអោយប្រព្រឹត្តកំហុសធ្ងន់
- ការឃោសនា សកម្មភាព ឬ បាតុកម្មនយោបាយក្នុងកន្លែងធ្វើការ
- ប្រព្រឹត្តអំពើហិង្សាក្នុងពេលកូដកម្ម
- ខកខានមិនបានចូលធ្វើការវិញ ដោយគ្មានមូលហេតុត្រឹមត្រូវ ក្នុងរយៈពេល៤៨ម៉ោង បន្ទាប់ពីតុលាការ ចេញបញ្ជាអោយចូលធ្វើការ ។

ដោយផ្អែកតាមកាលៈទេសៈនេះ តុលាការអាចកំណត់ទង្វើផ្សេងៗទៀតរបស់កម្មករនិយោជិតថាជាកំហុសធ្ងន់បាន ។ តែទោះជាយ៉ាងណាក៏ដោយ ការគ្រាន់តែធ្វើកូដកម្មដោយមិនគោរពតាមនិតិវិធីច្បាប់ មិនមែនជាកំហុសធ្ងន់នោះឡើយ ។

### ១០.១.៦ ការទាមទារអោយបញ្ឈប់ការងារកម្មករនិយោជិត ឬ អ្នកចាត់ចែង

សេចក្តីបង្គាប់អាជ្ញាកណ្តាល ០៦/១២ ១២៣/១២(១) និង ១៩៧/១២(៦)

ជាការពិតអ្នកចាត់ចែងម្នាក់ដែលបានមានកំហុស មិនមែនមានន័យថា និយោជកត្រូវតែបញ្ឈប់ការងារអ្នកចាត់ចែងនោះទេ។ កម្មករនិយោជិតអាចសុំអោយនិយោជករបស់គេបញ្ឈប់ការងារអ្នកចាត់ចែង ឬ កម្មករនិយោជិតម្នាក់ទៀត ដែលមានកំហុស ប៉ុន្តែសិទ្ធិក្នុងការសំរេចថាតើត្រូវបញ្ឈប់ ឬ មិនបញ្ឈប់ គឺជាសិទ្ធិរបស់និយោជក។ ប៉ុន្តែកម្មករនិយោជិត អាចទាមទារការខូចខាតប្រសិនបើ និយោជកនោះប្រព្រឹត្តកំហុសទៅលើពួកគេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានបដិសេធមិនព្រមតំរូវអោយនិយោជកបញ្ឈប់អ្នកគ្រប់គ្រង និង និយោជិតផ្សេងៗទៀតរបស់ខ្លួនចេញពីការងារទេ ។

## ១០.២ ការព្យួរកិច្ចសន្យាការងារ

ច្បាប់ស្តីពីការងារ មាត្រា ៧១ និង ៧២

កិច្ចសន្យាការងារអាចត្រូវបានព្យួរដោយមូលហេតុមួយចំនួន។ នៅពេលដែលកិច្ចសន្យាការងារត្រូវបានព្យួរ និយោជកមិនតម្រូវអោយផ្តល់ប្រាក់ឈ្នួល ហើយកម្មករនិយោជិតមិនតម្រូវអោយធ្វើការងារទេ។

នៅពេលបញ្ចប់ការព្យួរនោះហើយ ទំនាក់ទំនងការងារជាទូទៅត្រលប់មកដូចធម្មតាវិញ ។

## ១០.២.១ មូលហេតុនៃការព្យួរកិច្ចសន្យាការងារ

ច្បាប់ស្តីពីការងារ មាត្រា ៧១
សេចក្តីបង្គាប់អាជ្ញាកណ្តាល ២១/០៣
៤៦/០៤ និង ៦០/០៤

កិច្ចសន្យាការងារអាចត្រូវបានព្យួរបានតែដោយសារមូលហេតុទាំងឡាយដូចដែលបានកំណត់នៅក្នុង មាត្រា៧១ នៃច្បាប់ស្តីពីការងារ ។ មូលហេតុសំខាន់ៗបំផុតទាំងនេះរួមមាន:

- ការព្យួរដោយដាក់វិន័យតាមបទបញ្ជាផ្ទៃក្នុង និង
- បញ្ហាសេដ្ឋកិច្ចធ្ងន់ធ្ងររបស់សហគ្រាស ក៏ប៉ុន្តែការព្យួរត្រូវពិនិត្យនៅក្រោមការត្រួតពិនិត្យ របស់អធិការការងារ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសំរេចថាបើសិនជានិយោជកមិនបានព្យួរកិច្ចសន្យាការងារ ដោយអនុលោមតាម មាត្រា៧១ នៃច្បាប់ស្តីពីការងារទេ និយោជកត្រូវតែបង់ឈ្នួលពេញលេញជូនកម្មករនិយោជិតតាមកិច្ចសន្យា ការងាររបស់គេ ។

## ១០.២.២ ការព្យួរការងារដើម្បីជាការដាក់វិន័យ

ច្បាប់ស្តីពីការងារ មាត្រា ២៧ និង
៧១(៧)សេចក្តីបង្គាប់អាជ្ញាកណ្តាល
២៨/០៤ ១៤៦/១១(១ និង ២ និង ៣)

និយោជក អាចព្យួរកិច្ចសន្យាការងារនិយោជកនៅពេលដែលកំពុងស្រាវជ្រាវពីកំហុសធ្ងន់ដែលបានចោទ ប៉ុន្តែ កម្មករនិយោជិតនោះត្រូវទទួលបានប្រាក់ឈ្នួលក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារនេះ ។

និយោជកអាចព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតដោយផ្តល់ប្រាក់ឈ្នួលសំរាប់មូលហេតុវិន័យ តែក្នុងល័ក្ខខ័ណ្ឌដែល:

- រយៈពេលនៃការព្យួរកិច្ចសន្យាការងារសមាមាត្រទៅនឹងទំងន់ទោសដែលបានចោទ ហើយ
- បទបញ្ជាផ្ទៃក្នុងរបស់និយោជកអនុញ្ញាតអោយព្យួរកិច្ចសន្យាការងារបែបនោះ ។

## ១០.២.៣ ការព្យួរការងារដោយសារបញ្ហាសេដ្ឋកិច្ច

ច្បាប់ស្តីពីការងារ មាត្រា ៧១ (១១)
សេចក្តីបង្គាប់អាជ្ញាកណ្តាល ០១ /០៤
១០ / ០៤ ៤៦ / ០៤ ២៦/១២(៤)
៩៥/១២(១១) និង ៥២/១២(១)

និយោជកអាចព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតបាននៅពេលដែលប្រឈមនឹងបញ្ហាសេដ្ឋកិច្ចធ្ងន់ធ្ងរ។

ក្នុងករណីបែបនេះ កម្មករនិយោជិតអាចត្រូវបានព្យួរការងាររហូតដល់ ២ខែ ដរាបណាការព្យួរការងារត្រូវបាន យល់ព្រមពីប្រសួងទទួលបន្ទុកវិស័យការងារ។ ប្រសិនបើ ក្រសួងទទួលបន្ទុកវិស័យការងារមិនត្រូវបានជូន ដំណឹងទេនោះ ការព្យួរកិច្ចសន្យាការងារពុំមានសុពលភាព ហើយនិយោជកត្រូវបានតម្រូវអោយបង់ប្រាក់ឈ្នួល ពេញទៅកម្មករនិយោជិត ។

វាជាការអនុវត្តន៍ជាទូទៅក្នុងឧស្សាហកម្មសំលៀកបំពាក់ វាយនភ័ណ្ឌ និង ស្បែកជើង ដែលនិយោជកត្រូវបង់ ប្រាក់ឈ្នួល ៥០% ទៅកម្មករនិយោជិត នៅពេលដែលគ្មានការងារអោយធ្វើ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល មិនបានអនុញ្ញាតអោយអនុវត្តបែបនេះទេប្រសិនបើការព្យួរកិច្ចសន្យាការងារនេះ មិនធ្វើឡើងនៅក្រោមការ ពិនិត្យមើលរបស់ក្រសួងទទួលបន្ទុកវិស័យការងារ ។

## ១០.៣ ការបញ្ឈប់កិច្ចសន្យាការងារមានថិរវេលាកំណត់

ច្បាប់ស្តីពីការងារ មាត្រា ៧៣

កិច្ចសន្យាការងារមានថិរវេលាកំណត់អាចផុតរលត់នៅពេលដល់កាលកំណត់ ឬ ដោយការរំលាយ ។

កិច្ចសន្យាការងារមានថិរវេលាកំណត់ ជាធម្មតាផុតរលត់នៅពេលបញ្ចប់កាលបរិច្ឆេទដែលមានកំណត់នៅក្នុងកិច្ចសន្យា ។

មានមូលហេតុសំខាន់ៗ ២ តាមផ្លូវច្បាប់ចំពោះការរំលាយកិច្ចសន្យាការងារមានថិរវេលាកំណត់ មុនពេលកាលបរិច្ឆេទកំណត់ កិច្ចព្រមព្រៀង និង កំហុសធ្ងន់ ។




## ១០.៣.១ ការរំលាយកិច្ចសន្យាការងារតាមការព្រមព្រៀង

ច្បាប់ស្តីពីការងារ មាត្រា ៧៣ (១)
សេចក្តីបង្គាប់អាជ្ញាកណ្តាល ២០០/១២ (១ និង ២)

កិច្ចសន្យាការងារមានថិរវេលាកំណត់ អាចរំលាយដោយការព្រមព្រៀង។ ការព្រមព្រៀងនេះ ត្រូវតែសរសេរជាលាយលក្ខណ៍អក្សរ និង មានអធិការការងារធ្វើជាសាក្សី។

## ១០.៣.២ ការរំលាយកិច្ចសន្យាការងារដោយសារកំហុសធ្ងន់

ច្បាប់ស្តីពីការងារ មាត្រា ៧៣(២) និង ៨៣

និយោជកអាចរំលាយកិច្ចសន្យាការងារមានថិរវេលាកំណត់មុខដល់ពេលកាលបរិច្ឆេទកំណត់ ប្រសិនបើកម្មករនិយោជិតប្រព្រឹត្តកំហុសធ្ងន់។

ទាក់ទងនឹងសេចក្តីពន្យល់អំពីកំហុសធ្ងន់ សូមមើលផ្នែកទី ១០.១.៥ ខាងលើ។

## ១០.៣.៣ ការរំលាយកិច្ចសន្យាការងារដោយសារករណីប្រធានស័ក្តិ

ច្បាប់ស្តីពីការងារ មាត្រា ៧៣(២)

កិច្ចសន្យាការងារមានថិរវេលាកំណត់ក៏អាចរំលាយបានផងដែរ ដោយពុំចាំបាច់មានការព្រមព្រៀងរបស់ភាគីទាំងពីរនៅពេលដែលមានករណីប្រធានស័ក្តិឡើង ។

## ១០.៣.៤ ការរំលាយកិច្ចសន្យាការងារមានថិរវេលាកំណត់ដោយគ្មានមូលហេតុស្របច្បាប់

ច្បាប់ស្តីពីការងារ មាត្រា ៧៣(៣) និង (៤)
សេចក្តីបង្គាប់អាជ្ញាកណ្តាល ៨៤/១១(២) ១៥០/១១(១១) ១០៦/១២(៥) និង ២១២/១២(២)

ទាំងនិយោជក និង កម្មករនិយោជិតអាចរំលាយកិច្ចសន្យាការងារមានថិរវេលាកំណត់ ដោយមូលហេតុផ្សេងៗបាន ។

ប៉ុន្តែ ប្រសិនបើនិយោជករំលាយកិច្ចសន្យាការងារមានថិរវេលាកំណត់ដោយគ្មានហេតុផលស្របច្បាប់ និយោជកត្រូវផ្តល់ប្រាក់ឈ្នួលពេញដែលកម្មករនិយោជិតត្រូវទទួលបាន បើសិនត្រូវបានអនុញ្ញាតអោយធ្វើការរហូតដល់កាលបរិច្ឆេទបញ្ចប់ ដូចជាកំណត់នៅក្នុងកិច្ចសន្យា។ ស្រដៀងគ្នានេះដែរ បើសិនជាកម្មករនិយោជិតរំលាយកិច្ចសន្យាការងារមានថិរវេលាកំណត់ ដោយគ្មានហេតុផលត្រឹមត្រូវតាមច្បាប់ ខ្លួនត្រូវតែសងជំងឺចិត្តដល់និយោជក ចំពោះការខូចខាតនានាដែលនិយោជក បានទទួលរងគ្រោះដោយសារតែការរំលាយកិច្ចសន្យាការងាររបស់កម្មករនិយោជិតនោះ ។

## ១០.៣.៥ ប្រាក់បំណាច់បញ្ចប់កិច្ចសន្យានៅពេលបញ្ចប់កិច្ចសន្យាការងារមានថិរវេលាកំណត់

ច្បាប់ស្តីពីការងារ មាត្រា ៧៣ (៦)
សេចក្តីបង្គាប់អាជ្ញាកណ្តាល ៨៤/១១(២) ១១៥/១១(១) និង ១៥០/១១(១១)

នៅពេលដែលកិច្ចសន្យាការងារមានថិរវេលាកំណត់ត្រូវបានរំលាយ ឬ ដល់កាលកំណត់ កម្មករនិយោជិតមានសិទ្ធិទទួលប្រាក់បំណាច់បញ្ចប់កិច្ចសន្យា ។

ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាត្រូវស្មើនឹងយ៉ាងតិច ៥% នៃប្រាក់ឈ្នួលសរុបដែលបើកអោយកម្មករនិយោជិតក្នុងកំឡុងពេលនៃកិច្ចសន្យាមានថេរវេលាកំណត់ ។

ឧទាហរណ៍:　ប្រាក់បំណាច់បញ្ចប់កិច្ចសន្យា

*សុខា*

បានចុះហត្ថលេខាជាមួយរោងចក្រកាត់ដេរសំលៀកបំពាក់លើកិច្ចសន្យាការងារមានថិរវេលាកំណត់១ឆ្នាំ។ ប្រាក់ឈ្នួលគោលគឺ ៨០ ដុល្លារ ប៉ុន្តែនាងក៏បានធ្វើការងារបន្ថែមម៉ោងផងដែរ និង បានទទួលប្រាក់រង្វាន់ខ្លះ។ ជាសរុប នាងទទួលបាន ១៣៥៣.៦០ ដុល្លារ ក្នុងមួយឆ្នាំ។

*ដោយគណនា ៥% នៃប្រាក់ឈ្នួលសុរប ប្រាប់បំណាច់បញ្ចប់កិច្ចសន្យារបស់នាងអាច ៥% X ១៣៥៣.៦០ ដុល្លារ = ៦៧.៦៨ ដុល្លារ*

## ១០.៣.៦　ការជូនដំណឹងមុនពេលដល់កាលបរិច្ឆេទនៃកិច្ចសន្យាការងារមានថិរវេលាកំណត់

ច្បាប់ស្តីពីការងារ មាត្រា ៧៣ ៨៧ និង ៨៦
សេចក្តីជូនដំណឹង ០៦/ ៩៧
សេចក្តីបង្គាប់អាជ្ញាកណ្តាល ១០/០៣ ១០២/១២(២) ១១៩/១២(១)

កាលណានិយោជកមានបំណងអោយកម្មករនិយោជិត ឈប់ធ្វើការនៅពេលចប់កិច្ចសន្យាការងារមានថិរវេលាកំណត់និយោជកត្រូវតែជូនដំណឹងដល់កម្មករនិយោជិតជាមុនដោយផ្អែកទៅតាមតារាងខាងក្រោម:

| រយៈពេលនៃកិច្ចសន្យា | រយៈពេលជូនដំណឹង |
|---|---|
| ៦ខែ ឬ តិចជាង | មិនតម្រូវអោយជូនដំណឹង |
| លើសពី ៦ខែ | ១០ថ្ងៃ |
| លើសពី ១ឆ្នាំ | ១៥ថ្ងៃ |

ប្រសិនបើជាគ្មានការជូនដំណឹងជាមុន កិច្ចសន្យាការងារមានថិរវេលាកំណត់ នឹងត្រូវបានបន្តដោយស្វ័យប្រវត្តិសំរាប់រយៈពេលដូចគ្នានឹងកិច្ចសន្យាការងារដើមដែរ។ កិច្ចសន្យានេះនឹងក្លាយទៅជាកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ ប្រសិនបើរយៈពេលសរុបនៃការងារលើសពី ២ឆ្នាំ។

## ១០.៤　ការបញ្ចប់កិច្ចសន្យាការងារមានថិរវេលាមិនកំណត់

ច្បាប់ស្តីពីការងារ មាត្រា ៧៤
សេចក្តីបង្គាប់អាជ្ញាកណ្តាល ១០១/១២(២)

កិច្ចសន្យាការងារមានថិរវេលាមិនកំណត់ អាចត្រូវបានរំលាយដោយនិយោជក ឬ កម្មករនិយោជិត។

កម្មករនិយោជិតអាចរំលាយកិច្ចសន្យាថិរវេលាមិនកំណត់ដោយមានមូលហេតុណាមួយក៏បាន ។

និយោជក អាចរំលាយកិច្ចសន្យាមិនកំណត់បាន លុះត្រាតែមានហេតុផលសមរម្យដែលពាក់ព័ន្ធ ទៅនឹងជំនាញ អាកប្បកិរិយារបស់កម្មករនិយោជិត ឬ ត្រូវការ ផ្សេងៗរបស់សហគ្រាស ។




## ១០.៤.១ ការជូនដំណឹងអំពីការបញ្ចប់កិច្ចសន្យាការងារ

ច្បាប់ស្តីពីការងារ មាត្រា ៧៥

និយោជក ឬ កម្មករនិយោជិតដែលមានបំណងរំលាយកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរៗរយៈពេលនៃការជូនដំណឹងផ្អែកទៅលើរយៈពេលនៃការងារដែលកំណត់នៅក្នុងតារាងខាងក្រោមនេះ៖

| រយៈពេលនៃការងារ | រយៈពេលជូនដំណឹង |
|---|---|
| តិចជាង ៦ខែ | ៧ថ្ងៃ |
| ៦ខែ រហូតដល់ ២ឆ្នាំ | ១៥ថ្ងៃ |
| លើសពី ៥ឆ្នាំ រហូតដល់៥ឆ្នាំ | ១ខែ |
| លើសពី ៥ឆ្នាំ រហូតដល់១០ឆ្នាំ | ២ខែ |
| លើសពី ១០ឆ្នាំ | ៣ខែ |

ឯកសារយោង

ច្បាប់ស្តីពីការងារ មាត្រា ៧៨ ៧៩ និង៨១

ច្បាប់ស្តីពីការងារ មាត្រា ៧៧
សេចក្តីបង្គាប់អាជ្ញាកណ្តាល៨១ /០៤
១០៣/១២(១ និង ២) ១៨៤/១២(១)
១៩៣/១២(២) ១៩៩/១២(១)

ច្បាប់ស្តីពីការងារ មាត្រា ៨២ និង ៨៦
សេចក្តីជូនដំណឹង ០៦/៩៧
១១៦/១២(២) និង

*កាតព្វកិច្ចក្នុងរយៈពេលជូនដំណឹង*

ជាទូទៅ និយោជក និង កម្មករនិយោជិតត្រូវតែធ្វើការជាមួយគ្នាតាមធម្មតាក្នុងអំឡុងពេលជូនដំណឹង ។

ទោះជាយ៉ាងណាក៏ដោយ កម្មករនិយោជិតអាចឈប់សំរាកដោយមានប្រាក់ឈ្នួល ២ថ្ងៃ ក្នុង១សប្តាហ៍ ដើម្បីស្វែងរកការងារថ្មី និង អាចឈប់ធ្វើការមុនបាន ប្រសិនបើគេរកបានការងារមួយទៀត។ បើសិនដូច្នេះទេ និយោជកនិងកម្មករនិយោជិតត្រូវធ្វើការជាមួយគ្នាដូចធម្មតាក្នុងរយៈពេលជូនដំណឹងនោះ ។

*ការមិនបានជូនដំណឹង*

និយោជកដែលមិនបានជូនដំណឹងទៅកម្មករនិយោជិតត្រូវបើកប្រាក់ឈ្នួល និង អត្ថប្រយោជន៍ផ្សេងៗទៅតាមការដែលកម្មករនិយោជិតអាចទទួលបានក្នុងអំឡុងពេលជូនដំណឹង។ មូលដ្ឋាននៃការគណនានេះ គឺប្រាក់ឈ្នួលប្រចាំថ្ងៃជាមធ្យមក្នុងរយៈពេល ១២ខែ កន្លងមក មិនមែនជាប្រាក់ឈ្នួលអប្បបរមាទេ ( សូមអានផ្នែក ១០.៤.៣ខាងក្រោម ) ។

*វិធានពិសេសទាក់ទងនឹងតម្រូវការជូនដំណឹង*

| ក្នុងករណី | តម្រូវការជូនដំណឹង |
|---|---|
| កំហុសធ្ងន់ | មិនបាច់ជូនដំណឹង |
| កម្មករនិយោជិតសាកល្បង | មិនបាច់ជូនដំណឹង(លើកលែងតែនៅឧស្សាហកម្មសំលៀកបំពាក់នៅក្នុងភ្នំពេញដែលតម្រូវឱ្យជូនដំណឹង៧ថ្ងៃ) |
| វិកលចរិត ឬការបាត់បង់ | ត្រូវជូនដំណឹង |
| កូនជាង | មិនបាច់ជូនដំណឹង(លើកលែងតែនៅក្នុងឧស្សាហកម្មសំលៀកបំពាក់នៅក្នុងទីក្រុងភ្នំពេញដែលតម្រូវអោយជូនដំណឹង១ថ្ងៃ) |

ជាទូទៅមិនតម្រូវអោយជូនដំណឹងចំពោះករណីមានកំហុសធ្ងន់ ឬ ប្រសិនបើកម្មករនិយោជិតនៅក្នុងអំឡុងពេលសាកល្បងទេ។ ប៉ុន្តែ និយោជកត្រូវតែជូនដំណឹងជាមុន ចំពោះការរំលាយកិច្ចសន្យាការងារមានថេរវេលាមិនកំណត់ នៅពេលដែលកម្មករនិយោជិតមានជំងឺពុំរ៉ៃ វិកលចរិត ឬ បាត់បង់សមត្ថភាពជាអចិន្ត្រៃយ៍ ។

នៅក្នុងវិស័យឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ វាយនភ័ណ្ឌ និង ស្បែកជើងនៅក្នុងទីក្រុងភ្នំពេញកម្មករនិយោជិតសាកល្បងមានសិទ្ធិទទួលដំណឹង៧ថ្ងៃមុន ចំណែកឯកម្មករនិយោជិតកូនជាងចំនួន១ថ្ងៃ ។

## ១០.៤.២ ប្រាក់បំណាច់បណ្ដាញចេញពេលបញ្ចប់កិច្ចសន្យាការងារមានថិរវេលាមិនកំណត់

និយោជកត្រូវតែផ្តល់សំណងទូទាត់នៃការផ្លាស់កិច្ចសន្យា នៅពេលដែលមានការបញ្ឈប់ការងារកម្មករនិយោជិត ដែលនៅក្រោមកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ដោយមូលហេតុក្រៅពីកំហុសធ្ងន់។

ច្បាប់ស្ដីពីការងារ មាត្រា ៨៩- ៩០ និង១១០
សេចក្ដីបង្គាប់អាជ្ញាកណ្ដាល២៧ /០៣
២៧/០៤ ២៩/០៤ ៣៦/១២(៥)
១០៣/១២(១និង២) ១៨៤/១២(៥)

ចំនួនសំណង់ទូទាត់នៃការ ផ្តាច់កិច្ចសន្យា គឺអាស្រ័យលើរយៈពេលដែលកម្មករនិយោជិតធ្វើការអោយនិយោជកដែលកំណត់នៅក្នុងតារាងខាងក្រោមនេះ។
មូលដ្ឋាននៃការគិតគឺត្រូវយកប្រាក់បានជាមធ្យមក្នុងរយៈពេល១២ខែ កន្លងមកមិនមែនប្រាក់ឈ្នួលអប្បបរមាទេ។ ក្រុមប្រឹក្សាអាជ្ញា កណ្ដាលយល់ឃើញថា ប្រាក់បន្ថែមម៉ោង និងប្រាក់រង្វាន់ដែល កម្មករនិយោជិតទទួលបានក្នុងរយៈពេល ១២ខែ មុនពេលបញ្ឈប់ពីការងារ គួរតែត្រូវបានគិតបញ្ចូលក្នុងការគិតប្រាក់នេះផង ដែរ ( សូមអានផ្នែក ១០.៤.៣ ខាងក្រោម )។

| រយៈពេលនៃការងារ | សំណងទូទាត់នៃការផ្តាច់កិច្ចសន្យា |
|---|---|
| ៦ខែ -១ឆ្នាំ | ប្រាក់ឈ្នួល៧ថ្ងៃ និង អត្ថប្រយោជន៍ផ្សេងៗ |
| លើសពី ១ឆ្នាំ | ១៥ថ្ងៃសំរាប់រយៈពេល១ឆ្នាំនៃការងាររហូតដល់៦ខែនៃប្រាក់ឈ្នួល និង អត្ថប្រយោជន៍ផ្សេងៗ (ប្រភាគនៃ ថិរវេលាពាកកណ្ដាលឆ្នាំ ឬ លើសពីនេះត្រូវគិត ស្មើនឹង មួយឆ្នាំពេញ ។ |

និយោជកមិនត្រូវផ្តល់សំណងទូទាត់លើការផ្តាត់កិច្ចសន្យាការងារទេ កាលណាកម្មករនិយោជិតសុំលាឈប់ពីការងារដោយ ស្ម័គ្រចិត្ត ប៉ុន្តែនិយោជកត្រូវតែផ្តល់សំណងទូទាត់ ប្រសិនបើនិយោជកជុំរុញអោយកម្មករនិយោជិតសុំលាឈប់ពីការងារ ។

ច្បាប់ស្ដីពីការងារ មាត្រា ៨៩- ៩០ និង១១០
សេចក្ដីបង្គាប់អាជ្ញាកណ្ដាល២៧ /០៣
២៧/០៤ ២៩/០៤ និង ២១/១០

**ឧទាហរណ៍: ការលាឈប់ពីការងារដោយបង្ខំ**

រោងចក្រមួយបានដំណើរការនៅក្នុងទីក្រុងភ្នំពេញអស់រយៈពេល ៣ឆ្នាំ។ ដោយមូលហេតុអាជីវកម្ម ម្ចាស់រោងចក្របានសំរេចចិត្តប្តូររោងចក្រទៅខេត្តកំពង់ចាម ។ និយោជក បានផ្តល់អោយកម្មករនិយោ ជិតទាំងអស់ បន្តធ្វើការងាររបស់ពួកគេនៅរោងចក្រថ្មី កម្មករនិយោជិតខ្លះទទួលយកការងារ និង ខ្លះសំរេចចិត្តថាពួកគេចង់ ស្នាក់នៅភ្នំពេញ ។ កម្មករនិយោជិតដែលទទួលយកការងារដែលប្តូរទៅកំពង់ចាម ត្រូវបានជំរុញអោយលាឈប់ពីការងារ ដូច្នេះពួកគេមានសិទ្ធិទទួលបានសំណងទូទាត់នៃការផ្តាច់កិច្ចសន្យាការងារនេះ ។

## ១០.៤.៣ សំណងជំងឺចិត្តចំពោះការបញ្ចប់កិច្ចសន្យាការងារដោយគ្មានមូលហេតុត្រឹមត្រូវ

ច្បាប់ស្តីពីការងារ មាត្រា ៩១
សេចក្តីបង្គាប់អាជ្ញាកណ្តាល
៣៦/១២(៥) ១០៣/១២(១និង២)
និង ១៩៩/១២(១)

និយោជកត្រូវតែផ្តល់ជំងឺចិត្ត ( បន្ថែមលើសំណងទូទាត់ចំពោះការផ្តាច់កិច្ចសន្យាការងារ ) ប្រសិនបើពួកគេរំលោយកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ជាមួយកម្មករនិយោជិតដោយគ្មានហេតុផលសមរម្យ ( សូមអានផ្នែក១០.៤ ) ។ កម្មករនិយោជិត មានសិទ្ធិទទួលសំណងជំងឺចិត្តយ៉ាងតិចណាស់ក៏ស្មើនឹងចំនួនដែលគេទទួលបានសំណងទូទាត់ចំពោះការផ្តាច់កិច្ចសន្យាការងារ ដែលជាប្រាក់បំណាច់បណ្តេញចេញពេលបញ្ចប់កិច្ចសន្យាដែរ ។

**ឧទាហរណ៍: សំណងជំងឺចិត្ត**

*សម្បត្តិ* បានធ្វើការអោយរោងចក្រកាត់ដេរសំលៀកបំពាក់អស់រយៈពេល ២៦ខែ នៅពេលដែលគាត់ត្រូវបានបណ្តេញចេញដោយគ្មានមូលហេតុ។ ក្រៅពីសំណងទូទាត់សំរាប់ការផ្តាច់កិច្ចសន្យា ( ចំនួន ៣០ថ្ងៃ ) គាត់អាចទាមទារចំនួនដូចគ្នានេះម្តងទៀត ដើម្បីជាការសងជំងឺចិត្ត ។

ក្នុងរយៈពេល ១២ខែ ចុងក្រោយប្រាក់ខែគោលរបស់ *សម្បត្តិ* គឺ ៨០ដុល្លារ ក្នុងមួយខែ តែគាត់ធ្វើការថែមម៉ោងជាច្រើន ហើយតែងតែមកធ្វើការជាប្រចាំ។ បើគិតបញ្ចូលទាំងប្រាក់រង្វាន់នឹង ប្រាក់បន្ថែមម៉ោង *សម្បត្តិ* រកបានសរុបទាំងអស់១៣៥៣.៦០ ដុល្លារ ក្នុងមួយឆ្នាំ ។

ទាំងសោហ៊ុយជម្ងឺចិត្តបណ្តាញចេញ និង សំណងជម្ងឺចិត្តផ្សេងៗទៀតតែត្រូវបានគិតដោយផ្អែកតាមប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់គាត់ ដូចមានថែងក្នុងរូបមន្តខាងក្រោមនេះ៖

$$= \frac{\text{១៣៥៣.៦០ដុល្លារ (ប្រាក់ឈ្នួលដែលរកបានក្នុងរយៈពេល១២ខែចុងក្រោយ)}}{\text{១២(ខែ) x ២៦ (ថ្ងៃធ្វើការក្នុងមួយខែ)}}$$

= *៤.៣៤ ដុល្លារ ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ*

ដូច្នេះ សោហ៊ុយជម្ងឺចិត្តបណ្តេញចេញរបស់សម្បត្តិ គឺ ៣០ថ្ងៃ x ៤.៣៤ ដុល្លារ = ១៣០.២ដុល្លារ។
ហើយគាត់អាចទាមទារសោហ៊ុយជម្ងឺចិត្តបានចំនួន ១៣០.២ ដុល្លារ ។

## ១០.៥ វិធានពិសេសសំរាប់ការបញ្ឈប់ពីការងាររួមគ្នា

ការបញ្ឈប់ពីការងាររួមគ្នាកើតឡើង នៅពេលនិយោជកបញ្ឈប់ការងារកម្មករនយោជិតដើម្បីបន្ថយផលិតកម្ម រៀបចំសហគ្រាសឡើងវិញ ឬបង្កើនផលិតកម្ម ។

ច្បាប់ស្តីពីការងារ មាត្រា ៩៥
សេចក្តីបង្គាប់អាជ្ញាកណ្តាល ០២/០៤ ៣១/០៤ ២១/១០ ៩៦/១០(១) និង ១១១/១០(២និង៣)

### ១០.៥.១ នីតិវិធីសំរាប់ការបញ្ឈប់ការងាររួមគ្នា

មុនពេលធ្វើការបញ្ឈប់ការងាររួមគ្នា និយោជកត្រូវតែធ្វើតាមនិតិវិធីខាងក្រោមនេះ៖

- ជូនដំណឹងទៅប្រតិភូបុគ្គលិក និង តំណាងសហជីពជាលាយលក្ខណ៍អក្សរ អំពីគំរោងបញ្ឈប់ការងារ ។
- បញ្ឈប់កម្មករនិយោជិតដែលមានសម្បទាខាងវិជ្ជាជីវ:ទាបជាងគេបំផុតមុន ។
- ចំពោះកម្មករនិយោជិតដែលមានលក្ខណ:សម្បត្តិស្មើគ្នា និយោជក គួរបញ្ឈប់អ្នក ដែលមានអតីតភាពតិចភាពជាងគេមុន។ ( អតីតភាពត្រូវតែតម្លើងមួយឆ្នាំ សំរាប់កម្មករនិយោជិតណាដែលមានគូរស្រករ និង មួយឆ្នាំថែមទៀត ក្នុងកូនម្នាក់ៗក្នុងបន្ទុក ។)

ច្បាប់ស្តីពីការងារ មាត្រា ៩៥ និង ២៨៤
ប្រធាន ៣១៣/00
សេចក្តីបង្គាប់អាជ្ញាកណ្តាល ២៦/១២(១)

### ១០.៥.២ សិទ្ធិអាទិភាពក្នុងការជួលអោយធ្វើការឡើងវិញ

កម្មករនិយោជិតដែលត្រូវបានបញ្ឈប់ពីការងាររួមគ្នានោះមានអាទិភាពក្នុងការជួលអោយធ្វើការឡើងវិញ សំរាប់រយ:ពេល២ឆ្នាំ ។

ច្បាប់ស្តីពីការងារ មាត្រា ៩៥

## ១០.៦ វិធានពិសេសសំរាប់ការបញ្ឈប់ពីការងារសកម្មជនសហជីព និង ប្រតិភូបុគ្គលិក

និយោជកត្រូវបានហាមឃាត់មិនអោយពិចារណាលើសហជីព ឬ ការចូលរួមក្នុងសកម្មភាពសហជីពនៅពេលធ្វើការសំរេចលើការជ្រើសរើសអោយចូលធ្វើការ ការចាត់ចែង និង ការបែងចែកការងារការតំឡើងថ្នាក់ការផ្តល់ប្រាក់ឈ្នួល និង ការផ្តល់អត្ថប្រយោជន៍ វិធានការដាក់វិន័យ និង ការបញ្ឈប់ការងារ ។

ច្បាប់ស្តីពីការងារ មាត្រា ១២ និង ២៧៩
សេចក្តីបង្គាប់អាជ្ញាកណ្តាល ១១៩/១០(១) ២១២/១២(១) និង ២១៥/១២(១និង២)

### ១០.៦.១ ការការពារប្រតិភូបុគ្គលិក និង សកម្មជនសហជីព

និយោជកត្រូវតែអនុវត្តតាមវិធានពិសេស នៅពេលដែលគេបញ្ឈប់ការងារប្រតិភូបុគ្គលិក និង សកម្មជនសហជីព *(ដែលត្រូវចាត់ទុកថាជា កម្មករនិយោជិតដែលទទួលបានការការពារ)*។ វិធានទាំងឡាយមានដូចខាងក្រោមនេះ៖

ច្បាប់ស្តីពីការងារ មាត្រា ២៩៣ - ២៩៥
សេចក្តីបង្គាប់អាជ្ញាកណ្តាល ៩៥/០៩(៦) ០០២/១២(១) ២៦/១២(១) និង ១២៥/១២(១)

- និយោជកអាចបញ្ឈប់ការងារកម្មករនិយោជិតដែលត្រូវបានការពារ តែបន្ទាប់ពីទទួលការអនុញ្ញាតពីអធិការការការងារ ។
- ប៉ុន្តែ ប្រសិនបើកម្មករនិយោជិតដែលត្រូវបានការពារ ត្រូវបានចោទពីបទប្រព្រឹត្ត ឬកំហុសធ្ងន់ និយោជក អាចព្យួរការងារភ្លាមនៅពេលកំពុងរង់ចាំការអនុញ្ញាតពីអធិការ ការងារ ។
- អធិការការងារត្រូវតែសំរេចក្នុងរយៈពេល១ខែបន្ទាប់ពីទទួលសំណើសុំបញ្ឈប់ការងារពីនិយោជក។ ប្រសិនបើអធិការការងារមិនផ្តល់ការសំរេចក្នុង១ខែ សំណើនេះត្រូវចាត់ទុកថាត្រូវបានបដិសេធ។

ឯកសារយោង

- និយោជក កម្មករនិយោជិត ឬ សហជីព អាចតវ៉ានឹងសេចក្តីសំរេចរបស់អធិការការងារទៅក្រសួងទទួលវិស័យការងារក្នុងរយៈពេល២ខែ បន្ទាប់ពីបានជូនដំណឹងពីសេចក្តីសំរេចនោះ។




## ១០.៦.២ ប្រភេទផ្សេងៗនៃកម្មករនិយោជិតដែលទទួលបានការការពារ

ច្បាប់ស្តីពីការងារ មាត្រា ២៨២ និង ២៩៣

ប្រកាស ៣១៣ / ០០ និង ៣០៥ /០១

កម្មករនិយោជិតដែលត្រូវបានការពារមាន:

| | |
|---|---|
| i. បេក្ខជនឈរឈ្មោះបោះឆ្នោតប្រតិភូបុគ្គលិ ក | ច្បាប់ស្តីពីការងារ មាត្រា ២៩៣ |
| ii. ប្រតិភូបុគ្គលិក ( ប្រតិភូពេញសិទ្ធិ និងប្រតិភូជំនួយ) | ច្បាប់ស្តីពីការងារ មាត្រា ២៩៣ |
| iii. បេក្ខជនដែលមិនបានជាប់ឆ្នោតក្នុងការបោះឆ្នោតប្រតិភូបុគ្គលិក (រយៈពេល ៣ខែ បន្ទាប់ពីការផ្សាយលទ្ធផលបោះឆ្នោត) | ច្បាប់ស្តីពីការងារ មាត្រា ២៩៣ |
| iv. អតីតប្រតិភូបុគ្គលិកពេញសិទ្ធិ និង ប្រតិភូជំនួយ (រយៈពេល៣ខែបន្ទាប់ពី បញ្ចប់អណត្តិ) | ច្បាប់ស្តីពីការងារ មាត្រា ២៩៣<br>ឯកសារយោង |
| v. សមាជិកស្ថាបនិកសហជីព និង អ្នកដែលចូលរួមក្នុងសហជីពក្នុងអំឡុងពេលដាក់ពាក្យចុះបញ្ជីកា ពេលចាប់ផ្តើមពីកាលបរិច្ឆេទដាក់ពាក្យ និង ពេលបន្តសំរាប់ពេល ៣០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៅពេលដែលចុះបញ្ជិកាសហជីពនៅក្រសួងទទួលបន្ទុកវិស័យការងារ | ប្រកាស ៣០៥/០១ប្រការ ៤ |
| vi. អ្នកដឹកនាំសហជីព (ប្រធាន អនុប្រធានទីមួយលេខាធិការទីមួយ) ប្រសិនបើនិយោជកបាន ទទួលដំណឹងជាលាយលក្ខណ៍អក្សរពីអត្តសញ្ញាណរបស់ពួកគេ | ប្រកាស ៣០៥/០១ប្រការ ៤<br>ប្រកាស ៣១៣/០០ប្រការ ៧ |
| vii. បេក្ខជនឈរឈ្មោះប្រធានសហជីព ចាប់ផ្តើម៤៥ថ្ងៃ មុនពេលបោះឆ្នោត និង បញ្ចប់ ៤៥ថ្ងៃ ក្រោយបោះឆ្នោត ប្រសិនបើបេក្ខជននោះពុំជាប់ឆ្នោត | ច្បាប់ស្តីពីការងារ មាត្រា ២៩៣<br>ប្រកាស ៣០៥/០១ប្រការ ៣ |
| viii. អតីតអ្នកនាំសហជីព (រយៈពេល ៣ខែ បន្ទាប់ពីបញ្ចប់អាណត្តិរបស់ពួកគេ) | ច្បាប់ស្តីពីការងារ មាត្រា ២៩៣<br>ប្រកាស ៣០៥/០១ប្រការ ៣ |
| ix. ប្រតិភូសហជីព | ច្បាប់ស្តីពីការងារ មាត្រា ២៨២ |
| x. អតីតប្រតិភូសហជីព ( រយៈពេល៦ខែ បន្ទាប់បញ្ចប់អាណត្តិរបស់ពួកគេ) | ច្បាប់ស្តីពីការងារ មាត្រា ២៨២ |
| xi. តំណាងសហជីពដែលត្រូវបានតែងតាំងនៅក្នុងសហគ្រាស ដែលសហជីពថ្នាក់ឧស្សាហកម្ម ឬ សហជីពថ្នាក់ជាតិដែលមានសមាជិកនៅក្នុងសហគ្រាស | ប្រកាស ៣០៥/០១ ប្រការ ៥ |
| xii. អតីតតំណាងសហជីពដូចបានរៀបរាប់ក្នុងចំនុច xi ខាងលើនេះ (រយៈពេល ៣ខែ បន្ទាប់ពីបញ្ចប់អាណត្តិរបស់ពួកគេ) | ច្បាប់ស្តីពីការងារ មាត្រា ២៩៣<br>ប្រកាស ៣០៥/០១ ប្រការ ៥ |

## ១០.៧ ការមិនរើសអើង

រដ្ឋធម្មនុញ្ញ មាត្រា ៣១

រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា ធានាអោយប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ទទួលបានការប្រព្រឹត្តដោយស្មើភាពគ្នាចំពោះមុខច្បាប់ ។

## ១០.៧.១ ការមិនរើសអើង

ឯកសារយោង ១២

*គ្មាននិយោជកណាម្នាក់អាចយកបញ្ហា:*

- ពូជសាសន៍
- ភេទ
- គំនិតនយោបាយ
- ដើមកំណើតសង្គម
- ពណ៌សម្បុរ
- សាសនា ឬ ជំនឿ
- ជាតិកំណើត
- ការចូលជាសមាជិកសហជីពកម្មករ និយោជិត ឬ ធ្វើសកម្មភាពក្នុងសហជីព

*ដើម្បីជាលេសក្នុងការធ្វើសេចក្តីសំរេចអំពី:*

- ការជួល
- ការបណ្តុះបណ្តាលវិជ្ជាជីវៈ
- ការតម្លើងឋានន្តរសក្តិ
- ការផ្តល់អត្ថប្រយោជន៍
- ការបែងចែកការងារ
- ការតម្លើងថ្នាក់
- ការផ្តល់កំរៃ
- វិន័យ ឬ ការផ្តាច់កិច្ចសន្យាការងារ។

## ១០.៧.២ ការរើសអើងដែលអាចអនុញ្ញាតបាន

ច្បាប់ស្តីពីការងារ មាត្រា ១២

និយោជក ត្រូវតែធ្វើសេចក្តីសំរេចខាងលើដោយផ្អែកលើភាពសមហេតុផល និង ដោយមិនផ្អែក លើកត្តាដូចជា ពូជសាសន៍ ភេទ សាសនា ឬ ការចូលរួមក្នុងសកម្មភាពនយោបាយ ។ ប៉ុន្តែ នៅពេលដែលលក្ខណៈនៃការងារ តម្រូវលើលក្ខណៈសម្បត្តិសំរាប់ មុខរបរ ការរើសអើងនេះត្រូវ បានអនុញ្ញាត ។

## ១០.៧.៣ ប្រាក់ឈ្នួលត្រូវស្មើគ្នា ចំពោះការងារដូចគ្នា

ច្បាប់ស្តីពីការងារ មាត្រា ១០៦
សេចក្តីបង្គាប់អាជ្ញាកណ្តាល ១៩ /០៥ និង ១៨៥/១២(២)

ប្រាក់ឈ្នួលផ្សេងគ្នាដោយផ្អែកលើដើមកំណើតភេទ ឬ អាយុរបស់កម្មករនិយោជិត ត្រូវបានហាមឃាត់ ។

## ផ្នែកទី ១១ ការដោះស្រាយវិវាទ

ឯកសារយោង

វិវាទអាចកើតឡើងនៅក្នុងកន្លែងការងារ ទោះជាការចាត់ចែងល្អយ៉ាងណាក៏ដោយ។ ដោយហេតុនេះហើយ និយោជក និង កម្មករនិយោជិត គួរប្រមើលមើលពីវិវាទទាំងឡាយ ហើយបង្កើតអោយមានយុទ្ធសាស្រ្តនៅក្នុង ការដោះស្រាយវិវាទនៅពេលដែលវាកើតឡើង ។

លើកលែងតែនិយោជក និង កម្មករនិយោជិតព្រមព្រៀងគ្នាលើប្រព័ន្ធផ្សេងមួយទៀតនៃការដោះស្រាយវិវាទ ពួកគេត្រូវតែ អនុវត្តតាមនីតិវិធីនៃការដោះស្រាយវិវាទដូចមានចែងនៅក្នុងជំពូកទី១២នៃច្បាប់ស្តីពីការងារ ។

យោងតាមច្បាប់ស្តីពីការងារនិយោជក និងកម្មករនិយោជិតអាចដោះស្រាយវិវាទរបស់ពួកគេតាមវិធីមួយចំនួន។

វិធីទាំងនេះរួមមាន:

- ការចរចា
- ការផ្សះផ្សា
- ការដោះស្រាយដោយអាជ្ញាកណ្តាល
- កូដកម្ម /ឡុកអៅ
- ប្តឹងទៅតុលាការ

### ដំណាក់កាលសំរាប់ដោះស្រាយវិវាទការងាររួម



## ១១.១ វិវាទបុគ្គល និង វិវាទការងាររួម

ច្បាប់ស្តីពីការងារ មាត្រា ៣០០ និង៣០២

ដំណាក់កាលទាំងឡាយដែលកម្មករនិយោជិត និង និយោជកត្រូវការអនុវត្តតាមដើម្បីដោះស្រាយវិវាទ គឺអាស្រ័យទៅលើថាតើវិវាទនេះជាវិវាទការងាររួម ឬវិវាទបុគ្គល ។

### ១១.១.១ វិវាទបុគ្គល

ច្បាប់ស្តីពីការងារ មាត្រា ៣០០
សេចក្តីបង្គាប់អាជ្ញាកណ្តាល១០ /០៣

វិវាទបុគ្គលគឺជាវិវាទដែលពាក់ព័ន្ធទៅនឹងនិយោជក និង កម្មករនិយោជិតម្នាក់ ឬច្រើននាក់ដាច់ដោយឡែកពីគ្នា។

### ១១.១.២ វិវាទការងាររួម

ច្បាប់ស្តីពីការងារ មាត្រា ៣០២
សេចក្តីបង្គាប់អាជ្ញាកណ្តាល ១០ /០៣
៥៨/១០ និង ១១៩/១២(១)

វិវាទការងាររួមពាក់ព័ន្ធទៅនឹងកម្មករនិយោជិតមួយក្រុម និង និយោជកម្នាក់ ឬ ច្រើននាក់ ។ ប្រសិនបើសហជីពមួយ ពាក់ព័ន្ធនឹងវិវាទមួយ នៅពេលនោះ ជាទូទៅគេត្រូវចាត់ទុកថាជាវិវាទការងាររួម ។

វិវាទការងាររួមក៏អាចពាក់ព័ន្ធទៅនឹងកម្មករនិយោជិតដែលគ្មានសហជីពផងដែរ ប្រសិនបើពួកគេធ្វើឡើងជាក្រុម ។

## ១១.២ នីតិវិធីបណ្តឹងតវ៉ាមិនសុខចិត្ត/បុគ្គលិកទំនាក់ទំនង

សារាចរ ២១ / ៩៩

និយោជកជាច្រើនបានបង្កើតនីតិវិធីបណ្តឹងនៅក្នុងកន្លែងធ្វើការ ដោយការពិគ្រោះយោបល់ជាមួយកម្មករនិយោជិតរបស់គេ ដើម្បីអោយវិវាទអាចត្រូវបានដោះស្រាយយ៉ាងរហ័ស និង យុត្តិធម៌ ។

ច្បាប់ស្តីពីការងារ មិនបានតម្រូវអោយនិយោជកបង្កើតកំរិតនីតិវិធីបណ្តឹងនៅក្នុងកន្លែងធ្វើការទេ ប៉ុន្តែច្បាប់តម្រូវអោយនិយោជក មានបុគ្គលិកទំនាក់ទំនងទទួលខុសត្រូវក្នុងការដោះស្រាយ សំណើកម្មករនិយោជិត និង ពាក្យបណ្តឹងតវ៉ាមិនសុខចិត្ត ។

### ១១.២.១ ការតែងតាំងបុគ្គលិកទំនាក់ទំនង

មុននឹងតែងតាំងបុគ្គលិកទំនាក់ទំនង និយោជកត្រូវតែពិគ្រោះយោបល់ជាមួយតំណាងកម្មករនិយោជិត ដើម្បីស្វែងរកការព្រមព្រៀងក្នុងការជ្រើសរើសអ្នកដែលអព្យាក្រិត និង ឯករាជ្យ ។

### ១១.២.២ តួនាទីរបស់បុគ្គលិកទំនាក់ទំនង

បុគ្គលិកទំនាក់ទំនងត្រូវតែជូនដំណឹងទៅនិយោជក ប្រសិនបើកម្មករនិយោជិតដាក់ពាក្យបណ្ដឹងដែលបុគ្គលិកទំនាក់ទំនងនោះមិនអាចដោះស្រាយបាន ។

ប្រសិនបើបុគ្គលិកទំនាក់ទំនងមិនអាចដោះស្រាយបញ្ហាបាន នៅពេលនោះនិយោជកត្រូវតែជួបកម្មករនិយោជិត ឬ តំណាងរបស់គេ។ ប្រតិភូបុគ្គលិក ឬ មន្ត្រីសហជីពអាចជួយកម្មករនិយោជិតនៅក្នុងប្រជុំនោះ។

ប្រសិនបើភាគីទាំងឡាយគ្មានការព្រមព្រៀងនឹងគ្នាទេ ពួកគេត្រូវជូនដំណឹងទៅអធិការការងារ ដើម្បីធ្វើការផ្សះផ្សាបន្តទៀត ។

## ១១.៣ ការផ្សះផ្សា

### ១១.៣.១ ការផ្សះផ្សាវិវាទបុគ្គលដោយស្ម័គ្រចិត្ត

ច្បាប់ស្ដីពីការងារ មាត្រា ៣០០ - ៣០១
ប្រកាស ៣១៨/០១

ការផ្សះផ្សាវិវាទបុគ្គលគឺធ្វើឡើងដោយស្ម័គ្រចិត្ត មិនថានិយោជក ឬក៏កម្មករនិយោជិតអាចដាក់ពាក្យបណ្ដឹងទៅក្រសួងទទួលបន្ទុកវិស័យការងារ ដើម្បីធ្វើការផ្សះផ្សាវិវាទរបស់ពួកគេមុននឹងទៅតុលាការ។ ប៉ុន្តែ ប្រសិនបើភាគីមួយស្នើអំពីផ្សះផ្សាវិវាទបុគ្គល ភាគីមួយត្រូវតែទៅចូលរួមក្នុងការផ្សះផ្សាបានទទួលជោគជ័យ និយោជក និង កម្មករនិយោជិតត្រូវតែអនុវត្តតាមការព្រមព្រៀងដែលធ្វើនៅពេលផ្សះផ្សានោះ ។ ប្រសិនបើការផ្សះផ្សាមិនបានជោគជ័យ វិវាទអាចត្រូវដាក់ទៅតុលាការ ។

### ១១.៣.២ ការផ្សះផ្សាវិវាទការងាររួមជាភាគពួកិច្ច

ច្បាប់ស្ដីពីការងារ មាត្រា ៣០២ - ៣០៨
ប្រកាស ៣១៧/០១

លើកលែងតែមានការព្រមព្រៀងលើនីតិវិធីដោះស្រាយវិវាទផ្សេងពីនេះ ភាគីទាំងឡាយនៃវិវាទការងាររួមត្រូវជូនដំណឹងទៅក្រសួងទទួលបន្ទុកវិស័យការងារអំពីវិវាទរបស់ពួកគេ ។ ក្រសួងការងារត្រូវព្យាយាមធ្វើការផ្សះផ្សាវិវាទការងាររួម ។

### ១១.៣.៣ គ្មានកូដកម្ម ឬ ឡុកអៅត្នុង អំឡុងពេលផ្សះផ្សា

ច្បាប់ស្ដីពីការងារ មាត្រា ៣០៦និង ៣២០

ក្នុងរយៈពេលផ្សះផ្សា កម្មករនិយោជិតមិនអាចធ្វើកូដកម្ម រីឯនិយោជកមិនអាចធ្វើឡុកអៅទេ ។

### ១១.៣.៤ កិច្ចព្រមព្រៀងផ្សះផ្សាដែលចងភាគពួកិច្ច

ច្បាប់ស្ដីពីការងារ មាត្រា ៣០៧និង ៣១៥

ការព្រមព្រៀង ដែលសំរេចបានក្នុងពេលផ្សះផ្សាវិវាទរួមត្រូវតែអនុវត្ត ហើយនិយោជកត្រូវតែបិទផ្សាយកិច្ចព្រមព្រៀងនេះ នៅកន្លែងធ្វើការ និងក្នុងការិយាល័យការងារមូលដ្ឋាន ។

## ១១.៤ ការដោះស្រាយដោយអាជ្ញាកណ្តាល

បើសិនជាការផ្សះផ្សាវិវាទការងាររួមទទួលបានជោគជ័យ ក្រសួងទទួលបន្ទុកវិស័យការងារនឹងបញ្ជូនវិវាទនោះទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

ច្បាប់ស្តីពីការងារ មាត្រា ៣០៩-៣១៧
ប្រកាស ០៩៩/០៤

## ១១.៤.១ គ្មានកូដកម្ម ឬ ឡុកអៅក្នុងអំឡុងពេលដំណើរការដោះស្រាយដោយអាជ្ញាកណ្តាល

ក្នុងអំឡុងពេលដោះស្រាយដោយអាជ្ញាកណ្តាល កម្មករនិយោជិតមិនអាចធ្វើកូដកម្ម ហើយនិយោជកមិនអាចធ្វើឡុកអៅបានទេ ។ កន្លងមកក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបដិសេធមិនបើកសវនាការទេ លុះត្រាតែភាគីបញ្ឈប់ កូដកម្ម ឬ ឡុកអៅរជាមុនសិន ។

ច្បាប់ស្តីពីការងារ មាត្រា ៣២០
ប្រកាស ០៩៩/០៤
សេចក្តីបង្គាប់អាជ្ញាកណ្តាល ០៤ /០៤
១៨/០៤ ២២៧/១២ និង ២២៨/១២

## ១១.៤.២ ការតម្រូវអោយសហការជាមួយក្រុមប្រឹក្សាអាជ្ញាកណ្តាល

ភាគីទាំងឡាយនៃវិវាទដែលត្រូវរួមក្នុង សវនាការដោយក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវតែចូលរួម គ្រប់បើការប្រជុំដែលអាជ្ញាកណ្តាលបានកោះហៅ និង ផ្តល់គ្រប់ឯកសារ និង ពត៌មានដទៃទៀតដែលអាជ្ញាកណ្តាលស្នើសុំ។

ច្បាប់ស្តីពីការងារ មាត្រា ៣១៥ និង ៣១៤
ប្រកាស ០៩៩/០៤
សេចក្តីបង្គាប់អាជ្ញាកណ្តាល ២២ /០៤
និង ២០១/១២

## ១១.៤.៣ សេចក្តីបង្គាប់អាជ្ញាកណ្តាល

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ហៅថា *សេចក្តីបង្គាប់* ។

សេចក្តីបង្គាប់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវតែអនុវត្ត លើកលែងតែភាគីណាមួយនៃវិវាទបដិសេធនឹងសេចក្តីបង្គាប់ក្នុងរយៈពេល ៨ថ្ងៃ បន្ទាប់ពីការជូនដំណឹងនៃសេចក្តីបង្គាប់នោះ ។ ក្នុងករណីនេះ សេចក្តីបង្គាប់ត្រូវ ចាត់ទុកថាគ្មានសុពលភាពអនុវត្តទេ ។

បើសិនជាគ្មានការបដិសេធចំពោះសេចក្តីបង្គាប់ទេនោះនិយោជកត្រូវតែបិទផ្សាយច្បាប់ចំលងនៃសេចក្តីសំរេចបង្គាប់នោះទាំងនៅកន្លែងធ្វើការនិង ការិយាល័យអធិការកិច្ចការងារមូលដ្ឋាន ។

បើចង់ដឹងច្បាស់អំពីព័ត៌មានបន្ថែមទៀត សូមមើលសៀវភៅដែលមានចំណងជើងថា *ក្រុមប្រឹក្សាអាជ្ញាកណ្តាល និង ដំណើរការដោះស្រាយវិវាទការងារនៅកម្ពុជា* ( រៀបរៀងដោយ *មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍* ក្រោមការឧបត្ថម្ភរបស់ អង្គការពល កម្មអន្តរជាតិ ក្នុងច្បាប់បោះពុម្ពផ្សាយលើកទីពីរ ឆ្នាំ២០០៤ ) ។

ច្បាប់ស្តីពីការងារ មាត្រា ៣១២ និង៣១៥
ប្រកាស ០៩៩/០៤
សេចក្តីបង្គាប់អាជ្ញាកណ្តាល
២០៩/១២(១)

## ១១.៥ កូដកម្ម និង ឡុកអៅ

រដ្ឋធម្មនុញ្ញ មាត្រា ៣៧
ច្បាប់ស្តីពីការងារ មាត្រា ៣១៨-៣៣៧
ប្រកាស ៣៣៨/០២
សារាចរ ០០៥ / ០០
សេចក្តីជូនដំណឹង ២០/ ០០

### ១១.៥.១ តើពេលណាដែលកម្មករនិយោជិតអាចធ្វើកូដកម្មបាន?

កូដកម្មនិយោជិតអាចធ្វើកូដកម្មដើម្បីការពារសិទ្ធ និង អត្ថប្រយោជន៍របស់ពួកគេ ប៉ុន្តែពួកគេអាចធ្វើដូច្នេះបានដោយស្របច្បាប់តែបន្ទាប់ពីវិធីផ្សេងៗ សំរាប់ដោះស្រាយវិវាទទាំងអស់បានបរាជ័យប៉ុណ្ណោះ។ ស្ទើរតែគ្រប់ករណីកម្មករនិយោជិត ត្រូវព្យាយាមអនុវត្តតាមទំរង់នៃការដោះស្រាយវិវាទទាំងឡាយដូចតទៅនេះមុនធ្វើកូដកម្ម:

- ការចរចា
- ការផ្សះផ្សា និង
- អាជ្ញាកណ្តាល ។

ច្បាប់ស្តីពីការងារ មាត្រា ៣២០
សេចក្តីបង្គាប់អាជ្ញាកណ្តាល ២៩ /០៣
និង ២០៤/១២(១២)

### ១១.៥.២ តើពេលណាដែលកម្មករនិយោជិតមិនអាចធ្វើកូដកម្មបាន ?

កូដកម្មដែលធ្វើឡើងដើម្បីបង្ខំនិយោជកអោយកែប្រែអនុសញ្ញារួម ឬ សេចក្តីបង្គាប់អាជ្ញាកណ្តាលដែលកំពុងតែនៅមានប្រសិទ្ធភាព គឺជាកូដកម្មខុសច្បាប់ ។

ច្បាប់ស្តីពីការងារ មាត្រា ៣២១

### ១១.៥.៣ នីតិវិធីច្បាប់ក្នុងការធ្វើកូដកម្ម

មុនពេលធ្វើកូដកម្ម កម្មករនិយោជិតត្រូវតែអនុវត្តតាមនីតិវិធីដែលកំណត់នៅក្នុងលក្ខន្តិកៈរបស់សហជីព។នីតិវិធីទាំងនេះត្រូវតែរួមបញ្ចូលល័ក្ខខ័ណ្ឌតម្រូវដូចខាងក្រោមនេះ៖

ច្បាប់ស្តីពីការងារ មាត្រា៣២៣-៣២៩ ៣៣៦ និង ៣៣៧

*ការបោះឆ្នោតជាសំងាត់*

កូដកម្មមិនស្របច្បាប់ទេ ប្រសិនបើ សមាជិកនៃសហជីពមិនបានអនុម័តធ្វើកូដកម្មតាមការបោះឆ្នោតជាសំងាត់។

ច្បាប់ស្តីពីការងារ មាត្រា ៣២៣

*ការជូនដំណឹងជាមុន*

កូដកម្មនេះមិនស្របច្បាប់ទេ ប្រសិនបើសហជីពមិនបានជូនដំណឹងមុនចំនួន ៧ថ្ងៃ ពីការធ្វើកូដកម្មទៅនិយោជក និង ទៅក្រសួងទទួលបន្ទុកវិស័យការងារ ។

ច្បាប់ស្តីពីការងារ មាត្រា ៣២៤ ៣២៥ ៣២៧ និង ៣២៩

## ១១.៥.៤ កូដកម្មខុសច្បាប់

កូដកម្មដែលមិនស្របទៅនឹងនីតិវិធីដែលមានកំណត់នៅក្នុងច្បាប់ស្តីពីការងារ គឺជាកូដកម្មខុសច្បាប់។ កូដកម្មមិនធ្វើឡើងដោយសន្តិវិធីក៏ជាកូដកម្មខុសច្បាប់ដែរ។ មានតែតុលាការទេ ដែលអាចប្រកាសថា កូដកម្មមួយ ជាកូដកម្មខុសច្បាប់បាន ។

ច្បាប់ស្តីពីការងារ មាត្រា ៣៣៦ និង៣៣៧

## ១១.៥.៥ អហិង្សា

សកម្មភាពហិង្សាណាដែលធ្វើឡើងក្នុងអំឡុងពេលធ្វើកូដកម្មដោយភាគីណាមួយគឺជាកូដកម្មខុសច្បាប់។ និយោជកអាចដាក់វិន័យ ឬ បញ្ឈប់ការងារកម្មករនិយោជិតដោយសារទង្វើហិង្សា ដែលបានប្រព្រឹត្តក្នុងពេលធ្វើកូដកម្ម ។

ច្បាប់ស្តីពីការងារ មាត្រា ៣៣០ និង ៣៣៦
សេចក្តីបង្គាប់អាជ្ញាកណ្តាល ១៦/១១(១)

## ១១.៥.៦ សេរីភាពរបស់អ្នកមិនមែនជាកូដករ

កូដករ ត្រូវអនុញ្ញាតអោយកម្មករនិយោជិត ដែលចង់ទៅធ្វើការអំឡុងពេលធ្វើកូដកម្ម បានចូលទៅធ្វើការតាមបំណងរបស់គេ។ កូដករ មិនត្រូវគំរាមកំហែងអ្នកដែលមិនមែនជាកូដករទេ ។

ច្បាប់ស្តីពីការងារ មាត្រា ៣៣១

## ១១.៥.៧ គ្មានការដាក់ទណ្ឌកម្មលើកូដករ

ប្រសិនបើ និយោជកមិនអាចបង្ហាញថាកូដករបានប្រព្រឹត្តកំហុសទេ ពួកគេត្រូវអនុញ្ញាតអោយកម្មករនិយោជិតត្រលប់ទៅធ្វើការវិញដោយគ្មានការដាក់ទណ្ឌកម្ម នៅពេលដែលកូដកម្មបានបញ្ចប់ភ្លាម។ ការដែលគ្រាន់តែចូលរួមក្នុងកូដកម្មខុសច្បាប់ មិនមែនជាកំហុសធ្ងន់នោះទេ ។ ប៉ុន្តែការមិនត្រលប់មកធ្វើការវិញដោយគ្មានហេតុផលត្រឹមត្រូវ ក្នុងរយៈពេល ៤៨ម៉ោង បន្ទាប់ពីមានបញ្ហាពីតុលាការ គឺជាកំហុសធ្ងន់ ។

ច្បាប់ស្តីពីការងារ មាត្រា៣៣២-៣៣៣ និង ៣៣៧
សេចក្តីបង្គាប់អាជ្ញាកណ្តាល០៤/០៣ ១៨/០៤ ២២/០៤ ១៧/១០ ២២/១១(១និង២) ១៦៩/០៩(១) និង

ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានបកស្រាយវិធានអំពីការមិនត្រូវដាក់ទណ្ឌកម្មបន្ទាប់ពីកូដកម្មនេះ ក្នុងគោលបំណងមិនអោយនិយោជកអាចកាត់ប្រាក់រង្វាន់ការងារទៀងទាត់ ១០ដុល្លារ ពីកម្មករនិយោជិតដែលបានចូលរួមក្នុងកូដកម្មស្របច្បាប់ ។

ក្នុងករណីកូដកម្មស្របច្បាប់ និយោជកអាចកាត់ប្រាក់រង្វាន់ ១០ដុល្លារ តែសមាមាត្រប៉ុណ្ណោះ។ ឧទាហរណ៍ ប្រសិនបើកម្មករនិយោជិតធ្វើកូដកម្ម២ថ្ងៃ និយោជកអាចកាត់បន្ថយត្រឹមចំនួនទឹកប្រាក់ដូចខាងក្រោមនេះ:

$$= \frac{\text{២ថ្ងៃ} \times \text{១០ដុល្លារ}}{\text{២៦ថ្ងៃ}}$$

*= ០.៧៧ ដុល្លារ*

ឯកសារយោង

(ក្សាទុកប្រាក់រង្វាន់ដែលនៅសល់ ៩.២៣ដុល្លារ ប្រសិនបើកម្មករនិយោជិតបានបំពេញតាមល័ក្ខខ័ណ្ឌតម្រូវអោយធ្វើការដទៃទៀតក្នុង ១ខែ នោះ) ។

ក្នុងករណីកូដកម្មខុសច្បាប់ និយោជកអាចកាត់ប្រាក់រង្វាន់ការងារទៀងទាត់ ១០ដុល្លារ ទាំងអស់តែម្តង ។

## ១១.៥.៨ ការបើកប្រាក់ឈ្នួលក្នុងអំឡុងពេលធ្វើកូដកម្ម

ច្បាប់ស្តីពីការងារ មាត្រា ៣៣២
សេចក្តីបង្គាប់អាជ្ញាកណ្តាល ២០៨/១២(១២)

តាមផ្លូវច្បាប់ កម្មករនិយោជិតគ្មានសិទ្ធទទួលបាន ប្រាក់ឈ្នួលនៅពេលដែលពួកគេធ្វើកូដកម្មទេ ទោះជាកូដកម្មនោះជាកូដកម្មខុសច្បាប់ ឬ ស្របច្បាប់ក៏ដោយ។ ប៉ុន្តែជួនកាល ខាងផ្នែកគ្រប់គ្រង និងសហជីព អាចព្រមព្រៀងគ្នាបង់ប្រាក់ឈ្នួលអោយកម្មករនិយោជិតដែលធ្វើកូដកម្ម ដើម្បីជាចំណែកមួយនៃការដោះស្រាយវិវាទរបស់ពួកគេ ។

## ១១.៥.៩ គ្មានការជ្រើសរើសកម្មករនិយោជិតអោយចូលធ្វើការក្នុងអំឡុងពេលធ្វើកូដកម្ម

ច្បាប់ស្តីពីការងារ មាត្រា ៣៣៨
សេចក្តីបង្គាប់អាជ្ញាកណ្តាល ០៨/០៣ ១៨/០៨ ១៥/០៨ ១៧៨/១២(១២និង៣) ១៩៧/១២(១០)

និយោជក មិនអាចជ្រើសរើសកម្មករនិយោជិតអោយចូលធ្វើការជំនួសកម្មករនិយោជិតដែលធ្វើកូដកម្មទេ។ ទាក់ ទិននឹងបញ្ហានេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការដឹកជញ្ជូនវត្ថុធាតុដើមទៅធ្វើនៅក្នុងរោងចក្រផ្សេង នៅពេលកម្មករនិយោជិតកំពុងធ្វើកូដកម្ម មានន័យស្មើនឹងការជួលកម្មករនិយោជិតថ្មី អោយចូលធ្វើការក្នុងពេលមានកូដកម្ម ។

ប្រសិនបើនិយោជកបានជួលអ្នកធ្វើការជំនួសកម្មករនិយោជិតដែលកូដកម្ម និយោជកត្រូវតែបើកប្រាក់ឈ្នួលទៅអោយកម្មករនិយោជិត ដែលធ្វើកូដកម្មសំរាប់រយៈពេលធ្វើកូដកម្ម។ ក្រុមប្រឹក្សា អាជ្ញាកណ្តាលយល់ឃើញថា កូដករមានសិទ្ធិទទួលប្រាក់ឈ្នួលបានតាមមាត្រា ៣៣៨ តែក្នុង ករណីពួកគេអនុវត្តតាមនីតិវិធីស្របច្បាប់ក្នុងការធ្វើកូដកម្មតែប៉ុណ្ណោះ ។

## ១១.៥.១០ ឡុកអៅ

ច្បាប់ស្តីពីការងារ មាត្រា ៣១៨
៣១៩៣២២៣៦៩

ជាចំណែកមួយនៃវិវាទការងារ និយោជក ក៏អាចបិទទ្វារមិនអោយកម្មករនិយោជិតចូលធ្វើការបានផងដែរ។ ការធ្វើនេះហៅថា ឡុកអៅ។ សិទ្ធិឡុកអៅគឺត្រូវអនុវត្តតាមវិធាន និង ការដាក់កំហិតដូចគ្នានឹងសិទ្ធិកូដកម្មដែរ ។

បើសិន ជានិយោជកធ្វើឡុកអៅខុសច្បាប់ និយោជកត្រូវតែបង់ប្រាក់ឈ្នួលជូនកម្មករនិយោជិតសំរាប់រយៈពេលឡុកអៅនោះ ហើយក្រៅពីនេះ ទោសទណ្ឌផ្សេងៗទៀតក៏ត្រូវអនុវត្តផងដែរ ។.

# ផ្នែកទី១២ សហជីព និង ប្រតិភូបុគ្គលិក

ឯកសារយោង

## ១២.១ សេរីភាពក្នុងការបង្កើត និង ចូលរួមក្នុងសហជីព

ច្បាប់ស្តីពីការងារ មាត្រា ២៦៦ និង ២៧១

និយោជកមិនត្រូវបង្កភាពលំបាកចំពោះកម្មករនិយោជិតក្នុងការបង្កើតសហជីពទេ ។

និយោជកមិនអាចបង្ខំ ឬ ផ្តល់សំណូកអោយកម្មករនិយោជិតចូល ឬ មិនចូលជាសមាជិកសហជីពបានឡើយ ។

កម្មករនិយោជិតមានសិទ្ធិជាសមាជិករបស់សហជីព តាមការជ្រើសរើសរបស់ពួកគេ ។

## ១២.២ ការរើសអើងដោយឈរលើមូលដ្ឋានសមាជិកភាពសហជីព

ច្បាប់ស្តីពីការងារ មាត្រា ២៧៩
សេចក្តីបង្គាប់អាជ្ញាកណ្តាល ៥៧/១១ និង ១៥៥/១១

និយោជកមិនត្រូវពិចារណាលើសមាជិកភាពសហជីព ឬ ការចូលរួមក្នុងសកម្មភាពសហជីពនៅពេលធ្វើសេចក្តីសំរេចពាក់ព័ន្ធទៅនឹងការងារ ( ដូចជាការទទួលអោយធ្វើ ការតំឡើងថ្នាក់ ការបញ្ឈប់ពីការងារ។ល ។)

## ១២.៣ ការរួមបញ្ចូលនិយោជក និង កម្មករនិយោជិតនៅក្នុងសហជីព ឬ សមាគមតែមួយត្រូវបានហាមឃាត់

ច្បាប់ស្តីពីការងារ មាត្រា ២៦៦

គ្មានសហជីពណាមួយអាចតំណាងអោយទាំងកម្មករនិយោជិតផង និង ទាំងនិយោជកផងបាននោះទេ ។

## ១២.៤ គ្មានការជ្រៀតជ្រែកក្នុងប្រតិបត្តិការរបស់សហជីព

ច្បាប់ស្តីពីការងារ មាត្រា ២៨០
សេចក្តីបង្គាប់អាជ្ញាកណ្តាល ១៧/០៤

និយោជកមិនត្រូវបានអនុញ្ញាតអោយ:

- ជ្រៀតជ្រែ កនៅក្នុងការងាររបស់សហជីព ឬ
- ជួយឧបត្ថម្ភសហជីពដែលនៅក្រោមការត្រួតពិនិត្យរបស់និយោជក ឬ អង្គការនិយោជកជាដាច់ខាត ។

## ១២.៥ ការកាត់ប្រាក់ឈ្នួលក្នុងការបង់ប្រាក់ភាគទានសហជីព

ច្បាប់ស្តីពីការងារ មាត្រា ១២៩
ប្រកាស ៣០៥/០១
សេចក្តីបង្គាប់អាជ្ញាកណ្តាល ០៣/០៣ ០៥/០៣ ២៥/០៣ ៧៨/១១(១០) និង ១០៨/១២(១)

កម្មករនិយោជិត អាចផ្តល់អំណាចអោយនិយោជកកាត់ប្រាក់ឈ្នួលរបស់ពួកគេ ដើម្បីបង់ភាគទានសហជីព។ ការផ្តល់អំណាចនេះត្រូវតែសរសេរជាលាយលក្ខណ៍អក្សរ និង អាចបដិសេធវិញបានគ្រប់ពេលវេលា។

នៅពេលដែលកម្មករនិយោជិតផ្តល់អំណាចក្នុងការកាត់ប្រាក់ឈ្នួលដើម្បីបង់ភាគទានសហ ជីព និយោជកត្រូវកាត់ប្រាក់ឈ្នួល និង ផ្តល់ចំនួនទឹកប្រាក់ភាគទាននោះទៅសហជីពដែលពាក់ព័ន្ធ ។

## ១២.៦ ការការពារសកម្មជនសហជីពពីការបញ្ឈប់ពីការងារ

សូមអានផ្នែកទី ១០.៦ ខាងលើ ។

ឯកសារយោង

## ១២.៧ ប្រតិភូបុគ្គលិក

ច្បាប់ស្តីពីការងារ មាត្រា ២៨៣ -២៩៩
ប្រកាស ២៨៦ /០១

នៅក្នុងសហគ្រាសដែលមានកម្មករនិយោជិត ៨នាក់ ឬច្រើនជាង និយោជកត្រូវរៀបចំការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក។ ការបោះឆ្នោតរៀបចំក្នុងរយៈពេល ៦ខែ បន្ទាប់ពីបើកសហគ្រាស ។

ប្រតិភូបុគ្គលិក មានអណត្តិ ២ឆ្នាំ ហើយអាចត្រូវបានគេបោះឆ្នោតជ្រើសរើសារជាថ្មីបាន។ ប្រតិភូបុគ្គលិកមានភារកិច្ចនាំយកបញ្ហាព្រួយបារម្ភផ្សេងៗ ពីកម្មករនិយោជិតទៅនិយោជក និង អធិការការងារ ។

### ១២.៧.១ និយោជកទទួលខុសត្រូវចំពោះការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក

ច្បាប់ស្តីពីការងារ មាត្រា ២៨៧ -២៨៨ និង ២៩១
ប្រកាស ២៨៦ /០១
សេចក្តីបង្គាប់អាជ្ញាកណ្តាល ៥៨/១០(១) និង ១៨៩/១១(២)

និយោជកត្រូវរៀបចំការបោះឆ្នោត ដោយយោងទៅតាមនីតិវិធីដូចខាងក្រោមនេះ៖

- ពិគ្រោះយោបល់ជាមួយសហជីព (ប្រសិនបើមាន) មុនធ្វើការបោះឆ្នោត
- អនុញ្ញាតអោយសហជីពតំណាងតែងតាំងបេក្ខជន
- បិទផ្សាយកាលបរិច្ឆេទនៃការបោះឆ្នោតក្នុងរយៈពេល ១៥ថ្ងៃ និង ធ្វើការបោះឆ្នោតក្នុងរយៈពេល៤៥ ថ្ងៃ បន្ទាប់ពីទទួលសំណើពីកម្មករនិយោជិត សហជីព ឬអធិការការងារ
- បិទផ្សាយនីតិវិធីបោះឆ្នោត និង បញ្ជីឈ្មោះបេក្ខជន យ៉ាងតិច ៣ថ្ងៃមុនកាលបរិច្ឆេទបោះឆ្នោត
- អនុញ្ញាតអោយកម្មករនិយោជិតសំរាកពីការងារយ៉ាងតិច២ម៉ោង ដើម្បីធ្វើការពិចារណាពីបេក្ខជន
- បោះឆ្នោតដោយសំងាត់
- បោះឆ្នោតក្នុងម៉ោងធ្វើការ
- បោះឆ្នោតយ៉ាងតិច១៥ថ្ងៃ
  មុនពេលដល់កាលបរិច្ឆេទបញ្ចប់អណត្តិរបស់ប្រតិភូបុគ្គលិកដែលកំពុងកាន់មុខតំណែង
- រាយការណ៍ពីលទ្ធផលនៃការបោះឆ្នោតក្នុងរយៈពេល ៨ថ្ងៃ បន្ទាប់ពីការបោះឆ្នោត
- ចេញ ថ្លៃចំណាយលើការបោះឆ្នោត ។

### ១២.៧.២ ភាតព្វកិច្ចរបស់និយោជកចំពោះប្រតិភូបុគ្គលិក

ប្រកាស ២៨៦ /០១
សារាចរ ៤០/ ៩៨
សេចក្តីបង្គាប់អាជ្ញាកណ្តាល ៦៨/០៦(៣)

និយោជកត្រូវ:

- ផ្តល់អោយប្រតិភូបុគ្គលិកនូវ ទីកន្លែងធ្វើការ ទីកន្លែងប្រជុំ សំភារៈធ្វើការ និង កន្លែងសំរាប់ការបិទផ្សាយផ្សេងៗ ។

- ផ្តល់អោយប្រតិភូបុគ្គលិក និងសហជីពនូវទីកន្លែងសំរាប់ដាក់តាំងឈ្មោះ រូបភាព និង តួនាទីរបស់ប្រតិភូបុគ្គលិក និង អ្នកដឹកនាំសហជីព និង សកម្មភាពរបស់ពួកគេ ។
- ផ្តល់រយៈ ២ម៉ោង ក្នុងមួយសប្តាហ៍ ដោយមានប្រាក់ឈ្នួលទៅអោយប្រតិភូបុគ្គលិក ម្នាក់ៗ ដើម្បីធ្វើការរបស់ពួកគេ ។

ឯកសារយោង

## ១២.៧.៣ ប្រតិភូបុគ្គលិកដែលត្រូវបានការពារប្រឆាំងនឹងការបញ្ឈប់ពីការងារ

ច្បាប់ស្តីពីការងារ មាត្រា ២៩៣ -២៩៥
សេចក្តីបង្គាប់អាជ្ញាកណ្តាល ១៩៩/០៨(១)

និយោជកអាចបញ្ឈប់ការងារប្រតិភូបុគ្គលិក ឬ បេក្ខជនប្រតិភូបុគ្គលិកបាន លុះត្រាតែបន្ទាប់ពីបានទទួលសិទ្ធិអំណាចពីអធិការការងារ។ ការធ្វើដូចគ្នានេះ ក៏ត្រូវអនុវត្តផងដែរចំពោះបេក្ខជនដែលមិនបានជាប់ឆ្នោតក្នុងអំឡុងពេល៣ខែបន្ទាប់ពីការផ្សាយលទ្ធផលនៃការបោះឆ្នោត និងចំពោះអតីតប្រតិភូបុគ្គលិក ក្នុងអំឡុងពេល ៣ខែ បន្ទាប់ពីការបញ្ចប់អណត្តិរបស់ពួកគេ ( ចំពោះព័ត៌មានលំអិត សូមអានផ្នែក ១០.៦ ខាងលើ ) ។

## ១២.៧.៤ ភារកិច្ចរបស់ប្រតិភូបុគ្គលិក

ច្បាប់ស្តីពីការងារ មាត្រា ២៤ ៩៥ និង ២៨៤
ប្រកាស ២៨៦ /០១

ប្រតិភូបុគ្គលិកមានតួនាទីដូចខាងក្រោមៈ

- បង្ហាញនិយោជកអំពីការមិនសុខចិត្តទាក់ទងនឹងប្រាក់ឈ្នួល និង ការអនុវត្តន៍ច្បាប់ស្តីពីការងារបទបញ្ញត្តិទាំងឡាយ និង អនុសញ្ញារួមដែលកំពុងមានប្រសិទ្ធភាពអនុវត្ត
- បញ្ជូនពាក្យបណ្តឹងទៅអធិការការងារ
- ធានាអោយមាន ការអនុវត្តន៍បទបញ្ញត្តិ សុខភាព និង សុវត្ថិភាព
- ស្នើសុំអោយមានភាពល្អប្រសើរឡើងនូវល័ក្ខខ័ណ្ឌការងារ សុខភាព និង សុវត្ថិភាពនិងគ្រោះថ្នាក់ការងារ និង ជំងឺវិជ្ជាជីវៈ
- ពិគ្រោះយោបល់ជាមួយនិយោជក អំពីសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស ( សូមអានផ្នែក ២.៤.២ ខាងលើ )
- ពិគ្រោះយោបល់ជាមួយនិយោជកអំពីផែនការបញ្ឈប់ពីការងាររួមគ្នា ( សូមអានផ្នែកទី ១០.៥.១ ខាងលើ ) ។

## ១២.៧.៥ ចំនួនប្រតិភូបុគ្គលិកនៅក្នុងគ្រឹះស្ថាន

ច្បាប់ស្តីពីការងារ មាត្រា ២៨៥

សហគ្រាសត្រូវមានចំនួនប្រតិភូបុគ្គលិកដូចខាងក្រោមនេះ ដោយយោងតាមទំហំរបស់សហគ្រាស:

| ចំនួនកម្មករនិយោជិត | ចំនួនប្រតិភូបុគ្គលិក(+ ចំនួនប្រតិភូជំនួស) |
|---|---|
| ១-៧ | ០ |
| ៨-៥០ | ១ (+១) |
| ៥១-១០០ | ២ (+២) |
| ១០១-២០០ | ៣ (+៣) |
| ២០១+ | ប្រតិភូបុគ្គលិក ១នាក់ បន្ថែម និង ប្រតិភូជំនួយម្នាក់បន្ថែម រាល់ពេលដែលមាន កម្មករនិយោជិត១០០នាក់បន្ថែម ។ |

## ១២.៨ អនុសញ្ញារួម

ច្បាប់ស្តីពីការងារ មាត្រា ៩៦ - ១០១
ប្រកាស ២៨៧ /០១ និង ៣០៥/ ០១
សេចក្តីបង្គាប់អាជ្ញាកណ្តាល ១៨៨/១២(៥)

អនុសញ្ញារួម គឺជាកិច្ចព្រមព្រៀងរវាងកម្មករនិយោជិតមួយក្រុម និង និយោជកម្នាក់ ឬ ច្រើននាក់ អំពីប្រាក់ឈ្នួល និងលក្ខខ័ណ្ឌការងារ ។

អនុសញ្ញារួម អាចផ្តល់ប្រយោជន៍ដល់កម្មករនិយោជិតល្អប្រសើរជាងច្បាប់ ។ ប៉ុន្តែ បទបញ្ញត្តិរបស់អនុសញ្ញារួមដែលផ្តល់អត្ថប្រយោជន៍ទៅកម្មករនិយោជិតតិចជាងច្បាប់ មិនអាចអនុវត្តបានទេ។

**ឧទាហរណ៍:**

សហជីពនៅក្នុងរោងចក្រ K ចុះ ហត្ថលេខាលើអនុសញ្ញារួមដែលមានរយ:ពេល ៣ឆ្នាំ ដែលចែងថាកម្មករទទួលបានការឈប់សំរាកប្រចាំឆ្នាំចំនួនតែ ១២ថ្ងៃ ប៉ុណ្ណោះ។ ១ឆ្នាំបន្ទាប់ពីការចុះហត្ថ លេខាលើអនុសញ្ញារួមកម្មករនិយោជិតទាមទារសំរាកប្រចាំឆ្នាំ ១៨ ថ្ងៃ។

កម្មករនិយោជិតនៅក្នុងរោងចក្រ K នៅតែមានសិទ្ធិទទួលបានការឈប់សំរាក ១៨ថ្ងៃ ដោយសារបទបញ្ញត្តិរបស់អនុសញ្ញារួម ដែលផ្តល់អត្ថប្រយោជន៍ទៅកម្មករតិចជាងនៅក្នុងច្បាប់នេះ មិនអាចមានសុពលភាពអនុវត្តឡើយ ។

## ១២.៨.១ អ្នកណាខ្លះអាចរៀបចំធ្វើអនុសញ្ញារួម?

ច្បាប់ស្តីពីការងារ មាត្រា ៩៦(២) និង ២៧៧
ប្រកាស ៣០៥ /០១
សេចក្តីបង្គាប់អាជ្ញាកណ្តាល ២២/០៤
២៩/០៩ និង ១៤/១២(១)

ជាទូទៅកម្មករនិយោជិតនឹងត្រូវតំណាងដោយសហជីពនៅពេលចរចាអនុសញ្ញារួម។ សហជីពនេះ ត្រូវតែតំណាងឱ្យកម្មករនិយោជិតនៅក្នុងសហគ្រាស។ ក្រសួងទទួលបន្ទុកវិស័យការងារ គឺជាអ្នកសំរេចថាតើសហជីពមួយមាន ឬ គ្មានភាពជាអ្នកតំណាង ។

លើកលែងតែពុំមានសហជីពនៅក្នុងកន្លែងធ្វើការ ទើបនិយោជកអាចចរចាអនុសញ្ញារួមជាមួយប្រតិភូបុគ្គលិកបាន ។

## ១២.៨.២ ថិរវេលានៃអនុសញ្ញារួម

ច្បាប់ស្តីពីការងារ មាត្រា ៩៦ (៣)

អនុសញ្ញារួមអាច មានរយៈពេលជាក់លាក់ ឬ មិនជាក់លាក់។ នៅពេលដែលអនុសញ្ញារួមមានរយៈពេលជាក់លាក់ គឺមិនអាចលើសពី ៣ឆ្នាំ បានទេ ។

នៅពេលដែលអនុសញ្ញារួមមានរយៈពេលមិនកំណត់ អនុសញ្ញារួមនោះអាចលុបចោលបាន ប៉ុន្តែវានឹងនៅតែមានប្រសិទ្ធិភាពរយៈពេលមួយឆ្នាំ បន្ទាប់ពីផ្តល់ការជូនដំណឹងលុបចោលនោះ មក ។

ប្រតិភូបុគ្គលិកមិនអាចរៀបចំអនុសញ្ញារួម ដែលមានរយៈពេលយូរជាង ១ឆ្នាំ បានទេ ។

## ១២.៨.៣ កាតព្វកិច្ចក្នុងការចរចារួម

ប្រកាស ៣០៥ /០១ ប្រការ ១១
សេចក្តីបង្គាប់អាជ្ញាកណ្តាល ០៦ / ០៤
និង ២៩/៩

និយោជកត្រូវតែចរចាដោយស្មោះត្រង់ កាលណាតំណាងសហជីពស្នើសុំចរចាអនុសញ្ញារួម។ កាតព្វកិច្ចចរចាដោយស្មោះត្រង់រួមមានល័ក្ខខ័ណ្ឌតំរូវអោយៈ

- ព្រមព្រៀងលើវិធានដ៏សមហេតុផលសំរាប់ការចរចា
- ឆ្លើយតបទៅនឹងសំណើដែលធ្វើឡើងដោយសហជីពតាមវិធីដ៏សមហេតុផល
- ផ្តល់ធនធានដ៏សមរម្យ និង ព័ត៌មានទៅសហជីពដែលពាក់ព័ន្ធ នៅក្នុងការចរចាអនុសញ្ញារួម ។

## ១២.៨.៤ ការចុះបញ្ជីកាអនុសញ្ញារួម

ប្រកាស ២៤៧ /០១

និយោជកត្រូវចុះបញ្ជីអនុសញ្ញារួមនៅក្រសួងទទួលបន្ទុកវិស័យការងារ និង បិទអនុសញ្ញារួមនៅក្នុងកន្លែងធ្វើការ។

អត្ថបទអនុសញ្ញារួមដែលចុះកា បញ្ជី ត្រូវសរសេរជាភាសាខ្មែរ ។

## ១២.៨.៥ ការដោះស្រាយវិវាទ

ប្រកាសលេខ ១៩៧ /៩៧ ៣០៥ / ០១ ប្រការ ១២ និង ០៩៩/០៤ ប្រការ ៤៣ សេចក្តីបង្គាប់អាជ្ញាកណ្តាល ២៤ / ០៣ ២៨/ ០៣ និង ២៩/០៣

បើសិនជាភាគីទាំឡាយមិនអាចឈានដល់ការព្រមព្រៀង បង្កើតអនុសញ្ញារួម ក្នុងថិរវេលាដែលបានកំណត់ទេនោះ ពួកគេមានសិទ្ធិធ្វើកូដកម្ម ឬ ឡុកអៅ ប៉ុន្តែមិនមែនមុនពេលព្យាយាមដោះស្រាយវិវាទតាមការផ្សះផ្សា និង អាជ្ញាកណ្តាលនោះទេ ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចចេញសេចក្តីបង្គាប់ដែលមានតំលៃស្មើនឹងអនុសញ្ញារួម ។

# ផ្នែកទី ១៣ ការចងក្រងឯកសារ ការរក្សាទុកកំណត់ហេតុការបិទផ្សាយ

ឯកសារយោង

## ១៣.១ ប្រការបើក និង បិទសហគ្រាស

ច្បាប់ស្តីពីការងារ មាត្រា ១៧ - ១៩
ប្រការ ២៨៨ / ០១

និយោជកត្រូវតែធ្វើការប្រកាសបើកសហគ្រាសទៅក្រសួងទទួលបន្ទុកវិស័យការងារ។ ចំពោះសហគ្រាសដែលមានកម្មករនិយោជិតចំនួន ៨នាក់ ឬ ច្រើនជាងនេះ ឬ មានប្រើប្រាស់គ្រឿងយន្ត ការប្រកាសត្រូវធ្វើឡើងមុនពេលដែលបើកអាជីវកម្ម ។

ចំពោះសហគ្រាសដែលមានកម្មករនិយោជិតតិចជាង ៨នាក់ ការប្រកាសត្រូវធ្វើឡើងក្នុងរយៈ ពេល ៣០ថ្ងៃ បន្ទាប់ពីបើកសហគ្រាស ។

និយោជិតត្រូវធ្វើការប្រកាសបិទសហគ្រាសទៅ ក្រសួងទទួលបន្ទុកវិស័យការងារក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីការបិទសហគ្រាស ។

## ១៣.២ សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន

ច្បាប់ស្តីពីការងារ មាត្រា ២០
ប្រការ ២៦៧ / ០១

និយោជកទាំងអស់ត្រូវរក្សាសៀវភៅបញ្ជីប្រចាំគ្រឹះស្ថានដែលមានចុះឈ្មោះគ្រឹះស្ថាន ប្រភេទសកម្មភាព ពាក់ព័ន្ធ និងឈ្មោះ និង អាសយដ្ឋានរបស់និយោជក និង លេខរៀង និងហត្ថលេខាសង្ខេបរបស់អធិការការងារ ។

និយោជកត្រូតែរក្សាសៀវភៅបញ្ជីប្រចាំគ្រឹះស្ថានដែលប្រើរួចហើយអោយគង់ សំរាប់រយៈពេល ៣ឆ្នាំ និងអនុញ្ញាតអោយអធិការការងារអាចត្រួតពិនិត្យបានគ្រប់ពេលវេលា ។

## ១៣.៣ សៀវភៅបើប្រាក់ឈ្នួល

ច្បាប់ស្តីពីការងារ មាត្រា ៣៩-៤១
ប្រការ ២៦៧ / ០១

សៀវភៅបើកប្រាក់ឈ្នួលត្រូវតែរួមបញ្ចូលព័ត៌មានអំពីៈ

- កម្មករនិយោជិតម្នាក់ៗ
- ប្រាក់ឈ្នួលរបស់កម្មករនិយោជិត
- ការងារដែលកម្មករនិយោជិតធ្វើ និង
- ពេលវេលាដែលកម្មករនិយោជិតឈប់សំរាក ។

សៀវភៅបើកប្រាក់ត្រូវតែរក្សាទុកក្នុងការិយាល័យបេឡា ឬ ទីចាត់នៃសហគ្រាសរបស់និយោជក។
កំណត់ត្រាពីការបើកប្រាក់ ត្រូវតែរក្សាទុករយៈពេល ៣ឆ្នាំ ។
សៀវភៅបើកប្រាក់មានសុពលភាព លុះត្រាតែមានចុះលេខគ្រប់ទំព័រ និង ចុះហត្ថលេខាសង្ខេបដោយអធិការការងារ ។ អធិការការងារត្រូវតែទទួលបានការអនុញ្ញាតអោយពិនិត្យសៀវភៅបើកប្រាក់នៅពេលណាក៏បាន ។

## ១៣.៤ សេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិក

ច្បាប់ស្តីពីការងារ មាត្រា ២១

និយោជកត្រូវតែប្រកាសជូនដំណឹងទៅក្រសួងទទួលបន្ទុកវិស័យការងារ គ្រប់ពេលវេលាដែលគេជួលកម្មករនិយោជិតអោយធ្វើការឬ បញ្ឈប់ការងារ ។

## ១៣.៥ ប័ណ្ណការងារ និង សៀវភៅការងារសំរាប់កម្មករនិយោជិតកម្ពុជា និងបរទេស

ច្បាប់ស្តីពីការងារ មាត្រា ៣២ ៣៧ និង ២៦១

ប្រកាស ៥៦ / ០១ ១៤៧ / ០១

និង ១៦២/០១

សេចក្តីជូនដំណឹង ១៣/ ៩៧

សេចក្តីបង្គាប់អាជ្ញាកណ្តាល ២១ / ០៣

ប្រជាពលរដ្ឋខ្មែរគ្រប់រូប និង ជនបរទេសដែលកំពុងធ្វើការនៅ ក្នុងប្រទេសកម្ពុជា ត្រូវមានប័ណ្ណការងារ និងសៀវភៅការងារ។ គ្មានជនណាដែលអាចទទួលអោយធ្វើការដោយគ្មានប័ណ្ណការងារ និងសៀវភៅការងារបានទេ ។

និយោជកត្រូវធ្វើការកំណត់ត្រាអំពីការទទួលធ្វើការងារ និង បញ្ឈប់ការងារកម្មករនិយោជិត ប្រាក់ឈ្នួល និង ការកែប្រែប្រាក់ឈ្នួលរបស់ពួកគេ នៅក្នុងសៀវភៅការងារនិងប័ណ្ណការងាររបស់ពួកគេ ។

ក្នុងរយៈពេល ៧ថ្ងៃ បន្ទាប់ពីការចុះព័ត៌មានក្នុងសៀវភៅការងារ និងប័ណ្ណការងាររួចហើយ សៀវភៅការងារ និង ប័ណ្ណការងារនោះ ត្រូវតែដាក់សុំទិដ្ឋាការពីអធិការការងារ ។ ការកត់ត្រានេះត្រូវទទួលបានទិដ្ឋាការពីអធិការការងារក្នុងរយៈពេល ៧ថ្ងៃ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតគួរតែចេញសោហ៊ុយធ្វើប័ណ្ណការងារ និងសៀវភៅការងារតាមការកំណត់របស់ក្រសួង ។

## ១៣.៦ ការបិទផ្សាយ

ច្បាប់ស្តីពីការងារ មាត្រា ២៩ ១០៩

២៩៦ និង ៣១៥

សារាចរ ៤០ / ៩៨

និយោជក ត្រូវតែតំឡើងក្តារបិទផ្សាយព័ត៌មាននៅកន្លែងដែលសមស្រប ដែលងាយស្រួលដល់ការងារនិយោជិតអាច អានបាន ។

នៅលើក្តារនេះត្រូវតែមានបិទផ្សាយ:

- ប្រកាសប្រចាំឆ្នាំអំពីថ្ងៃឈប់បុណ្យដោយមានប្រាក់ឈ្នួល
- អនុសញ្ញារួមណាមួយក៏ដោយ
- សេចក្តីសំរេចរបស់និយោជក ឬ សេចក្តីសំរេចលើការចាត់ចែងដែលទាក់ទងនឹងកម្មករនិយោជិត
- បទបញ្ជាផ្ទៃក្នុង
- វិធានការសុខភាព និង សុវត្ថិភាពការងារ ឬ សេចក្តីព្រមានទាំងឡាយ
- ប្រាក់ឈ្នួលអប្បបរមា ដែលមានកំណត់ក្នុងច្បាប់ស្តីពីការងារ
- របាយការណ៍ស្តីពីការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក

- របាយការណ៍ស្តីពីកិច្ចព្រមព្រៀងផ្សះផ្សា និង សេចក្តីបង្គាប់អាជ្ញាកណ្តាល ដែលមាន ប្រសិទ្ធិភាពអនុវត្ត នៅកន្លែងការងារនោះ ។

និយោជកត្រូវអោយមានក្តារបិទប្រកាសផ្សេងមួយសំរាប់អោយសហជីព និង ប្រតិភូបុគ្គលិកប្រើប្រាស់ ។